ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

# ជីវវិទ្យា



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

## ថ្នាក់ទី ៧


បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្ដម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង គិមលី | លោក ស៊ូ គន្ធី |
| | លោក សួន សុជាតិ | លោកស្រី យឹម យីហ៊ុប |
| | លោកស្រី ហ៊ុយ ចន្ទូ | លោក ពុធ ដារិទ្ធ |
| **អ្នកវាយអត្ថបទ** | លោកស្រី ហាក់ ផាន្នី | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ជា សូផាត(រូបវិទ្យា) | លោក ស៊ុន ប៊ុណ្ណា(គីមីវិទ្យា) |
| | លោក វ៉ា វុទ្ធី (ជីវវិទ្យា) | លោក ជួន វណ្ណា(ផែនដីវិទ្យា) |
| **អ្នករចនាទំព័រ** | លោក ហាក់ វណ្ណថា | |
| **អ្នកឯកទេស** | លោក អ៊ឹង ហេង | |
| **គណៈកម្មការពិនិត្យ** | លោក អ៊ុច សំម | លោក ចាន់ ខេង |
| | លោកស្រី អ៊ាន សារិន | លោកស្រី សម្បត្តិ អ៊ាត |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២៣៨៥ អយក.ប្រក. ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។


ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©



**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពផ្សាយ ឆ្នាំ ២០១៨

ISBN 9-789-995-000-813

# អារម្ភកថា

សៀវភៅវិទ្យាសាស្ត្រសម្រាប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដែលគណៈកម្មការនិពន្ធយើងបានតាក់តែងឡើង ដើម្បីឆ្លើយតបតាមតម្រូវការរបស់សិស្សនិងគ្រូ ។ សៀវភៅវិទ្យាសាស្ត្រនេះមានបួនមុខវិជ្ជាគឺ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ។

រាល់ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះ អ្នកនិពន្ធបានរៀបចំពីកម្រិតងាយទៅកម្រិតលំបាក ហើយស្របតាមកម្មវិធីសិក្សាថ្មី និងស្របតាមវិធីវិទ្យាសាស្ត្រ ។

គណៈកម្មការនិពន្ធយើងខ្ញុំ រង់ចាំទទួលការរិះគន់ពីសំណាក់អ្នកគ្រូ លោកគ្រូ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ដើម្បីជួយកែលម្អសៀវភៅនេះឱ្យកាន់តែមានគុណភាពថែមទៀត ដើម្បីឆ្លើយតបទៅនឹងគោលដៅអប់រំជាតិ ។

**គណៈកម្មការនិពន្ធ**

ជីវវិទ្យា ទំព័រ

**ជំពូក 1 : បរិស្ថានធម្មជាតិ**........................151
1. ភាវៈរស់និងបរិស្ថានរបស់វា........................152
2. បរិស្ថានរូបនិងបរិស្ថានជីវៈ........................156
3. ទំនាក់ទំនងនៅក្នុងសហគមន៍........................164
**ជំពូក 2 : រុក្ខជាតិ**........................169
1. រុក្ខជាតិឥតផ្កា : ប៉ប្រក ........................170
2. រុក្ខជាតិមានផ្កា........................174
3. ដំណើកនាំក្នុងរុក្ខជាតិមានផ្កា........................182
**ជំពូក 3 : កោសិកា**........................187
1. រូបផ្តុំកោសិកា........................188
2. រូបផ្តុំសារពាង្គកាយមនុស្ស........................194
3. កោសិការុក្ខជាតិ........................200
**ជំពូក 4 : ការរំលាយអាហារ**........................205
1. រូបផ្តុំប្រដាប់រំលាយអាហារ........................206
2. ផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ........................208
3. ការរំលាយអាហារ........................214
4. ជំងឺនិងអនាម័យប្រដាប់រំលាយអាហារ........................220
**ជំពូក 5 : អាល់កុលនិងថ្នាំជក់**........................225
1. ថ្នាំ........................226
2. ថ្នាំជក់និងបារី........................232
3. គ្រឿងស្រវឹង........................240

# ជំពូក 1 បរិស្ថានធម្មជាតិ



*ព្រៃលិចទឹកបឹងទន្លេសាប*

រូបភាពនេះបង្ហាញពីព្រៃលិចទឹកបឹងទន្លេសាប ដែលជាស្ថានប្រព័ន្ធមួយសម្បូរទៅដោយភាវៈរស់ ។ ភាវៈរស់ទាំងអស់អាស្រ័យនឹងបរិស្ថានរបស់វា ។ វាក៏អាស្រ័យនិងភាវៈរស់ផ្សេងៗទៀត និងភាវៈគ្មានជីវិតផងដែរ ។ នៅក្នុងបរិស្ថានមួយ ភាវៈរស់មានឥទ្ធិពលលើគ្នាទៅវិញទៅមកតាមរបៀបផ្សេងៗគ្នា ។

មេរៀនទី

# 1 ភាវៈរស់និងបរិស្ថានរបស់វា

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យ ពពួក សហគមន៍ និងស្ថានប្រព័ន្ធ
- ❑ បង្ហាញពីទំនាក់ទំនងរវាងស្ថានប្រព័ន្ធ សហគមន៍ និងពពួក
- ❑ ប្រៀបធៀបស្ថានប្រព័ន្ធ និងសហគមន៍
- ❑ បង្ហាញលក្ខណៈខុសគ្នារវាងស្ថានប្រព័ន្ធច្នៃប្រឌិត និងស្ថានប្រព័ន្ធធម្មជាតិ ។

សមុទ្រឬវាលខ្សាច់ជាឧទាហរណ៍មួយក្នុងចំណោមបរិស្ថាននៅលើផែនដី ។ សារពាង្គកាយនីមួយៗមានទំនាក់ទំនងជាមួយបណ្ដាភាវៈមានជីវិត និងភាវៈគ្មានជីវិត ដែលបង្កើតបានជាបរិស្ថានរបស់សារពាង្គកាយនេះ ។

## 1. លំនៅឋាន



*រូបទី 1.1. សេះ*

សេះជាសារពាង្គកាយមួយ ។ សារពាង្គកាយប្រភេទខុសគ្នា រស់នៅក្នុងបរិស្ថានខុសគ្នា ។ សារពាង្គកាយមួយទទួលបានអាហារ ទឹក ជម្រក និងតម្រូវការផ្សេងទៀតសម្រាប់ការរស់នៅ ការលូតលាស់ និងការបន្តពូជពីមជ្ឈដ្ឋានរស់នៅផ្ទាល់របស់វា ។ បរិស្ថានដែលផ្ដល់ឱ្យនូវវត្ថុផ្សេងៗដល់សារពាង្គកាយដើម្បីរស់នៅ លូតលាស់ និងបន្តពូជហៅថា ***លំនៅឋាន*** ។

តំបន់មួយអាចមានលំនៅឋានច្រើន ។ ***ឧទាហរណ៍*** ទន្សាយរស់នៅក្នុងគុម្ពោតព្រៃ សត្វត្រសេះធ្វើសម្បុកនៅក្នុងដើមឈើ ។

សារពាង្គកាយផ្សេងៗគ្នា រស់នៅក្នុងលំនៅឋានខុសៗគ្នា ព្រោះតម្រូវការរបស់ពួកវាក្នុងការរស់នៅមានមិនដូចគ្នាទេ ។ ទន្សាយទទួលបានអាហារនិងជម្រកពីលំនៅឋានរបស់វា ។



*រូបទី 1.2. លំនៅឋាន*

## 2. ពពួក

សារពាង្គកាយមួយជាឯកត្ត មួយនៅក្នុងពពួក។ ***ឧទាហរណ៍*** ព្រលិតជាឯកត្ត មួយក្នុងពពួកព្រលិត។



*រូបទី 1.3. ពពួកព្រលិត*



*រូបទី 1.4. ពពួកកង្កែប*



*រូបទី 1.5. ពពួកត្រី*

នៅក្នុងលំនៅឋានមួយមានសារពាង្គកាយច្រើនប្រភេទរស់នៅ។ សារពាង្គកាយមួយប្រភេទអាចបន្តពូជហើយរស់នៅក្នុងលំនៅឋានពិសេសណាមួយ ដែលបង្កើតបានជា***ពពួក***។ ***ឧទាហរណ៍*** នៅក្នុងលំនៅឋានត្រពាំង មានពពួកផ្សេងៗរស់នៅ ដូចជា ពពួកព្រលិត ពពួកឈូក ពពួកត្រី ពពួកកង្កែប. ។

## 3. សហគមន៍

សារពាង្គកាយ ឬពពួកភាគច្រើនមិនអាចរស់នៅតែឯងបានទេ។ វាតែងរស់នៅនិងមានទំនាក់ទំនងជាមួយប្រភេទដទៃទៀត។ សារពាង្គកាយប្រភេទខុសៗគ្នា រស់នៅជាមួយគ្នាក្នុងកន្លែងណាមួយហៅថា ***សហគមន៍***។ ត្រី សត្វល្អិត កង្កែប និងរុក្ខជាតិទឹកជាសមាជិកនៃសហគមន៍ត្រពាំង។ ក៏ដូចគ្នាដែរ សត្វល្អិត បក្សី ដើមឈើនិងស្មៅបង្កើតបានជាសហគមន៍ព្រៃមួយ។ នេះជារបៀបមួយដែលពពួកទាំងនេះរស់នៅជាសហគមន៍ដោយមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកតាមការប្រើប្រាស់ធនធានរួមគ្នា ដូចជាអាហារ និងជម្រក។ ***ឧទាហរណ៍*** ដើមឈើអាចជាជម្រករបស់បក្សី។ សត្វតូចៗជីករូងក្រោមដើមឈើជាជម្រក។ សត្វល្អិតស៊ីស្លឹកឈើនិងស្មៅជាអាហារ។ បក្សីស៊ីសត្វល្អិត និងផ្លែឈើជាដើម។



*រូបទី 1.6. សហគមន៍ត្រពាំង*

# 4. ស្ថានប្រព័ន្ធ

សារពាង្គកាយទាំងអស់រស់នៅក្នុងបរិស្ថានខុសៗគ្នាជាច្រើន ។ ចាប់ពីតំបន់ប៉ូលរហូតដល់អេក្វាទ័រមានភាវៈរស់ជាច្រើនរស់នៅក្នុងដី ខ្យល់ ទឹក និងលើដី ។ សារពាង្គកាយនៃប្រភេទខុសៗគ្នាមួយក្រុមរស់នៅជាមួយគ្នាក្នុងកន្លែងមួយ ហើយមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងជាមួយភាវៈគ្មានជីវិតហៅថា ***ស្ថានប្រព័ន្ធ*** ។


រូបទី 1.7 ស្ថានប្រព័ន្ធព្រៃ

នៅក្នុងស្ថានប្រព័ន្ធព្រៃមួយ ភាវៈរស់ជាច្រើនរស់នៅទីនោះ ។ ខ្លះរស់នៅក្នុងដីនិងចិញ្ចឹមជីវិតដោយស៊ីសាកសពសត្វ និងរុក្ខជាតិ ។ សារពាង្គកាយធំៗ មានជ្រូកព្រៃ ឆ្កែចចក ខ្លាស្វែងរករំពារជាអាហារ ។ ទន្សាយស៊ីរុក្ខជាតិជាអាហារ ។ ខ្លាស៊ីចចក ចចកស៊ីទន្សាយ ហើយទន្សាយស៊ីរុក្ខជាតិ ។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថាមានភាវៈជាច្រើននៅក្នុងស្ថានប្រព័ន្ធដែលមានទំនាក់ទំនងនឹងគ្នា ។ រុក្ខជាតិ សត្វ និងភាវៈគ្មានជីវិតទាំងអស់នៅក្នុងស្ថានប្រព័ន្ធមានឥទ្ធិពលលើគ្នាទៅវិញទៅមក ។


រូបទី 1.8. ស្ថានប្រព័ន្ធធម្មជាតិនិងច្នៃប្រឌិត

ដូចជាស្ថានប្រព័ន្ធដទៃទៀតដែរ ស្ថានប្រព័ន្ធបឹងទន្លេសាបនៅប្រទេសកម្ពុជាសម្បូរទៅដោយភាវៈរស់ច្រើនប្រភេទ ។ ភាវៈរស់ស្វ័យជីព ( រុក្ខជាតិ) ជាសារពាង្គកាយដែលផលិតអាហារដោយខ្លួនឯងតាមការធ្វើរស្មីសំយោគដោយទាញយកថាមពលពីពន្លឺព្រះអាទិត្យ ។ ភាវៈរស់បរជីពមានរុក្ខាសីនិងមំសាសី ។ ក្រុមរុក្ខាសី (សត្វស៊ីរុក្ខជាតិ) មានប្លង់តុងសត្វនិងសារពាង្គកាយរស់នៅបាតបឹង ។ ក្រុមមំសាសី( សត្វស៊ីសាច់) អាចជាប្លង់តុងសត្វព្រមទាំងត្រីដែលស៊ីប្លង់តុងរុក្ខជាតិនិងត្រីផ្សេងៗទៀតជាអាហារ ។ អ្នកបំបែកជាសារពាង្គកាយប្លែកៗជាច្រើន ( បាក់តេរី ផ្សិត សត្វល្អិត ដង្កូវ ...)ដែលចិញ្ចឹមជីវិតដោយស៊ីសាកសពសត្វឬរុក្ខជាតិ ។ សារពាង្គកាយទាំងអស់នេះរស់នៅក្នុងកំណកម្ទេចបាតបឹង ។ ភាវៈគ្មានជីវិត(ពន្លឺព្រះអាទិត្យ សីតុណ្ហភាព ទឹកភ្លៀង ខ្យល់ ...) ធ្វើឱ្យភាវៈមានជីវិតងាយស្រួលក្នុងការរស់នៅ ។

រូបភាពទី 1.8 នេះ បង្ហាញពីស្ថានប្រព័ន្ធបីបែប : ត្រពាំង វាលស្មៅ និងវាលស្រែ ។ ត្រពាំង និងវាលស្មៅជាស្ថានប្រព័ន្ធធម្មជាតិ ចំណែកឯវាលស្រែ ជាស្ថានប្រព័ន្ធច្នៃប្រឌិត ដែលមនុស្សជាអ្នកបង្កើត ។ តើស្ថានប្រព័ន្ធធម្មជាតិ និងស្ថានប្រព័ន្ធច្នៃប្រឌិតមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?

ត្រពាំង និងវាលស្មៅពុំមានការថែរក្សាទេ ។ កន្លែងទាំងពីរនេះគ្មានការគ្រប់គ្រងឬត្រួតពិនិត្យដោយមនុស្សទេ ។ ដូចនេះវាមិនត្រូវការថាមពលបន្ថែមដើម្បីរក្សាផលិតភាពរបស់វាឡើយ ។ ភាវៈរស់ទាំងឡាយលូតលាស់ដោយឯកឯងនៅក្នុងស្ថានប្រព័ន្ធធម្មជាតិ ។

ផ្ទុយទៅវិញ ស្ថានប្រព័ន្ធវាលស្រែទទួលរងអំពើជាច្រើនពីមនុស្ស ។ មនុស្សជាអ្នកកំណត់លក្ខខណ្ឌឱ្យស្ថានប្រព័ន្ធវាលស្រែ ដូចជា ភ្ជួរ រាស់ដី ស្ទូងស្រូវ ដាក់ជី បញ្ចេញ ឬបញ្ចូលទឹកជាដើម ។ ដូចនេះ ភាវៈរស់នៅក្នុងស្ថានប្រព័ន្ធវាលស្រែត្រូវបានកំណត់ដោយមនុស្ស គឺវាមិនអាចលូតលាស់ដោយឯកឯងដូចនៅក្នុងស្ថានប្រព័ន្ធធម្មជាតិបានទេ ។ មនុស្សធ្វើសកម្មភាពទាំងនេះឡើងដើម្បីទទួលផលពីស្ថានប្រព័ន្ធវាលស្រែ ។

### មេរៀនសង្ខេប

- កន្លែងដែលសារពាង្គកាយរស់នៅ និងបន្តពូជហៅថា ***លំនៅឋាន*** ។
- ក្រុមសារពាង្គកាយមួយប្រភេទរស់នៅនិងបន្តពូជនៅកន្លែងណាមួយហៅថា ***ពពួក*** ។
- ពពួកផ្សេងៗរស់នៅនិងមានទំនាក់ទំនងរវាងគ្នានិងគ្នាក្នុងកន្លែងមួយ ហៅថា ***សហគមន៍*** ។
- សហគមន៍នៃភាវៈរស់នៅកន្លែងណាមួយ មានទំនាក់ទំនងជាមួយសហគមន៍នៃភាវៈរស់ផ្សេងទៀតនិងជាមួយភាវៈគ្មានជីវិត ដែលនៅជុំវិញវា បង្កើតបានជា***ស្ថានប្រព័ន្ធ*** ។
- ស្ថានប្រព័ន្ធមានពីរបែប គឺ***ស្ថានប្រព័ន្ធច្នៃប្រឌិត***និង***ស្ថានប្រព័ន្ធធម្មជាតិ*** ។

### ? សំណួរ

1. តើពពួកនិងសហគមន៍ខុសគ្នាដូចម្ដេច ? ចូរឱ្យឧទាហរណ៍ ។
2. តើស្ថានប្រព័ន្ធបឹងទន្លេសាបមានអ្វីខ្លះ ?
3. ចូរប្រៀបធៀបសហគមន៍ និងស្ថានប្រព័ន្ធ ។
4. ដូចម្ដេចហៅថា ស្ថានប្រព័ន្ធធម្មជាតិ ? ចូរឱ្យឧទាហរណ៍ ។
5. ដូចម្ដេចហៅថា ស្ថានប្រព័ន្ធច្នៃប្រឌិត ? ចូរឱ្យឧទាហរណ៍ ។
6. តើស្ថានប្រព័ន្ធធម្មជាតិ និងស្ថានប្រព័ន្ធច្នៃប្រឌិតមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?

មេរៀនទី

# 2 បរិស្ថានរូបនិងបរិស្ថានជីវៈ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីបរិស្ថានរូបនិងបរិស្ថានជីវៈនៅកន្លែងកំណត់មួយ
- ❑ បង្ហាញពីភាពចាំបាច់របស់បរិស្ថានរូបចំពោះសារពាង្គកាយ
- ❑ ពណ៌នាពីក្រុមសំខាន់ទាំងបីរបស់បរិស្ថានជីវៈនៅក្នុងស្ថានប្រព័ន្ធ ។

ប្រសិនបើយើងក្រឡេកមើលជុំវិញខ្លួន យើងនិងឃើញមាន រុក្ខជាតិ សត្វ ទឹក ដី ពន្លឺ . . . ។ ដូចនេះនៅក្នុងបរិស្ថាន តើភាវៈទាំងនេះមានទំនាក់ទំនងជាមួយគ្នាដូចម្ដេចខ្លះ ?

## 1. បរិស្ថានរូប

នៅក្នុងបរិស្ថានព្រៃមួយ មានដើមឈើ បក្សី សត្វធំ សត្វតូច និងភាវៈរស់ដទៃទៀត រស់នៅពឹងពាក់គ្នាទៅវិញទៅមក តាមរយៈអាហារ និងជម្រក ។ ក្រៅពីអាហារ និងជម្រក នៅមានភាវៈគ្មានជីវិតដូចជា ទឹក ដី ខ្យល់ ពន្លឺ... ដែលជា ***បរិស្ថានរូប*** ។ បរិស្ថានរូបជះឥទ្ធិពលទៅលើជីវិតរបស់សារពាង្គកាយ ហើយជារឿយៗវាកំណត់ប្រភេទសារពាង្គកាយដែលមានលទ្ធភាពរស់នៅក្នុងបរិស្ថានកំណត់មួយ ។ ដូចនេះបរិស្ថានរូបជួយកំណត់ប្រភេទណាមួយដែលអាចរស់បានក្នុងកន្លែងណាមួយ ។

### 1.1. ដី

ដីបង្កឡើងពីល្បាយធាតុរ៉ែជាមួយកាកសំណល់ពុករលួយរបស់សារពាង្គកាយងាប់ ។ ដីមានទាំងសមាសធាតុមានជីវិត និងគ្មានជីវិត ។ ប្រភេទដីនៅកន្លែងពិសេសមួយ ជួយកំណត់នូវប្រភេទរុក្ខជាតិ និងសារពាង្គកាយដទៃទៀតដែលរស់នៅកន្លែងនោះ ។




*រូបទី 2.1. ដើមស្វាយ*




*រូបទី 2.2. ជន្លេន*

## 1.2. ទឹក

ភាវៈរស់ទាំងអស់ត្រូវការទឹក ដើម្បីឱ្យការរស់នៅរបស់វាបានប្រសើរ ។ មួយផ្នែកធំនៃសមាសធាតុរបស់សារពាង្គកាយបង្កឡើងពីទឹក ។ ***ឧទាហរណ៍*** សារពាង្គកាយមនុស្សមានទឹកប្រហែល 65 % ។ រុក្ខជាតិ និងសារាយត្រូវការទឹក ពន្លឺព្រះអាទិត្យ និងឧស្ម័នកាបូនឌីអុកស៊ីត($CO_2$) ដើម្បីផលិតអាហាររបស់ពួកវាតាមរយៈរស្មីសំយោគ ។ ភាវៈរស់ផ្សេងទៀតត្រូវការរុក្ខជាតិធ្វើជាអាហារ ។ គ្មានសារពាង្គកាយណាមួយរស់បានយូរដោយគ្មានទឹកឡើយ ។



*រូបទី 2.3. បង្កួយ*

ស្បែករបស់ខ្ញុំមានស្រកា និងមិនជ្រាបទឹកដែលជួយការពារខ្លួនខ្ញុំមិនឱ្យបាត់បង់ទឹកច្រើន ។



*រូបទី 2.4. កង្កែប*

ខ្ញុំរស់នៅកន្លែងសើម ។ ខ្ញុំមានស្បែកស្ដើង ហើយសើមដែលជួយខ្ញុំក្នុងការដកដង្ហើម ។



*រូបទី 2.5. ដើមផ្កាវ៉ែយោល*

ខ្ញុំជារុក្ខជាតិនៅតំបន់ត្រូពិច ។ ខ្ញុំទទួលបានទឹកគ្រប់គ្រាន់ពេញមួយឆ្នាំ ។ ខ្ញុំបំភាយចំហាយទឹកតាមរន្ធនៅផ្ទៃខាងក្រោមស្លឹករបស់ខ្ញុំ ។



*រូបទី 2.6. ដើមដំបងយក្ស*

ខ្ញុំជារុក្ខជាតិនៅវាលខ្សាច់ ។ ដើម្បីកាត់បន្ថយការបាត់បង់ទឹក ស្លឹករបស់ខ្ញុំប្លែងជាបន្លា ហើយដើមប៉ោងដោយស្តុកទឹក ។ ដើមរបស់ខ្ញុំពណ៌បៃតង ពីព្រោះវាមាននាទីផលិតអាហារ ។

## 1.3. ពន្លឺព្រះអាទិត្យ

ពន្លឺព្រះអាទិត្យមានសារៈសំខាន់ណាស់សម្រាប់ដំណើរការរស្មីសំយោគ ។ វាក៏ជាកត្តាគ្មានជីវិតយ៉ាងសំខាន់សម្រាប់ភាវៈរស់ភាគច្រើន ។ នៅកន្លែងដែលគ្មានពន្លឺព្រះអាទិត្យ ដូចជាក្នុងបន្ទប់ក្រោមដីរុក្ខជាតិ និងសារាយមិនអាចលូតលាស់បានឡើយ ។



រូបទី 2.7. កំប្លោក



រូបទី 2.8. ដើមស្វាយ



រូបទី 2.9. ស្មៅ

ពួកយើងត្រូវការពន្លឺព្រះអាទិត្យ ដើម្បីផលិតអាហារតាមដំណើររស្មីសំយោគ ។



រូបទី 2.10. ប្រចៀវ



រូបទី 2.11. មេអំបៅ



រូបទី 2.12. សត្វចាប

ខ្ញុំជាសត្វដែលដេកនៅពេលថ្ងៃ
ហើយស្វែងរកអាហារតែនៅពេល
យប់តែប៉ុណ្ណោះ ។

យើងត្រូវការពន្លឺព្រះអាទិត្យដើម្បីស្វែងរកអាហារ
ចិញ្ចឹមជីវិត ។



រូបទី 2.13. ជន្លេន

ខ្ញុំមិនត្រូវការពន្លឺទេ ។ ខ្ញុំសម្របខ្លួនបានទៅនឹងទីងងឹត ។
ខ្ញុំរស់នៅក្នុងដី ។ ខ្ញុំក្បាលខ្លួនក្នុងដី ដើម្បីចៀសពីពន្លឺទៅ
រកកន្លែងដែលមានសំណើម ។

## 1.4. អុកស៊ីសែន

ជាទូទៅភាវៈរស់ទាំងអស់ត្រូវការអុកស៊ីសែន ($O_2$) សម្រាប់សកម្មភាពផ្សេងៗនៃជីវិត ។ $O_2$ ក៏មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ដំណើរការនៅក្នុងសារពាង្គកាយមនុស្ស ។ អ្នកអាចរស់បានត្រឹមតែ 2 – 3 នាទីប៉ុណ្ណោះ ដោយអវត្តមាន $O_2$ ។ សារពាង្គកាយរស់នៅលើផែនដីទទួលបាន $O_2$ ពីខ្យល់ ។ ក្នុងខ្យល់មាន $O_2$ ប្រហែល 20 % ។ ត្រីនិងសត្វទឹកផ្សេងទៀតទទួលបាន $O_2$ រលាយក្នុងទឹកជុំវិញវា ។



រូបទី 2.14. មនុស្សនិងសត្វស្លាប



រូបទី 2.15. រុក្ខជាតិបៃតង



រូបទី 2.16. ត្រីនិងសារាយ

សារពាង្គកាយភាគច្រើនត្រូវការអុកស៊ីសែនសម្រាប់ដកដង្ហើម ។

យើងស្រូបយក $O_2$ពីខ្យល់ ។

យើងស្រូបយក $O_2$ រលាយក្នុងទឹក ។

- ដើមកោងកាងរស់នៅក្នុងល្បាប់ភក់ ។ ឫសរបស់វាស្ថិតនៅក្នុងភក់ដែលខ្សត់អុកស៊ីសែន ។ វាដកដង្ហើមតាមឫសដែលលេចចេញពីភក់ ។ ឫសទាំងនេះមានរន្ធចំហតូចៗសម្រាប់ស្រូបយកអុកស៊ីសែនពីក្នុងខ្យល់ ។
- ត្រីក្រឹមដកដង្ហើមដោយស្រូបយក$O_2$ ពីខ្យល់ ។ ប្រសិនបើទឹកដែលវារស់នៅនោះមានអុកស៊ីសែនតិចតួច វាអាចងើបឡើងលើផ្ទៃទឹកដើម្បីស្រូបយក$O_2$ បន្ថែមទៀត ។ យើងសង្កេតឃើញមានត្រីមួយចំនួនតូចប៉ុណ្ណោះដែលអាចធ្វើបែបនេះបាន ។ ត្រីផ្សេងទៀតមិនអាចធ្វើបែបនេះបានឡើយ ។
- ព្រូនអាចរស់នៅក្នុងបរិស្ថានដែលមានអុកស៊ីសែនតិចតួច ឬក៏គ្មានតែម្តង ។ វារស់នៅក្នុងពោះវៀនតូចរបស់មនុស្ស ហើយចិញ្ចឹមជីវិតដោយសារអាហាររំលាយស្រាប់ដែលមាននៅទីនោះ ។



រូបទី 2.17. ដើមកោងកាង



រូបទី 2.18. ត្រីក្រឹម



រូបទី 2.19. ព្រូន

## 1.5. សីតុណ្ហភាព

សីតុណ្ហភាពប្រែប្រួលទៅតាមមជ្ឈដ្ឋានផ្សេងៗ ។ វាក៏ជាកត្តាមួយយ៉ាងសំខាន់សម្រាប់កំណត់ភាវៈរស់នៅលើផែនដី ។



*រូបទី 2.20. ដើមស្វាយ*

សីតុណ្ហភាពជះឥទ្ធិពលលើសកម្មភាពរស់នៅរបស់រុក្ខជាតិ និងសត្វ ។ ខ្ញុំរស់នៅក្នុងតំបន់ត្រូពិចដែលមានសីតុណ្ហភាពចន្លោះពី 20°C ទៅ 30°C ។

ខ្ញុំមានពណ៌បៃតងពេញមួយឆ្នាំ ។



*រូបទី 2.21. បង្កួយ*



*រូបទី 2.22. ពស់*

យើងរស់នៅលើវាលខ្សាច់ ដែលមានអាកាសធាតុក្តៅខ្លាំងនៅពេលថ្ងៃ និងត្រជាក់ខ្លាំងនៅពេលយប់ ។

ពេលយប់យើងលាក់ខ្លួននៅក្រោមដី ដើម្បីជៀសពីធាតុអាកាសត្រជាក់ខ្លាំង ។

យើងមិនអាចរក្សាសីតុណ្ហភាពក្នុងខ្លួនបានទេ ។ ដូចនេះពេលថ្ងៃយើងសន្ទឹងខ្លួនក្រោមកម្តៅព្រះអាទិត្យ ហើយនៅពេលព្រះអាទិត្យមានកម្តៅខ្លាំងពេក យើងជ្រកក្រោមម្លប់ ។

## 1.6. ប៉ូតង់ស្យែលអ៊ីដ្រូសែន (pH)

ទឹកត្រពាំង សមុទ្រ ដីមានកំហាប់សូលុយស្យុងខុសៗគ្នា ។ ខ្លះមានកំហាប់សូលុយស្យុងអាស៊ីតខ្ពស់ ឯខ្លះទៀតមានកំហាប់សូលុយស្យុងបាសខ្ពស់ ។ ខ្នាតសម្រាប់វាស់កំហាប់សូលុយស្យុងអាស៊ីត ឬបាសហៅថា ***ប៉ូតង់ស្យែលអ៊ីដ្រូសែន*** ឬ(pH) ។ កម្រិត (pH) របស់មជ្ឈដ្ឋាន ជាកត្តាមួយសំខាន់ដែលជះឥទ្ធិពលទៅលើភាវៈរស់ ហើយអាចកំណត់ប្រភេទភាវៈរស់នៅតាមលំនៅឋានរបស់វា ។



រូបទី 2.23. ផ្សោមនិងត្រីឆ្លាមសមុទ្រ

យើងរស់នៅក្នុងសមុទ្រដែលជាមជ្ឈដ្ឋានបាស ហើយមាន pH ប្រហែល8 ។

យើងជាសារពាង្គកាយដែលរស់នៅក្នុងទឹកសាប ។ ទឹកដែលមាន pH ប្រហែល7 ជាលំនៅឋាន ប្រសើរបំផុតសម្រាប់ពួកយើង ។



រូបទី 2.24. សារាយនិងត្រី

យើងជារុក្ខជាតិដែលលូតលាស់ក្នុងដីមាន **pH** ខុសៗគ្នា ។



រូបទី 2.25. ដើមកប្បាស



រូបទី 2.26. ដើមផ្កាវិយោល



រូបទី 2.27. ដើមសណ្ដែក

ខ្ញុំចូលចិត្តដីមានកំហាប់ សូលុយស្យុងអាស៊ីតតិចតួច ។

ខ្ញុំចូលចិត្តដីដែលមាន pH ក្នុងរង្វង់7 (មជ្ឈដ្ឋានណឺត) ។

ចំណែកខ្ញុំចូលចិត្តដីមាន សូលុយស្យុងកំហាប់បាសតិចតួច ។

## 2. បរិស្ថានជីវៈ

ផ្ទុយពីបរិស្ថានរូប បរិស្ថានជីវៈជាបរិស្ថានដែលមានភាវៈមានជីវិតទាំងអស់ ដូចជា រុក្ខជាតិ សត្វ បាក់តេរី ផ្សិត និងប្រូទីស ។

## 2.1. រុក្ខជាតិ



រូបទី 2.28. ដើមចេក

នៅក្នុងស្ថានប្រព័ន្ធ រុក្ខជាតិមានសារៈសំខាន់ណាស់ ។ រុក្ខជាតិជាប្រភពអាហារសម្រាប់ស្ថានប្រព័ន្ធ ។ រុក្ខជាតិបៃតងអាចផលិតអាហារដោយខ្លួនឯងតាមរយៈរស្មីសំយោគ ។ ដូចនេះគេចាត់ទុករុក្ខជាតិបៃតងជាអ្នកផលិត ( ឬភាវៈរស់ស្វ័យជីព) ។ អ្នកផលិតជាភាវៈរស់ ដែលផលិតអាហារក្នុងស្ថានប្រព័ន្ធ ។

## 2.2. សត្វ



រូបទី 2.29. សត្វខ្លា

នៅក្នុងស្ថានប្រព័ន្ធព្រៃក៏ដូចជាស្ថានប្រព័ន្ធផ្សេងទៀតដែរ សត្វត្រូវការអាហារចិញ្ចឹមជីវិត ។ សត្វមិនអាចផលិតអាហារដោយខ្លួនឯងបានឡើយ ។ វាត្រូវស៊ីភាវៈរស់ដទៃទៀតជាអាហារ ។ ដូចនេះសត្វជាអ្នកស៊ី (ភាវៈរស់បរជីព) ។ អ្នកស៊ីជាភាវៈរស់ដែលស៊ីសារពាង្គកាយដទៃជាអាហារ ។

រុក្ខជាតិជាអាហារយ៉ាងសំខាន់របស់សត្វ ។ ***ឧទាហរណ៍*** កំប្រុក ទន្សាយ ក្តាន់ ជាសត្វដែលស៊ីរុក្ខជាតិជាអាហារ ។ នៅក្នុងស្ថានប្រព័ន្ធ សត្វដែលស៊ីរុក្ខជាតិជាអាហារហៅថា ***អ្នកស៊ីលំដាប់ទីមួយ*** ( ឬរុក្ខាសី) ។

ចំណែកសត្វមួយចំនួនទៀតមិនស៊ីរុក្ខជាតិជាអាហារទេ ។ សត្វប្រភេទនេះ វាស៊ីសត្វផ្សេងទៀតជាអាហារ ។ **ឧទាហរណ៍** ខ្លែងស្រាកស៊ីកណ្តុរ បក្សីស៊ីសត្វល្អិត និងដង្កូវ ខ្លាស៊ីប្រើស ក្តាន់ ។ សត្វទាំងអស់នេះគេហៅថា ***អ្នកស៊ីលំដាប់ទីពីរ*** ( មំសាសី) ។

## 2.3. អ្នកបំបែក



រូបទី 2.30. ផ្សិត

នៅក្នុងស្ថានប្រព័ន្ធព្រៃក៏ដូចជានៅក្នុងស្ថានប្រព័ន្ធផ្សេងទៀតដែរ មានភាវៈរស់មួយក្រុមទៀតដូចជា បាក់តេរីនិងផ្សិត ។ តើភាវៈរស់ប្រភេទនេះរស់នៅក្នុងស្ថានប្រព័ន្ធដូចម្តេច ?

ភាវៈរស់ប្រភេទនេះភាគច្រើនមិនមែនជាអ្នកផលិត ហើយក៏មិនស៊ីភាវៈរស់ផ្សេងទៀតជាអាហារដែរ ។ តើពួកវាទទួលបានអាហារនៅទីណា ?

ពួកវាស៊ីអាហារដែលជាកាកសំណល់រុក្ខជាតិនិងសាកសពសត្វ ។ ភាវៈរស់ប្រភេទនេះហៅថា ***អ្នកបំបែក*** ។ អ្នកបំបែកជាភាវៈរស់ដែលចិញ្ចឹមជីវិតលើកាកសំណល់រុក្ខជាតិឬសាកសពសត្វ ។ អ្នកបំបែកបាន បំប្លែងកាកសំណល់ទាំងនោះឱ្យទៅជាជីធម្មជាតិ ។ **បន្ទាប់មកជីទាំងអស់នោះត្រូវបានប្រើ**ប្រាស់នៅក្នុងស្ថានប្រព័ន្ធ ។ ***ឧទាហរណ៍*** នៅក្នុងកំណាកម្ទេចបាតបឹងទន្លេសាប អ្នកបំបែកអាចជាសារពាង្គកាយប្លែកៗជាច្រើនដូចជា បាក់តេរី ផ្សិត សត្វល្អិត ដង្កូវ... ដែលចិញ្ចឹមជីវិតនៅលើសាកសពសត្វឬកាកសំណល់រុក្ខជាតិរលួយ ។

## មេរៀនសង្ខេប

- ក្នុងស្ថានប្រព័ន្ធ រួមមានបរិស្ថានរូប (ភាវៈគ្មានជីវិត) និង**បរិស្ថានជីវៈ** (ភាវៈមានជីវិត) ។ ភាវៈគ្មានជីវិតរួមមានទឹក ដី ពន្លឺ សីតុណ្ហភាព អុកស៊ីសែននិង pH ។ ភាវៈគ្មានជីវិតកំណត់នូវប្រភេទសារពាង្គកាយ ដែលរស់នៅក្នុងមជ្ឈដ្ឋានមួយ ។
- ភាវៈមានជីវិតក្នុងស្ថានប្រព័ន្ធមានរុក្ខជាតិ សត្វ ប្រូទីស បាក់តេរី ។ រុក្ខជាតិបៃតង ជា**អ្នកផលិត**នៅក្នុងស្ថានប្រព័ន្ធ ។ សត្វជា**អ្នកស៊ី**នៅក្នុងស្ថានប្រព័ន្ធ ។ បាក់តេរី និងផ្សិតជា**អ្នកបំបែក**នៅក្នុងស្ថានប្រព័ន្ធ ។

## សំណួរ

1. តើភាវៈមានជីវិត និងភាវៈគ្មានជីវិត មានលក្ខណៈខុសគ្នាដូចម្តេចខ្លះ ? ចូរឱ្យឧទាហរណ៍យ៉ាងតិចបីចំពោះប្រភេទភាវៈនីមួយៗ ។
2. ហេតុអ្វីបានជាទឹកនិងពន្លឺព្រះអាទិត្យនៃបរិស្ថានរូបមានសារៈសំខាន់សម្រាប់សារពាង្គកាយ ?
3. ដូចម្តេចហៅថាប៉ូតង់ស្យែលអ៊ីដ្រូសែន ?
4. ចូរពណ៌នាពីសារពាង្គកាយបីក្រុមសំខាន់ក្នុងស្ថានប្រព័ន្ធ ។
5. ហេតុអ្វីបានជាអ្នកបំបែកមានសារៈសំខាន់នៅក្នុងស្ថានប្រព័ន្ធ ?
6. តើអ្នកបំបែកក្នុងបឹងទន្លេសាបមានអ្វីខ្លះ ?
7. តើអ្នកបំបែកមានប្រយោជន៍ដូចម្តេចសម្រាប់បឹងទន្លេសាប ?

មេរៀនទី

# 3 ទំនាក់ទំនងនៅក្នុងសហគមន៍

**ចប់មេរៀននេះ សិស្សអាច**

- ឱ្យនិយមន័យពាក្យ " សហប្រាណ "
- ឱ្យឧទាហរណ៍ទំនាក់ទំនងទាំងបីក្នុងស្ថានប្រព័ន្ធ
- ប្រៀបធៀបរវាងភាពប្រជួយ ភាពបន្ទម និងបរាសិតភាព ។

តើស្ថានប្រព័ន្ធនិងសហគមន៍ខុសគ្នាដូចម្តេច ? ស្ថានប្រព័ន្ធមួយមានបរិស្ថានរូបនិងបរិស្ថានជីវៈ ។ ចំណែកសហគមន៍ គឺជាបរិស្ថានជីវៈនៅកន្លែងណាមួយតែប៉ុណ្ណោះ ។ នៅក្នុងសហគមន៍មួយមានភាវៈមានជីវិតជាច្រើនដែលមានអន្តរទំនាក់ទំនងរវាងគ្នានិងគ្នា ។ ជាទូទៅអន្តរទំនាក់ទំនងរវាងភាវៈរស់ និងភាវៈរស់មានបីបែបសំខាន់ គឺការប្រកួតប្រជែង ជីវភាព ( សត្វរំពា)និងសហប្រាណ ។ នៅក្នុងមេរៀននេះ យើងសិក្សាតែសហប្រាណតែប៉ុណ្ណោះ ។

ពាក្យថា "សហប្រាណ" មានន័យថា " រស់នៅជាមួយគ្នា" ។ សហប្រាណជាទំនាក់ទំនងមួយដែលនៅក្នុងនោះសារពាង្គកាយមួយរស់នៅលើ ក្បែរ ឬនៅក្នុងសារពាង្គកាយមួយផ្សេងទៀត ។ ទំនាក់ទំនងសហប្រាណអាចទទួលផលប្រយោជន៍ពីភាគីតែម្ខាង ឬទាំងសងខាង ។ ពេលខ្លះភាគីម្ខាងទទួលផលប្រយោជន៍ដោយបំផ្លាញភាគីដៃគូ ។ ទំនាក់ទំនងសហប្រាណមានបីប្រភេទ: ភាពប្រជួយ ភាពបន្ទម និងបរាសិតភាព ។

## 1. ភាពប្រជួយ






*រូបទី3.1 កណ្ដៀរស៊ីឈើពុក*

នៅក្នុងធម្មជាតិ ភាវៈរស់រស់នៅដោយពឹងពាក់គ្នាទៅវិញទៅមក ។ ទំនាក់ទំនងមួយបែបដែលនៅក្នុងនោះសារពាង្គកាយពីរប្រភេទអាស្រ័យគ្នានិងទទួលផលពីគ្នាទៅវិញទៅមកហៅថា***ភាពប្រជួយ*** ។

ពួកវាមិនអាចរស់នៅដោយឡែកពីគ្នាបានទេ ។ ភាពប្រជួយកើតមាននៅក្នុងចំណោមរុក្ខជាតិ សត្វ ប្រូទីស ( សត្វឯកកោសិកា) ផ្សិត ។ ***ឧទាហរណ៍*** កណ្ដៀររស់នៅក្នុងកំណាត់ឈើពុកមួយ ។ វាស៊ីឈើ ប៉ុន្តែវាមិនអាចរំលាយឈើបានឡើយ ។ ឈើមិនអាចប្រើប្រាស់ជាថាមពលនៅក្នុងសារពាង្គកាយកណ្ដៀរ ។ តែមានប្រូទីសមួយប្រភេទដែលរស់នៅក្នុងប្រដាប់រំលាយអាហាររបស់កណ្ដៀរ អាចរំលាយឈើបាន ។ ដូចនេះប្រូទីសរំលាយឈើសម្រាប់កណ្ដៀរ ហើយកណ្ដៀរក៏អាចប្រើប្រាស់ឈើដែលរំលាយដោយប្រូទីសសម្រាប់ជាថាមពល ។ ប្រូទីសមានជម្រកនៅក្នុងខ្លួនកណ្ដៀរ ។ ប្រូទីសក៏ប្រើប្រាស់ឈើជាថាមពលសម្រាប់ពួកវាផងដែរ ។




***រូបទី32 លីកែន***

## 2. បរាសិតភាព

ទំនាក់ទំនងរវាងសារពាង្គកាយពីរដែលនៅក្នុងនោះសារពាង្គកាយមួយរស់នៅក្នុងឬលើសារពាង្គកាយមួយទៀតមាននាទីជាធ្នូលហៅថា ***បរាសិតភាព*** ។ សារពាង្គកាយដែលទទួលផលពីធ្នូលហៅថា ***បរាសិត*** ។ បរាសិតអាចបំផ្លាញសារពាង្គកាយធ្នូល ដោយវាធ្វើឱ្យសកម្មភាពមេតាបូលីសរបស់ធ្នូលចុះខ្សោយ ឬផ្អាក និង ជាយថាហេតុសម្លាប់ធ្នូល ។

ភាវៈរស់ជាច្រើន ជាបរាសិត ។ មូសជាបរាសិតមួយប្រភេទដែលចិញ្ចឹមជីវិត ដោយបឺតឈាមមនុស្ស និងឈាមសត្វផ្សេងៗទៀតជាអាហារ ។ មនុស្ស និងសត្វដែលមូសបឺតឈាម គឺជា***ធ្នូល*** ។ មូសអាចបំផ្លាញធ្នូលនិងផ្ទេរមេរោគដែលបង្កជំងឺដល់ធ្នូលថែមទៀតផង ។




*រូបទី3.3 បរាសិត*

## 3. ភាពបន្ទម

ភាពបន្ទមជាទំនាក់ទំនងមួយប្រភេទ ដែលនៅក្នុងនោះសារពាង្គកាយមួយបានផលពីធ្នូល ដោយគ្មានផ្តល់ផលប្រយោជន៍ ឬទុក្ខទោសដល់ធ្នូលហៅថា ***ភាពបន្ទម*** ។ សារពាង្គកាយដែលទទួលផលហៅថា ***បន្ទម*** ។ ក្នុងករណីខ្លះ សារពាង្គកាយធ្នូលគ្រាន់តែជាកន្លែងស្នាក់នៅ (ជម្រក) សម្រាប់សារពាង្គកាយដទៃទៀតតែប៉ុណ្ណោះ ។ អរគីដេជាឧទាហរណ៍មួយនៃបន្ទម ។ អរគីដេលូតលាស់នៅលើដើមឈើដោយសារឬសរបស់វាដែលអាចស្រូបយកសារធាតុចិញ្ចឹមនិងទឹកពីខ្យល់ ។

កូនខ្ចៅសមុទ្រមួយប្រភេទដែលមានសំបករាងកោណ ភ្ជាប់ខ្លួនទៅនឹងសំបកងាវ ឬក្តាម ។ ការភ្ជាប់បែបនេះងាយស្រួលឱ្យវាចាប់យកអាហារពីមជ្ឈដ្ឋានទឹកជុំវិញខ្លួន ហើយវាពុំមានផ្តល់ទុក្ខទោសដល់សត្វដែលវាភ្ជាប់ជាមួយនោះទេ ។



*រូបទី3.4 អរគីដេ*



*រូបទី3.5 កូនខ្ចៅសមុទ្រ*

## មេរៀនសង្ខេប

- សហប្រាណជាទំនាក់ទំនងមួយដែលនៅក្នុងនោះ សារពាង្គកាយមួយរស់នៅក្បែរ លើ ឬក្នុងសារពាង្គកាយមួយផ្សេងទៀត ។ ទំនាក់ទំនងសហប្រាណមានបីបែប : ភាពប្រជួយ ភាពបន្ទម និងបរាសិតភាព ។
- **ភាពប្រជួយ** ជាទំនាក់ទំនងមួយបែបដែលនៅក្នុងនោះសារពាង្គកាយពីររស់នៅជាមួយគ្នានិងទទួលផលពីគ្នាទៅវិញទៅមក ។
- **ភាពបន្ទម** ជាទំនាក់ទំនងមួយប្រភេទ ដែលនៅក្នុងនោះសារពាង្គកាយមួយបានផលពីធ្នូល ដោយគ្មានផ្តល់ផលប្រយោជន៍ ឬទុក្ខទោសដល់ធ្នូលទេ ។
- **បរាសិតភាព** ជាទំនាក់ទំនងរវាងសារពាង្គកាយពីរ ដែលនៅក្នុងនោះសារពាង្គកាយមួយរស់នៅក្នុង ឬលើសារពាង្គកាយធ្នូល ហើយទទួលបានផលប្រយោជន៍ពីធ្នូល ។

## សំណួរ

1. សារពាង្គកាយមួយទទួលបានផលប្រយោជន៍ ហើយសារពាង្គកាយមួយទៀតពុំមានរងឥទ្ធិពលអ្វី តើវាជាទំនាក់ទំនងអ្វី ?
2. នៅក្នុងទំនាក់ទំនងរវាងមនុស្ស និងសត្វមូស តើសារពាង្គកាយមួយណាជាបរាសិត មួយណាជាធ្នូល ?
3. ភាគីទាំងពីរទទួលបានផលប្រយោជន៍ដូចគ្នា តើវាជាទំនាក់ទំនងអ្វី?
4. ចូរឱ្យឧទាហរណ៍យ៉ាងតិចពីរ នូវទំនាក់ទំនងនីមួយៗ ខាងលើ ។

## សំណួរនិងលំហាត់ជំពូក 1

### I. ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. កន្លែងដែលសារពាង្គកាយមួយទទួលបានអាហារ និងជម្រកជា :

☐ក. ស្ថានប្រព័ន្ធ ☐ខ. លំនៅឋាន ☐គ. ពពួក ☐ឃ. សហគមន៍ ។

2. ក្នុងចំណោមភាវៈខាងក្រោម តើមួយណាជាភាវៈនៃបរិស្ថានរូប ?

☐ក. ប្រើស ☐ខ. ទន្សាយ ☐គ. ដើមស្វាយ ☐ឃ. ពន្លឺព្រះអាទិត្យ ។

3. ផ្នែកដែលមានជីវិតនៅក្នុងស្ថានប្រព័ន្ធជា :

☐ក. បរិស្ថាន ☐ខ. លំនៅឋាន ☐គ. ពពួក ☐ឃ. ត្រពាំង ។

4. ទំនាក់ទំនងដែលទទួលបានផលទាំងសងខាងជា ៖

☐ក. ភាពប្រជួយ ☐ខ. ភាពបន្ទម ☐គ. បរាសិតភាព ☐ឃ. ការប្រកួតប្រជែង ។

5. សារពាង្គកាយដែលផលិតអាហារដោយខ្លួនឯងគឺ ៖

☐ក. អ្នកស៊ី ☐ខ. អ្នកបំបែក ☐គ. ធ្មូល ☐ឃ. អ្នកផលិត ។

6. គេចាត់ទុកមនុស្សដែលបរិភោគបាយជា ៖

☐ក. អ្នកស៊ីលំដាប់ទី 2 ☐ខ. អ្នកស៊ីលំដាប់ទី 1 ☐គ. អ្នកផលិត ☐ឃ. អ្នកបំបែក ។

## II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. សារពាង្គកាយនៃប្រភេទតែមួយដែលបង្កើតកូនចៅ និងរស់នៅក្នុងលំនៅឋានណាមួយបង្កើតបានជា . . . . . ។

2. ចំការពោតជាស្ថានប្រព័ន្ធ . . . . . . . ។ ចំណែកឯទឹកជ្រោះជាស្ថានប្រព័ន្ធ . . . . . . ។

3. បាក់តេរី និងផ្សិតដែលចិញ្ចឹមជីវិតនៅលើសាកសពសត្វនិងកាកសំណល់រុក្ខជាតិជា . . . . . . ។

4. ទំនាក់ទំនងដែលភាគីទាំងសងខាង ទទួលបានផលដូចគ្នាហៅថា . . . . . . . ។

## III. សំណួរ

1. តើគត្តារូបកំណត់ប្រភេទសារពាង្គកាយយ៉ាងដូចម្តេច ? ចូរឱ្យឧទាហរណ៍ ។

2. ចូររៀបតាមលំដាប់ពីកម្រិតតូចទៅធំនូវពាក្យទាំងនេះ ៖ សារពាង្គកាយ ស្ថានប្រព័ន្ធ សហគមន៍ បរិស្ថាន ពពួក ។

3. តើសារពាង្គកាយប្រភេទខុសៗគ្នាទាំងអស់នៅក្នុងស្ថានប្រព័ន្ធព្រៃមួយសន្មតថាជាពពួក ឬក៏ជាសហគមន៍ ? ចូរពន្យល់ ។

4. ដូចម្តេចហៅថាសហប្រាណ ? ចូរឱ្យឧទាហរណ៍ប្រភេទនីមួយៗនៃសហប្រាណ ។

5. ចំពោះប្រភេទនីមួយៗនៃសហប្រាណ ចូរពន្យល់ថាតើសារពាង្គកាយពីរប្រភេទមានឥទ្ធិពលលើគ្នាទៅវិញទៅមកយ៉ាងដូចម្តេច ?

6. ខ្លា សេះ ស្មៅ ជាពពួកបីបែបដែលរស់នៅក្នុងស្ថានប្រព័ន្ធព្រៃ ។ តើពពួកទាំងបីបែបនេះមានទំនាក់ទំនងជាមួយគ្នាដូចម្តេចដែរ ?

7. ពណ៌នាពីសារពាង្គកាយសំខាន់បីក្រុមនៅក្នុងស្ថានប្រព័ន្ធ ។ ចូរឱ្យឧទាហរណ៍បញ្ជាក់ ។

8. តើអ្នកផលិត (រុក្ខជាតិបៃតង) មានសារៈសំខាន់ដូចម្តេចខ្លះ ?

## ជំពូក 2

# រុក្ខជាតិ



តើរុក្ខជាតិបៃតងទាំងអស់សុទ្ធតែជារុក្ខជាតិមានផ្កាឬទេ ?

នៅជុំវិញខ្លួនយើង រុក្ខជាតិមានផ្កាមានច្រើនប្រភេទណាស់ ។ រុក្ខជាតិខ្លះតូច ដូចជាស្មៅកំប្លោក រុក្ខជាតិខ្លះទៀតធំដូចជាដើមឈើហូបផ្លែ ។ ទោះបីជាវាមានរូបរាងខុសគ្នា ក៏វានៅមានលក្ខណៈមួយដូចគ្នាដែរត្រង់ថានៅពេលពេញវ័យវានឹងចេញផ្កា ។ រុក្ខជាតិភាគច្រើនចេញផ្កាតាមរដូវ ដូចជាដើមឈូក ដើមក្បោក ។ ខ្លះទៀតចេញផ្កាពេញមួយឆ្នាំ ដូចជាផ្កាកុលាប ។ ខ្លះទៀតពេញមួយជីវិតរបស់វាចេញផ្កាតែមួយដង រួចងាប់ទៅវិញ ដូចជាដើមឫស្សី ស្ដៅ ... ។ យើងក៏ធ្លាប់បានឃើញរុក្ខជាតិបៃតង ខ្លះទៀតមិនដែលចេញផ្កាទាល់តែសោះគឺពពួករុក្ខជាតិឥតផ្កាដូចជា ប៉ប្រក ។

មេរៀនទី

# 1 រុក្ខជាតិឥតផ្កា : បំប្រែក

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រដាប់លូតលាស់និងប្រដាប់បន្តពូជរបស់បំប្រែក
- ❑ បង្ហាញពីវដ្តនៃការបន្តពូជរបស់បំប្រែក
- ❑ យល់ពីសារប្រយោជន៍នៃការបន្តពូជរបស់រុក្ខជាតិ ។

រុក្ខជាតិមួយចំនួនធំ មានការបន្តពូជដោយភេទដែលប្រព្រឹត្តទៅដោយសារផ្កា ហើយបង្កបានជាគ្រាប់ ។ គ្រាប់ធានាការរាលដាលនៃសន្តានក្រោយ ។ បំប្រែកជារុក្ខជាតិឥតផ្កា ហើយឥតបង្កើតគ្រាប់ទេ ។

តើវាបន្តពូជដូចម្តេច ? តើការរាលដាលនៃសន្តានក្រោយប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

បំប្រែកច្រើនដុះនៅលើច្រាំងថ្មចោត លើដើមឈើធំៗ លើជញ្ជាំងចាស់ៗ ឬក្រោមម្លប់ឈើ ។ វាជារុក្ខជាតិមានអាយុវែង ។

## 1. ប្រដាប់លូតលាស់

បំប្រែកជារុក្ខជាតិម្យ៉ាងលូតលាស់ដោយសារគ្លៀង ។ គ្លៀងរបស់វាគឺជាដើមក្រោមដី ។ ដើមវាមានស្រកាពណ៌ត្នោតនិងមានឫស ។ ស្លឹកជាចំណែកនៅលើដី ដែលមានអ័ក្សត្រង់ឡើងលើ ហើយមានស្លឹកតែកពីរជួរនៅសងខាងអ័ក្ស ។ នៅពេលស្លឹកវានៅតូច វារមូរជារាងខ្យងហៀន ។

## 2. ប្រដាប់បន្តពូជ



រូបទី 1.1. ផ្ទៃខាងក្រោមរបស់ស្លឹកមានស្ព័រង់




រូបទី 1.2. ស្ព័រង់

នៅចុងរដូវស្លឹកឈើលាស់ លើផ្ទៃខាងក្រោមនៃស្លឹករបស់ចំប្រកមានកូនថង់តូចៗ ។ មុនដំបូង ថង់តូចៗនេះមានពណ៌បៃតង ក្រោយមកប្រែជាពណ៌ត្នោត ។ ថង់តូចៗនេះគឺជា ***ស្ប៉រង់*** ។

ស្ប៉រង់ភ្ជាប់ទៅលើផ្ទៃស្លឹកដោយសារកន្ទុយរបស់វា ។ នៅរដូវប្រាំង ស្ប៉រង់ស្ងួត ហើយរហែក បញ្ចេញ ***ស្ប៉*** មកក្រៅ ដែលងាយរសាត់តាមខ្យល់ ។

កាលណាស្ប៉ធ្លាក់ទៅលើដីសើម វាដុះបានជាស្លឹកមួយបន្ទះពណ៌បៃតង ដែលមានរាងដូចជាបេះដូងហៅថា ***ប្រូតាល់*** ។ ប្រូតាល់ដុះចាក់ជាប់ទៅនិងដីដោយសាររោមជញ្ជក់តូចៗ ។ នៅលើផ្ទៃខាងក្រោមនៃប្រូតាល់មាន

- សរីរាង្គបន្តពូជឈ្មោលហៅថា ***អង់តេរីឌី*** មានរាងជាថង់មួយ ។ កាលណាទុំ វាបញ្ចេញកោសិកាបន្តពូជឈ្មោល ***អង់តេរ៉ូសូអ៊ីត*** ជាច្រើន ។ អង់តេរ៉ូសូអ៊ីតមានរូបរាងតូចល្អិត ដែលយើងមិនអាចមើលនឹងភ្នែកទទេបានទេ ។ ប៉ុន្តែយើងអាចមើលវាឃើញដោយសារមីក្រូទស្សន៍ ។
- សរីរាង្គបន្តពូជញី ***អាកេកូន*** មានរាងដូចជាកូនដប ហើយបង្កប់ជ្រៅទៅក្នុងប្រូតាល់ ។ នៅក្នុងអាកេកូនមានកោសិកាបន្តពូជញី ***អូអូស្វ៊ែ*** ។ កោសិកាបន្តពូជញីមានទំហំធំ ។




*រូបទី 13. ប្រដាប់បន្តពូជរបស់ចំប្រក*

## 3. ការបន្តពូជ

បន្ទាប់ពីមានសំណើម អង់តេរីឌីក៏របើក ហើយបញ្ចេញអង់តេរ៉ូសូអ៊ីតដែលអាចហែលដោយសាររោមដ៏វែងរបស់វា ។ កាលណាអង់តេរ៉ូសូអ៊ីតណាមួយបានចូលទៅក្នុងអាកេកូន វារួមផ្សំជាមួយនិងអូស្វ៊ែ ហើយបង្កើតបានជាស៊ុត ។ នេះគឺជា ***ការបង្កកំណើត*** ។ ស៊ុតចិញ្ចឹមជីវិតដោយសារប្រូតាល់ ហើយរីកចម្រើនឡើងបានជាកូនរុក្ខជាតិមួយដែលមានឫស ដើម និងស្លឹក ។ វាជាចំប្រកមួយដើមថ្មីផ្សេងទៀត ។ បន្ទាប់មកប្រូតាល់ដែលអស់សារធាតុបម្រុង ក៏ស្វិតបាត់ទៅ ។




*រូបទី 1.4. ការបង្កកំណើតរបស់ចំប្រក*

## 4. វដ្តបន្តពូជរបស់ចំប្រក

វដ្តបន្តពូជរបស់ចំប្រកមានការឆ្លាស់គ្នារវាងឯកត្តៈពីរ គឺរុក្ខជាតិពេញវ័យបង្កើត***ស្ប៉័*** និងប្រូតាល់បង្កើត ***កោសិកាបន្តពូជ***។




*រូបទី 1.5. វដ្តបន្តពូជរបស់ចំប្រក*




*គំនូសបំព្រួញការបន្តពូជរបស់បំប្រក*

## មេរៀនសង្ខេប

- ដើមបំប្រក គឺជាក្លៀងដែលស្ថិតនៅក្នុងដី ។
- ផ្ទៃខាងក្រោមនៃស្លឹកបំប្រកមានស្ប៉រ៉ង់ ដែលនៅក្នុងនោះមានស្ប៉ ។ ផ្ទៃខាងក្រោមនៃប្រូតាល់មានកោសិកាបន្តពូជឈ្មោល (អង់តេរ៉ូស្សូអ៊ីត) និងកោសិកាបន្តពូជញី (អូស្វ៊ែ) ។
- កាលណាកោសិកាបន្តពូជញី និងកោសិកាបន្តពូជឈ្មោលជួបគ្នា វាបង្កើតបានជាស៊ុត ហើយលូតលាស់ជាកូនរុក្ខជាតិថ្មី ។

## ? សំណួរ

1. ដូចម្ដេចដែលហៅថា អង់តេរីឌី ? ដូចម្ដេចដែលហៅថា អាកេកូន ?
2. ដូចម្ដេចដែលហៅថា អង់តេរ៉ូស្សូអ៊ីត ? ដូចម្ដេចដែលហៅថា អូស្វ៊ែ ?
3. ចូរសរសេរសង្ខេបវដ្ដបន្តពូជរបស់បំប្រក ។
4. ហេតុអ្វីបានជាគេថា បំប្រកបន្តពូជដោយភេទ ?

មេរៀនទី

# 2 រុក្ខជាតិមានផ្កា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រដាប់លូតលាស់និងប្រដាប់បន្តពូជរបស់រុក្ខជាតិមានផ្កា
- ❑ បង្ហាញពីនាទីនៃសរីរាង្គនីមួយៗរបស់រុក្ខជាតិមានផ្កា
- ❑ កំណត់បានពីលក្ខណៈពិសេសរបស់រុក្ខជាតិមានផ្កា
- ❑ ស្រឡាញ់និងថែរក្សាធម្មជាតិ ជាពិសេសរុក្ខជាតិ ។

រុក្ខជាតិមានផ្កាជារុក្ខជាតិដែលមានលក្ខណៈស្មុំគ្រាំហើយសំខាន់ជាងគេ ។ ក្នុងចំណោមរុក្ខជាតិទាំងនោះ ខ្លះមានដើមទន់ ពណ៌បៃតងគឺ ***រុក្ខជាតិស្មៅ* ។ *ឧទាហរណ៍*** ស្មៅ ស្បូវ កក់ ។ រុក្ខជាតិខ្លះទៀតមានដើមធំ ដើមនិងមែកក្រាសរឹង ហើយពណ៌ត្នោត ។វាជា ***រុក្ខជាតិឈើ* ។ *ឧទាហរណ៍*** ដើមស្វាយ នាងនួន ។ វាបន្តពូជតាមរយៈផ្កា ហើយបង្កបានជាគ្រាប់ ។ គ្រាប់ធានាការពង្រាយនៃសន្តានក្រោយ ។

រុក្ខជាតិស្មៅឬរុក្ខជាតិឈើជារុក្ខជាតិមានផ្កាដែលផ្នែកលើដីរបស់វាមាន ដើម មែក ស្លឹក និងផ្កា ហើយផ្នែកក្នុងដីមានឫស ។ ឫស ដើម មែក និងស្លឹកជាប្រដាប់លូតលាស់ ។ ផ្កាជាប្រដាប់បន្តពូជ ។ បណ្តាសរីរាង្គទាំងនេះមាននាទីផ្សេងៗពីគ្នាក្នុងការទ្រទ្រង់ជីវិតរបស់វា ។

## 1. ប្រដាប់លូតលាស់

ប្រដាប់លូតលាស់របស់រុក្ខជាតិមាន ឫស ដើម មែក និងស្លឹក ។

### 1.1. ឫស

#### ក. ប្រព័ន្ធឫស

ធម្មតាប្រព័ន្ធឫសស្ថិតនៅក្រោមដីដែលកើតឡើងពី ឫសកែវនិងឫសរយាង ។ នៅផ្នែកខាងចុងនៃឫសនីមួយៗ មានសរីរាង្គម្យ៉ាងគ្របពីលើដែលគេឱ្យឈ្មោះថា ***ក្បាលឫស*** ។ វាមាននាទីការពារចុងឫសក្នុងការដុះលូតលាស់ ។ នៅផ្នែកខាងលើនេះបន្តិចមានរោមឆ្មារៗជាច្រើនដុះយ៉ាងក្រាស់គឺ ***រោមជញ្ជក់*** ។

## ខ. នាទីរបស់ឫស

ឫសមាននាទីសំខាន់ៗដូចតទៅ ៖

- នាទីទ្រទ្រង់ ៖ ភ្ជាប់ដើមទៅនឹងដី
- នាទីស្រូប ៖ ស្រូបទឹកនិងអំបិលរ៉ែនិជរលាយពីក្នុងដី
- នាទីដឹកនាំ ៖ ដឹកនាំទឹកនិងអំបិលរ៉ែនិជទៅដើម
- នាទីផ្ទុកអាហារបម្រុង ៖ ផ្ទុកអាហារចិញ្ចឹម ។

## គ. ប្រភេទនៃឫស

ឫសចែកជាពីរប្រភេទគឺ ***ឫសស្ទឹង*** និង ***ឫសស្ញែ*** ។

- ***ឫសស្ទឹង*** មានឫសកែវនិងឫសរយាង ។ ភាគច្រើនមាននៅលើរុក្ខជាតិឌីកូទីលេដូន ។
***ឧទាហរណ៍*** ដើមសណ្តែក ។
- ***ឫសស្ញែ*** ជាឫសគ្មានឫសកែវ ហើយភាគច្រើនឫសស្ញែមាននៅលើរុក្ខជាតិម៉ូណូកូទីលេដូន ហើយឫសលូតលាស់ស្មើគ្នាទាំងអស់ ។ ***ឧទាហរណ៍*** ស្មៅ ។




*រូបទី 2.1. ប្រភេទឫស*

## 1.2. ប្រភេទដើម

យើងចែកដើមរុក្ខជាតិជាបីបែបគឺ

## ក. ដើមលើដី

- ដងដើម ៖ លំអដោយមែកសាខាដូចជា ដើមពោធិ៍ ។
- ដើមទោល ៖ រឹង ខ្ពស់ គ្មានមែក មានតែស្លឹកមួយកញ្ចុំនៅខាងចុង ដូចជាដើមដូង ស្លា ។
- ដើមបំពង់ ៖ ដើមនេះប្រហោងក្នុងនៅផ្នែកចន្លោះថ្នាំង ឯថ្នាំងវិញណែនហើយគាត់ ។
***ឧទាហរណ៍*** ដើមស្រូវ ពោត ស្មៅ ឫស្សី... ។

- **ដើមវារ** មានឫសព្រយោងដុះនៅតាមថ្នាំងនិងពន្លកមែក ហើយអាចឱ្យកំណើតជារុក្ខជាតិថ្មី ដែលអាចរស់ដោយខ្លួនឯង កាលណាវាដាច់ចេញពីរុក្ខជាតិមេ ។ ***ឧទាហរណ៍*** ដើមឪឡឹក ដំឡូងជ្វា ត្រចៀកក្រាញ់ ... ។
- **ដើមតោង** វារតោងលើជន្លង់ តោងទៅនឹងជញ្ជាំង ឬដើមឈើផ្សេងទៀតដោយឫសព្រយោងរបស់វា ។ ដើមខ្លះថ្កក់ទៅនឹងរុក្ខជាតិជិតខាងដោយបន្លា **ឧទាហរណ៍** ដើមបន្លា ។ ដើមខ្លះទៀតភ្ជាប់ដោយដៃ ។ ***ឧទាហរណ៍*** ម្រះ ល្ពៅ ននោង ។ ខ្លះទៀតវារវ័ណ្ឌព័ទ្ធជុំវិញជន្លង់ ***ឧទាហរណ៍*** វល្លិ៍ជន្លង់ ។


ដើមជ្រៃ (ដងដើម)


ដើមត្នោត(ដើមទោល)


ដើមស្រូវ(ដើមបំពង់)


ដើមត្រចៀកក្រាញ់ (ដើមវារ)


ដើមននោង(ដើមតោង)

***រូបទី2.2. ប្រភេទដើម***

## ខ. ដើមក្នុងដី

ដើមដែលលូតលាស់នៅក្នុងដីមានច្រើនយ៉ាង ។

- **មើម** ជាដើមនៅក្នុងដី ដែលមានផ្ទុកសារធាតុបម្រុង ***ឧទាហរណ៍*** ដំឡូងបារាំង ។
- **មើមស្រកាស្លឹក** ជាប្រភេទដើមក្នុងដីដែលផ្សំឡើងដោយពន្លក មើម និងស្រកាស្លឹកយ៉ាងច្រើនព្រមជាមួយឫសស្ញែនៅពីក្រោម ។ ***ឧទាហរណ៍*** ខ្ទឹមបារាំង ។
- **មើមក្បៀង** ជាដើមក្នុងដីដែលមានថ្នាំង ចន្លោះថ្នាំងក្នុងស្រកាស្លឹក ហើយថ្នាំងនិងពន្លកមានឫសស្ញែតូចៗដុះពីក្រោមដី ។ ***ឧទាហរណ៍*** ខ្ញី ។



ដំឡូងបារាំង( មើម)　　វិមបារាំង( មើមស្រកាស្លឹក)　　រិទ្ធិ( ខ្ញី)

*រូបទី2.3. ប្រភេទដើមក្នុងដី*

## គ. ដើមក្នុងទឹក

ដើមដុះកប់ក្នុងភក់ដែលមានទឹកលិច ។ ដើមប្រភេទនេះច្រើនក្រាស់ហើយទន់ មានរន្ធខ្យល់ ។ ***ឧទាហរណ៍*** ក្ដៀងឈូក ។

- ដើមមានមុខងារទ្រទ្រង់មែក ស្លឹក និងផ្ការបស់រុក្ខជាតិទាំងមូល ។ វាដឹកនាំទឹកនិងអំបិលខនិជរលាយទៅស្លឹក និងដឹកនាំអាហារដែលផលិតចេញពីស្លឹកទៅសរីរាង្គផ្សេងៗនៃរុក្ខជាតិ ។

## 1.3. ស្លឹក

ស្លឹកដុះជាប់និងថ្នាំងដែលមានទងស្លឹកនិងតួស្លឹក ។ នៅលើតួស្លឹកនោះមាន ***ទ្រនុងកណ្ដាលធំ*** និង ***ទ្រនុងតូច*** ។ នៅចន្លោះគល់ស្លឹក ខ្លះមាន***ពន្លកមែក*** ដែលនឹងលូតលាស់ទៅជាមែក ឬគល់ស្លឹកខ្លះទៀតមាន***ពន្លកផ្កា*** ដែលនឹងលូតលាស់ទៅជាផ្កា ។ វាក៏អាចមានពន្លកនៅផ្នែកខាងចុងនៃដើម និងមែកដែរ ។ ស្លឹកមាននាទីផលិតអាហារ ហើយត្រូវគេចាត់ទុកថាជាសរីរាង្គលូតលាស់ធំបំផុត ។




*ទម្រង់ស្លឹកមួយល្អូនទីលេមួន*　　*ទម្រង់ស្លឹកពីរល្អូនទីលេមួន*

*រូបទី2.4. ទ្រនុងស្លឹក*

## ក. ប្រភេទស្លឹក

គេចែកស្លឹកជាពីរប្រភេទគឺ ស្លឹកទោលនិងស្លឹករួម ។

- ស្លឹកទោល : តួស្លឹកមានបន្ទះតែមួយ ហើយក្នុងចំណោមស្លឹកទោលគេចែកជា :

- ស្លឹកពេញ គឺស្លឹករាបស្មើ ហើយរលីង ។ ***ឧទាហរណ៍*** ស្លឹកស្វាយ ។

- **ស្លឹកនែក** គឺតួស្លឹកមាននែក ។ ***ឧទាហរណ៍*** ស្លឹកនែកមានស្លឹកល្ហុងនិងស្លឹកនែកពីរមានស្លឹកជើងគោ ។
- **ស្លឹកធ្មេញ** គឺតួស្លឹកមានធ្មេញ ដូចធ្មេញរណារ ។ ***ឧទាហរណ៍*** ស្លឹកតែ ។
- **ស្លឹកគន្លាក់** គឺតួស្លឹកចែកចេញជាពីរគន្លាក់ ។ ***ឧទាហរណ៍*** ស្លឹកក្រូច ។



ស្លឹកពេញ (ស្លឹកតែ) ស្លឹកនែក (ស្លឹកល្ហុង) ស្លឹកនែកពីរ(ស្លឹកជើងគោ) ស្លឹកគន្លាក់ (ស្លឹកក្រូច)

***រូបទី 2.5. ទម្រង់ស្លឹកទោល***

- **ស្លឹករួម** គឺតួស្លឹកមានបន្ទះជាច្រើនដែលមានរាងដូចស្លឹកតូចៗ ហៅថា ***កូនស្លឹក*** ។ គេចែកស្លឹករួមជា ៖
- **ស្លឹកស្និត** ជាស្លឹកដែលកូនស្លឹកស្ថិតនៅសងខាងទ្រនុងកណ្ដាល ។ គេហៅថា ***ស្លឹកស្និតគូ*** កាលណាកូនស្លឹកមានចំនួនគូ ។ ឧទាហរណ៍ ស្លឹកក្ទោក ។ ***ស្លឹកស្និតសេស*** កាលណាកូនស្លឹកមួយស្ថិតនៅចុងទ្រនុងកណ្ដាល ។ ឧទាហរណ៍ ស្លឹកកុលាប ។
- **ស្លឹកកង្ការ** ជាស្លឹកដែលកូនស្លឹកភ្ជាប់នឹងចុងទងស្លឹកនៅកន្លែងតែមួយ ។ ឧទាហរណ៍ ស្លឹកគ ។



ស្លឹកស្និតគូ (ស្លឹកអំពិលបារាំង) ស្លឹកកង្ការ(ស្លឹកគ) ស្លឹកស្និតសេស(ស្លឹកផ្កាកុលាប)

***រូបទី 2.6. ទម្រង់ស្លឹករួម***

## ខ. ការតម្រៀបស្លឹកលើដើម



ស្លឹកឆ្លាស់ (ស្លឹកទៀប) ស្លឹកឈម(ស្លឹកត្របែក) ស្លឹកកញ្ចុំ (ស្លឹកឃិតចៅ)

***រូបទី 2.7. ការតម្រៀបស្លឹកលើដើម***

- កាលណាក្នុងថ្នាំងមួយមានស្លឹកតែមួយគេហៅថា ***ស្លឹកឆ្លាស់*** ។ ***ឧទាហរណ៍*** ស្លឹកទៀប ។
- កាលណាក្នុងថ្នាំងមួយមានស្លឹកពីរទល់មុខគ្នាហៅថា ***ស្លឹកឈម*** ។ ***ឧទាហរណ៍*** ស្លឹកត្របែក ។
- កាលណាក្នុងថ្នាំងមួយមានស្លឹកចាប់ពីបីឡើងទៅហៅថា ***ស្លឹកកញ្ចុំ*** ។ ***ឧទាហរណ៍*** ស្លឹកយិតថោ ។
- ការតម្រៀបស្លឹកលើដើមរបស់រុក្ខជាតិខ្លះ មិនអាចរាប់បញ្ចូលក្នុងការតម្រៀបលើដើមដែលបានរៀបរាប់ខាងលើនេះបានទេ ។
- ស្លឹកស្រល់ : គេហៅថាស្លឹកម្ជុល មានរាងវែងស្រួច មានតែទ្រនុងកណ្ដាលប៉ុណ្ណោះ ។
- ស្លឹកដើមដំបងយក្ស : គេហៅថាស្លឹកបន្លា ។
- ស្លឹករុក្ខជាតិឡើងទ្រើង ដូចជាននោង ត្រឡាច : គេហៅថាស្លឹកដៃ ។ ស្លឹកទាំងអស់នេះហៅថាស្លឹកប្រែប្រួល ។
- ស្លឹករុក្ខជាតិចាប់សត្វល្អិតជាអាហារ ដូចជាណេបង់តែស ដ្រូសេរ៉ា ។
- រុក្ខជាតិខ្លះមិនដូចគ្នាទេ ជាពហុសណ្ឋានស្លឹក ។ ***ឧទាហរណ៍*** ស្លឹកល្ហុងប្រេង ព្រលិត ។




***រូបទី 2.8. ទម្រង់ស្លឹកផ្សេងៗ***

## 2. ប្រដាប់បន្តពូជ

### 2.1. ផ្កា

ផ្កាជាសរីរាង្គបន្តពូជពិសេសបំផុត ។ ផ្កានីមួយៗមាន 4 ផ្នែកដែលតម្រៀបលើរង្វង់បួនផ្សេងៗគ្នានៅលើទងមួយមានប្រវែងខ្លី ឬវែង ។

- កញ្ចុំត្របកមានពណ៌បៃតងដែលស្ថិតនៅរង្វង់ក្រៅក្រោមបង្អស់ ឬរង្វង់ទី 1 ។ ផ្នែកនីមួយៗរបស់វាមានឈ្មោះថា ***ត្របកផ្កា*** ។
- កញ្ចុំស្រទាប់ មានពណ៌ឆើតដែលអាចទាក់ទាញសត្វល្អិតបាន ហើយស្ថិតនៅរង្វង់បន្ទាប់ ឬរង្វង់ទី 2 ។ ផ្នែកនីមួយៗរបស់វាមានឈ្មោះថា ***ស្រទាប់ផ្កា*** ។

- កញ្ចុំកេសរឈ្មោល ស្ថិតនៅវង់ទី3 ។ ផ្នែកនីមួយៗឈ្មោះថា ***កេសរឈ្មោល***។ កេសរឈ្មោល នីមួយៗមានថ្នោកលំអងដែលក្នុងនោះមានគ្រាប់លំអងជាច្រើន ។
- កញ្ចុំកេសរញីស្ថិតនៅវង់លើគេបង្អស់ ឬវង់ទី4 ។ ផ្នែកនីមួយៗរបស់វាឈ្មោះថា ***កេសរញី***។ កេសរញីនីមួយៗមានថតមួយនៅផ្នែកខាងក្រោមដែលមានឈ្មោះថា***អូវែ*** ហើយក្នុងនោះមាន ***អូវុល*** ។ ឯផ្នែកខាងចុងនៃកេសរញីមាន **ស្ទិចម៉ាត** ។




***រូបទី 2.9. ទម្រង់ប្រដាប់បន្តពូជ***

## 2.2. ផ្លែ គ្រាប់ និងអំប្រីយ៉ុង

បន្ទាប់ពីគ្រាប់លំអងធ្លាក់ទៅលើស្ទិចម៉ាតដោយសារខ្យល់ ឬសត្វល្អិត អូវែក៏ក្លាយទៅជា ***ផ្លែ*** ហើយ ***អូវុល*** ក៏ក្លាយទៅជា ***គ្រាប់***។ បន្ទាប់ពីដំណុះនៃគ្រាប់ អំប្រីយ៉ុងដែលនៅខាងក្នុង គ្រាប់ ក៏ដុះលូតលាស់ទៅជា ***កូនរុក្ខជាតិ***។




***រូបទី 2.10. កំណើតកូនរុក្ខជាតិ***

## មេរៀនសង្ខេប

- រុក្ខជាតិមានផ្កាបន្តពូជដោយគ្រាប់ ។
- ឫស ដើម មែក និងស្លឹកជាប្រដាប់លូតលាស់ រីឯផ្កាជាប្រដាប់បន្តពូជរបស់រុក្ខជាតិមានផ្កា ។
- ប្រព័ន្ធឫស មានឫសកែវ ឫសរយាង និងរោមជញ្ជក់ ។ ប្រភេទនៃឫសផ្សេងៗទៀតមាន ឫសស្ពឹង ឫសស្វៃ និងឫសព្រយោង ។
- នៅតាមបណ្តោយដើមមានថ្នាំង ចន្លោះថ្នាំង និងពន្លក ។
- ដើមរុក្ខជាតិមានបីបែប: ដើមលើដី ដើមក្នុងដី និងដើមក្នុងទឹក ។
- ស្លឹកដុះជាប់នឹងថ្នាំង ។ ស្លឹកមានទងស្លឹក តួស្លឹក និងនៅលើតួស្លឹកមានទ្រនុងកណ្តាលធំ និងទ្រនុងតូច ។
- ស្លឹកមានពីរប្រភេទ : ស្លឹកទោល និងស្លឹករួម ។
- ក្នុងថ្នាំងមួយមានស្លឹកតែមួយ គឺស្លឹកឆ្លាស់ ។ បើមានស្លឹកពីរគឺស្លឹកឈម និងបើស្លឹកលើសពីបីទៅគឺស្លឹកកញ្ចុំ ។
- ផ្កាជាប្រដាប់បន្តពូជរបស់រុក្ខជាតិមានផ្កា ។ ផ្កានីមួយៗមានត្របក ស្រទាប់ កេសរឈ្មោល និងកេសរញី ។ នៅក្នុងកេសរឈ្មោលមានថ្នោកលំអងដែលក្នុងនោះមានគ្រាប់លំអងជាច្រើន ។ ឯកេសរញីនីមួយៗមានអូវែ ដែលក្នុងនោះមានអូវុល និងផ្នែកខាងចុងមានស្ទិចម៉ាត ។

## ? សំណួរ

1. តើរុក្ខជាតិមានផ្កាបន្តពូជដោយសារអ្វី ?
2. តើឫសមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូរឱ្យឧទាហរណ៍បញ្ជាក់ ។
3. តើនៅតាមបណ្តោយដើមនៃរុក្ខជាតិមានផ្កា គេឃើញមានសរីរាង្គអ្វីខ្លះ ?
4. គេចែករុក្ខជាតិមានផ្កាជាបីបែប ដោយសារមូលហេតុអ្វី ?
5. តើដងដើមរបស់រុក្ខជាតិមាននាទីអ្វីខ្លះ ?
6. តើនៅលើតួស្លឹកមានអ្វីខ្លះ ?
7. តើគេចែកស្លឹកជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូរឱ្យឧទាហរណ៍បញ្ជាក់ពីប្រភេទស្លឹកនីមួយៗ ។
8. ចូរពណ៌នាពីការតំរៀបស្លឹកលើដើម ព្រមទាំងឱ្យឧទាហរណ៍ ។
9. តើផ្កាមានប៉ុន្មានផ្នែក ? អ្វីខ្លះ ?
10. ចូរពណ៌នាពីកំណកូនរុក្ខជាតិមានផ្កា ។

មេរៀនទី

# 3 ដំណឹកនាំក្នុងរុក្ខជាតិមានផ្កា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីតម្រូវការប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កា
- ❑ ប្រាប់ឈ្មោះពីប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កានិងនាទីរបស់វា
- ❑ ធ្វើពិសោធន៍ដើម្បីពិនិត្យពីសម្រូបទឹករបស់រុក្ខជាតិមានផ្កា
- ❑ យល់ពីផលប្រយោជន៍របស់ប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កា ។

ក្នុងជីវិតរស់នៅ ភាវៈរស់ទាំងអស់ត្រូវការប្រព័ន្ធដំណឹកនាំ ដើម្បីដឹកនាំសារធាតុចិញ្ចឹមទៅកាន់កោសិកានិងនាំកាកសំណល់ផ្សេងៗចេញពីកោសិកាមកវិញ ។ ចំណែករុក្ខជាតិមានផ្កាក៏ត្រូវការ ប្រព័ន្ធដំណឹកនាំដែរ ដើម្បីមានជីវិតរស់នៅដូចជាភាវៈរស់ផ្សេងៗទៀតដែរ ។

## 1. តម្រូវការប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កា

- ចំពោះរុក្ខជាតិថ្នាក់ទាប ដូចជាសារាយ កោសិការបស់វាមានទំនាក់ទំនងផ្ទាល់ជាមួយមជ្ឈដ្ឋានជុំវិញ ។ សារធាតុផ្សេងៗដូចជាអុកស៊ីសែននិងកាកសំណល់ផ្សេងៗអាចនាំចេញនិងចូលក្នុងសារពាង្គកាយរបស់វា ***តាមបន្សាយ*** ។



*រូបទី 3.1. សារពាង្គកាយតូច (សារាយ)*

- ចំពោះរុក្ខជាតិថ្នាក់ខ្ពស់ដូចជារុក្ខជាតិមានផ្កា កោសិការបស់វាស្ថិតនៅជ្រៅនិងឆ្ងាយពីផ្ទៃខាងលើនៃសារពាង្គកាយ ។ ដូចនេះសារធាតុផ្សេងៗដូចជា អុកស៊ីសែនមិនអាចជ្រាបទៅដល់កោសិកាទាំងនោះតាមបន្សាយបានទេ ។ សារពាង្គកាយរបស់វាត្រូវមានប្រព័ន្ធដំណឹកនាំសារធាតុទាំងនោះ ព្រោះបន្សាយជាលំនាំយឺតៗដែលមិនអាចនាំសារធាតុផ្សេងៗឆ្លងកាត់ទីឆ្ងាយបានឡើយ ។



*រូបទី 3.2. សារពាង្គកាយធំ (ដើមប៉េងប៉ោះ)*

## 1.1. បន្សាយ

### ក. និយមន័យ

បន្សាយគឺជាចលនារបស់ម៉ូលេគុលនៃសារធាតុមួយពីតំបន់ដែលមានកំហាប់សូលុយស្យុងខ្ពស់ទៅតំបន់ដែលមានកំហាប់សូលុយស្យុងទាប ។

***ឧទាហរណ៍*** : បើយើងបន្តក់ទឹកថ្នាំក្រហមទៅក្នុងកែវទឹកមួយ បន្តិចក្រោយមកយើងសង្កេតឃើញទឹកក្នុងកែវប្ដូរពណ៌ជាពណ៌ក្រហមទាំងអស់ ។ ម៉ូលេគុលទឹកថ្នាំក្រហមបានសាយទៅក្នុងទឹក ។

### ខ. បន្សាយតាមរយៈភ្នាស

#### ការសាកល្បង





ទុកពិសោធន៍នៅស្ងៀមមួយរយៈពេល

បន្តិចក្រោយមកទឹកក្នុងកែវប្ដូរទៅជាមានពណ៌

ទឹកបានសាយពីកែវទៅក្នុងថង់កំណាត់ ។ គ្រាប់ពែម៉ង់ភាណាតក្នុងថង់កំណាត់រលាយក្នុងទឹកបង្កើតបានជាសូលុយស្យុង ។ បន្ទាប់មកសូលុយស្យុងនេះក៏សាយចេញពីថង់កំណាត់ទៅក្នុងកែវវិញ ។

ដូចនេះ បន្សាយក៏អាចឆ្លងកាត់ភ្នាសបានដែរ ។ ថង់កំណាត់មាននាទីដូចជាភ្នាសមួយ ។ ភ្នាសនេះហៅថា ***ភ្នាសជ្រាប*** ។ វាមានរន្ធតូចៗជាច្រើនដែលឱ្យម៉ូលេគុលតូចៗសាយចេញតាមនោះ ។

តាមលំនាំជីវៈ ភាគច្រើននៃបន្សាយរបស់សារធាតុផ្សេងៗកើតឡើងតាមរយៈ ***ភ្នាសអន្លជ្រាប*** ។ ភ្នាសអន្លជ្រាបអាចឱ្យឆ្លងកាត់តែសារធាតុខ្លះៗប៉ុណ្ណោះ ។ ***ឧទាហរណ៍*** ភ្នាសកោសិកា ។

## 1.2. អូស្មូស

អូស្មូសគឺជាបន្សាយនៃម៉ូលេគុលឆ្លងកាត់ភ្នាសអន្លជ្រាប ។

## ការសាកល្បង

- កាត់ការ៉ុត 2 ឬ 3 ដុំ ហើយដាក់វាក្នុងចានទឹកមួយ ។
- មួយម៉ោងក្រោយមក យើងពិនិត្យឃើញដុំការ៉ុតនោះបានជក់ទឹក រីកប៉ោងហើយរឹង ។ ការប្រែប្រួលនេះបណ្តាលមកពីដំណើរអូស្មូស ។ កំហាប់ទឹកនៅក្នុងចានខ្ពស់ជាងកំហាប់ទឹកខាងក្នុងកោសិកាការ៉ុត ។ ម៉ូលេគុលទឹកក្នុងចានសាយចូលទៅក្នុងកោសិកាការ៉ុតដោយឆ្លងកាត់ភ្នាសអឌ្ឍជ្រាបនៃកោសិកា ។



ដូចនេះ អូស្មូសគឺជាចលនានៃម៉ូលេគុលទឹកពីតំបន់ដែលមានកំហាប់សូលុយស្យុងទាបទៅតំបន់ដែលមានកំហាប់សូលុយស្យុងខ្ពស់តាមរយៈភ្នាសអឌ្ឍជ្រាប ។

## 2. ប្រព័ន្ធដឹកនាំរុក្ខជាតិ

ប្រព័ន្ធដឹកនាំរបស់រុក្ខជាតិមានផ្កាជាបំពង់តូចៗជាច្រើននៅក្នុងឫស ដើម និងស្លឹក ។ បំពង់នេះមានពីរបែបគឺ ***ស៊ីឡែម*** និង ***ផ្លូអែម*** ។ បំពង់ទាំងពីរបែបនេះមានមុខងារ ៖




*រូបទី3.3. ប្រព័ន្ធដឹកនាំរបស់រុក្ខជាតិមានផ្កា*

- ***ស៊ីឡែម*** ដឹកនាំទឹកនិងអំបិលខនិជរលាយផ្សេងៗ( ***រុក្ខរសឆៅ*** ) ពីឫសទៅកាន់ស្លឹករុក្ខជាតិ ។
- ***ផ្លូអែម*** ដឹកនាំចំណីអាហាររលាយក្រោមរូបរាងជាស្ករ( ***រុក្ខរសសម្រាំង*** )ពីស្លឹកទៅគ្រប់ផ្នែកទាំងអស់របស់រុក្ខជាតិ ដើម្បីចិញ្ចឹមផ្នែកទាំងនោះ ។

# 3. ផ្លូវដំណើរនាំទឹកនិងអំបិលខនិជ




*1 ចូល* : ទឹកចូលទៅក្នុងឫសដោយអូស្មូស ។ អំបិលខនិជត្រូវបានស្រូបតាមឫស ។

*2. ឡើង* : ទឹក និងអំបិលខនិជឡើងតាមដើមដោយកម្លាំងស្រូប ។

3. ***ទឹក*** និង***អំបិលខនិជ***ត្រូវបានប្រើប្រាស់ក្នុងរស្មីសំយោគ ។

*4 ចេញ* : ទឹកភាគច្រើនភាយចេញតាមស្លឹកតាមលំនាំរំភាយចំហាយទឹក ។

***រូបទី3.3. ផ្លូវដឹកនាំទឹក និងអំបិលខនិជឬដំណើររុក្ខរសដើម***

## មេរៀនសង្ខេប

- រុក្ខជាតិមានផ្កាត្រូវការដំណឹកនាំ ដើម្បីមានជីវិតរស់នៅដូចជាភាវៈរស់ផ្សេងៗទៀតដែរ ។
- ប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កាគឺជាបំពង់ ស៊ីឡែមនិងផ្លូអែម ។
- ស៊ីឡែមដឹកនាំទឹកនិងអំបិលខនិជរលាយ(រុក្ខរសដើម) ពីឫសទៅស្លឹកនៃរុក្ខជាតិ ។
- ផ្លូអែមដឹកនាំអាហាររលាយក្រោមរូបរាងជាស្ករ (រុក្ខរសសម្រាំង) ពីស្លឹកទៅកាន់ផ្នែកផ្សេងៗនៃរុក្ខជាតិ ។
- ទឹកចូលទៅក្នុងឫសដោយអូស្មូស ។ អំបិលខនិជត្រូវបានស្រូបតាមឫស ។
- ទឹក និងអំបិលខនិជឡើងតាមដើមដោយកម្លាំងស្រូបតាមស៊ីឡែមរហូតដល់ស្លឹក ។
- ទឹកភាគច្រើនភាយចេញពីរន្ធតូចៗរបស់ស្លឹក ។

## ? សំណួរ

1. តើប្រព័ន្ធដំណឹកនាំរបស់រុក្ខជាតិមានផ្កា មាននៅផ្នែកណាខ្លះនៃរុក្ខជាតិ ?
2. តើបំពង់ដឹកនាំពីរប្រភេទរបស់រុក្ខជាតិមានផ្កាមានឈ្មោះអ្វីនិងមាននាទីអ្វីខ្លះ ?
3. តើទឹកធ្វើដំណើរចូលទៅក្នុងឫសតាមលំនាំអ្វី ?
4. ចូរពណ៌នាសង្ខេបពីដំណឹកនាំទឹកនិងស្ករចំពោះរុក្ខជាតិមានផ្កា ។
5. តើទឹកភាយចេញពីរន្ធតូចៗរបស់ស្លឹកតាមលំនាំអ្វី ?

## ? សំណួរនិងលំហាត់ជំពូក 2

**I. ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. ទឹកចូលទៅក្នុងរោមជញ្ជក់តាមដំណើរ

☐ ក. បន្សាយ ☐ ខ. អូស្មូស ☐ គ. រំភាយចំហាយទឹក ☐ ឃ. សម្រូប ។

2. ទឹកផ្លាស់ទីពីកោសិកាមួយទៅកោសិកាមួយក្នុងរោមជញ្ជក់តាមដំណើរ

☐ ក. បន្សាយ ☐ ខ. អូស្មូស ☐ គ. រំភាយចំហាយទឹក ☐ ឃ. សម្រូប ។

**II. ចូរបំពេញឃ្លាខាងក្រោមនេះឱ្យបានត្រឹមត្រូវ**

1. សរីរាង្គលូតលាស់របស់បំប្រកជា. . . . . . . . . . . . . . . ។
2. ស្លឹកបន្ទះពណ៌បៃតងមានរាងដូចជាបេះដូងហៅថា. . . . . . . . . . . . . . . ។
3. កោសិកាបន្តពូជញីដែលនៅក្នុងអាកេកូនហៅថា. . . . . . . . . . . . . . ។
4. កោសិកាបន្តពូជឈ្មោលដែលនៅក្នុងអង់តេរីឌីហៅថា. . . . . . . . . . . . . ។

**III. សំណួរ**

1. ចូររាប់ឈ្មោះពីរុក្ខជាតិឥតផ្កាឱ្យបានចំនួនបី ។
2. តើយើងធ្វើការងារពិសោធន៍អ្វី ដើម្បីបង្ហាញឱ្យដឹងថារុក្ខជាតិត្រូវការទឹក ?
3. តើហេតុអ្វីបានជាគេត្រូវប្រមូលផលដំណាំដែលមានឫសជាមើម (ឧទាហរណ៍ : ដំឡូងមី) ឱ្យបានមុនពេលវាចេញផ្កា ?

**IV. លំហាត់**

ចូររកពាក្យ ឬកន្សោមពាក្យឱ្យបានសមស្រប ដើម្បីបំពេញក្នុងលំហាត់ខាងក្រោមនេះ :

ខ្ញុំបានដាំននោងក្នុងសួនដំណាំគ្រួសាររបស់ខ្ញុំ ។ ខ្ញុំថែទាំ ស្រោចទឹក បោចស្មៅ ពូនគល់ ដាក់ជីធម្មជាតិជារឿយៗ ។ វាក៏ដុះលូតលាស់ធំធាត់ឆាប់ ។ នៅពេលពិនិត្យមើលដើមននោងនេះ ដងដើមរបស់វាមាន . . . . ។ មែកដែលពោរពេញទៅដោយស្លឹកធំៗបានលូតលាស់ចេញពី . . . . និងកញ្ចុំផ្កាននោងមានពណ៌លឿងបានលូតលាស់ចេញពី . . . . ។ មិនទាន់បានពេញពីរខែ ដើមននោងរបស់ខ្ញុំបានលូតលាស់ពេញទ្រើងបានជាម្លប់យ៉ាងត្រជាក់នៅទីធ្លាផ្ទះរបស់ខ្ញុំ ។ វាបានផ្ដល់ឱ្យខ្ញុំនូវ . . . . យ៉ាងឆ្ងាញ់ពិសា ។ ខ្ញុំបានប្រាប់មិត្តខ្ញុំថា ដើមននោងជាប្រភេទរុក្ខជាតិ . . . . ។ វាតោងដោយ . . . . ខុសពីដើមជន្លង់ដែលមានក្នុងសួននេះ វាក៏ជាប្រភេទ . . . . ដែរ ប៉ុន្តែវាតោងដោយ . . . . . ។

## ជំពូក 3

# កោសិកា



រូបភាពខាងលើនេះ បង្ហាញថាកោសិកាជាឯកតាបង្ករបស់សារពាង្គកាយ មានន័យថាកោសិកាផ្សេងៗបំពេញនាទីផ្សេងៗគ្នា ។ កោសិកាប្រភេទដូចគ្នាផ្គុំគ្នាបានជាជាលិកា ។ ជាលិកាប្រភេទផ្សេងៗផ្គុំគ្នាបានជាសរីរាង្គ ។ សរីរាង្គផ្សេងៗផ្គុំគ្នាបានជាប្រព័ន្ធសរីរាង្គ ឬប្រដាប់ ។ ប្រព័ន្ធសរីរាង្គ ឬប្រដាប់ធ្វើការជាមួយគ្នា ដើម្បីបំពេញនាទីរួមមួយបង្កើតបានជាសារពាង្គកាយមួយ ។

មេរៀនទី

# 1 រូបធាតុកោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីរូបធាតុរបស់កោសិកា
- ❑ ពណ៌នាពីលំនាំបន្តពូជរបស់កោសិកា
- ❑ ប្រើប្រាស់កែវពង្រីក និងមីក្រូទស្សន៍ ។

សារពាង្គកាយភាវៈរស់ទាំងអស់សុទ្ធតែបង្កឡើងដោយ ***កោសិកា*** ដូចនេះកោសិកាជាឯកតាគ្រឹះបង្ករបស់ភាវៈរស់ ។

សារពាង្គកាយដែលបង្កឡើងដោយកោសិកាតែមួយហៅថា ***សារពាង្គកាយឯកកោសិកា***។ ចំពោះសារពាង្គកាយដែលបង្កឡើងដោយកោសិកាច្រើនហៅថា ***សារពាង្គកាយពហុកោសិកា***។




*រូបទី 1.1 សារពាង្គកាយពហុកោសិកា (ឧទាហរណ៍ : មនុស្ស)*

# 1. រូបផ្គុំកោសិកា

កាលពីជំនាន់ដើម គេអាចមើលឃើញតែរូបផ្គុំខ្លះៗប៉ុណ្ណោះនៅក្នុងកោសិកា ដោយប្រើមីក្រូទស្សន៍អុបទិច ។ ក្រោយមកដោយសារមីក្រូទស្សន៍អេឡិចត្រូនិចដែលជាឧបករណ៍ទំនើប គេអាចមើលឃើញរូបផ្គុំយ៉ាងលំអិតរបស់កោសិកា។

កោសិកាមានច្រើនប្រភេទ ហើយកោសិកាប្រភេទនីមួយៗមានរូបរាងមិនដូចគ្នាទេ ។ នាទីរបស់កោសិកាអាស្រ័យទៅនឹងប្រភេទកោសិកានីមួយៗ ។ ប៉ុន្តែវាមានលក្ខណៈរួមមួយចំនួន ។

## 1.1. ភ្នាសសែលុយឡូស

ភ្នាសសែលុយឡូសជាភ្នាសរឹងមាំ គ្មានជីវិត ដែលរុំព័ទ្ធពីក្រៅភ្នាសកោសិកា ។ ទោះបីភ្នាសសែលុយឡូសរឹងមាំក៏ដោយ ក៏វាអាចឱ្យទឹក អុកស៊ីសែន ឧស្ម័នកាបូនិច និងសារធាតុមួយចំនួនឆ្លងកាត់បានដែរ ។ ចំពោះកោសិការុក្ខជាតិតែងតែមានភ្នាសសែលុយឡូសជានិច្ច ។ ភ្នាសសែលុយឡូសការពារ និងទ្រទ្រង់រុក្ខជាតិឱ្យលូតលាស់ខ្ពស់ឡើង ។

## 1.2. ភ្នាសកោសិកាឬភ្នាសស៊ីតូប្លាស

ភ្នាសកោសិកាជាភ្នាសមួយស្តើង ហើយទន់ដែលរុំព័ទ្ធពីក្រៅកោសិកា ។ ចំពោះកោសិការុក្ខជាតិភ្នាសសែលុយឡូសព័ទ្ធពីក្រៅភ្នាសកោសិកា។ ចំពោះកោសិកាសត្វ ភ្នាសដែលរុំព័ទ្ធពីក្រៅ គឺភ្នាសស៊ីតូប្លាស វាគ្មានភ្នាសសែលុយឡូសទេ ។ ភ្នាសស៊ីតូប្លាសជាភ្នាសជ្រាបជ្រើសដែលអនុញ្ញាតឱ្យចូលបានតែសារធាតុមួយចំនួនប៉ុណ្ណោះ ។

## 1.3. ស៊ីតូប្លាស

ស៊ីតូប្លាសជាសារធាតុខាប់អន្ទិល ដែលស្ថិតនៅចន្លោះណ្វៃយ៉ូនិងភ្នាសស៊ីតូប្លាស ហើយមានចលនាជានិច្ច ។

## 1.4. វ៉ាគុយអូល

វ៉ាគុយអូលជាថង់មួយពេញដោយទឹក ខ្យល់ និងចុណ្ណភាគនៃអាហារ ។ វ៉ាគុយអូលអណ្តែតក្នុងស៊ីតូប្លាស ។ កោសិការុក្ខជាតិភាគច្រើននិងកោសិកាសត្វមួយចំនួនមានវ៉ាគុយអូល ។ កោសិការុក្ខជាតិច្រើនមានវ៉ាគុយអូលធំៗ ។ ចំណែកឯកោសិកាសត្វច្រើនមានវ៉ាគុយអូលតូចៗ ។ វ៉ាគុយអូលគឺជាកន្លែងសម្រាប់ស្តុកភាគសំណល់ដែរ ។ កាលណាវ៉ាគុយអូលរបស់កោសិការុក្ខជាតិពេញដោយទឹក វារឹកប៉ោង ហើយធ្វើឱ្យរុក្ខជាតិរឹងមាំ ។

## 1.5. ណ្វៃយ៉ូ

ណ្វៃយ៉ូត្រួតពិនិត្យរាល់សកម្មភាពរបស់កោសិកា ។ ណ្វៃយ៉ូផ្ទុកក្រូម៉ូសូមដែលមានរាងជាសរសៃស្មារៗនៅពាសពេញ ។




*រូបទី 1.2. រូបថ្មីកោសិកា*

## 2. ការបន្តពូជរបស់កោសិកា

មនុស្សពេញវ័យមានចំនួនកោសិកាប្រហែល រាប់កោដិកោសិកា ហើយកោសិកាទាំងរាប់កោដិនេះកើតចេញពីកោសិកាដើមតែមួយ ។

សារពាង្គកាយធំធាត់ដោយសារចំនួនកោសិកាកើនឡើង ។ កំណើនចំនួនកោសិកាបណ្តាលមកពីកោសិកាធ្វើចំណែក ។ កោសិកាមេមួយបន្តពូជដោយចែកខ្លួនជាកោសិកាកូនពីរ ។ កោសិកាកូនទាំងពីរមានលក្ខណៈដូចគ្នាបេះបិទនិងដូចកោសិកាមេ ។ ការចែកបែបនេះ ហៅថា ***ចំណែកកោសិកាលូតលាស់*** ។




*រូបទី 1.3. លំនាំនៃការបន្តពូជរបស់កោសិកា ឬចំណែកកោសិកាលូតលាស់*

ការបន្តពូជរបស់កោសិកាធ្វើឱ្យសារពាង្គកាយលូតលាស់ធំធាត់បានយ៉ាងឆាប់រហ័ស ជាពិសេសនៅក្នុងដំណាក់កាលលូតលាស់របស់សារពាង្គកាយ ។ រីឯសារពាង្គកាយពេញវ័យវិញ លំនាំនៃការបន្តពូជរបស់កោសិកានៅតែប្រព្រឹត្តជាបន្ត ប៉ុន្តែមានលក្ខណៈយឺតជាង ។ ជារៀងរាល់ថ្ងៃ កោសិកាជាច្រើនត្រូវងាប់ ហើយត្រូវបានជំនួសទៅវិញដោយកោសិកាទើបនិងកើតថ្មីៗ ។

# 3. កែវពង្រីកនិងមីក្រូទស្សន៍

ដើម្បីពិនិត្យវត្ថុតូចដែលមើលមិនឃើញដោយភ្នែកទទេ យើងត្រូវប្រើកែវពង្រីកឬមីក្រូទស្សន៍ ។

## 3.1. កែវពង្រីក

កែវពង្រីកដែលងាយប្រើប្រាស់ជាងគេ គឺកែវពង្រីកមានដង ។ កែវពង្រីកនេះមានដងមួយសម្រាប់កាន់ ដែលធ្វើអំពីលោហៈ (ឬជ័រ) ដោយភ្ជាប់ជាមួយកញ្ចក់មូលមួយ ថ្លា ក្រាស់ហើយផ្ទៃកញ្ចក់ទាំងសងខាងជាផ្ទៃលយនិងរុំព័ទ្ធទៅដោយខ្សែលោហៈ (ឬខ្សែជ័រ) ។ កែវពង្រីកមានអនុភាពពង្រីកពី 3 – 20 ដង ។



*រូបទី 1.4. កែវពង្រីក*

របៀបប្រើ

- ដៃឆ្វេងកាន់ដងរបស់វា ។
- ដាក់ផ្ទៃកញ្ចក់ពីលើ ហើយឱ្យជិតវត្ថុដែលចង់ពិនិត្យ ។
- ភ្នែកសម្លឹងទៅលើផ្ទៃកញ្ចក់នោះ ។
- រំកិលកែវពង្រីកបន្តិចម្តងៗរហូតដល់ពិនិត្យឃើញវត្ថុនោះច្បាស់ ។

## 3.2. មីក្រូទស្សន៍



*រូបទី 1.5. មីក្រូទស្សន៍អុបទិច*

មីក្រូទស្សន៍អុបទិចមានច្រើនប្រភេទណាស់និងមានអានុភាពពង្រីករូបពី 40 – 3 000 ដង ។ ចំណែកមីក្រូទស្សន៍អេឡិចត្រូនិចមានអនុភាពពង្រីករូបពី 10 000 - 40 000 ដង ។

## ពិសោធន៍ : សង្កេតរូបធាតុកោសិកាខ្ទឹមបារាំង

## 1. វត្ថុបំណង

សង្កេតកោសិកាដោយប្រើមីក្រូទស្សន៍ ។

## 2. សម្ភារៈ

មីក្រូទស្សន៍អុបទិច បន្ទះកញ្ចក់ស្តើង បន្ទះកញ្ចក់ ដបទឹកមានបំពង់បឺត ម្ជុលលំពែង មើមខ្ទឹមបារាំងស្រស់ ។

## 3. ដំណើរការ




- យកម្ជុលលំពែងមកឆ្កឹះយកស្រទាប់កោសិកាអេពីឌែមមើមខ្ទឹមបារាំង
- ដាក់បំណែកកោសិកាអេពីឌែមលើបន្ទះកញ្ចក់ ហើយបន្តក់ទឹកមួយតំណក់ពីលើវត្ថុពិសោធន៍ បន្ទាប់មកគ្របវាដោយបន្ទះកញ្ចក់ស្តើងពីលើបំណែកដែលមានបន្តក់ទឹករួច
- យករណ្តាប់ពិសោធន៍ដែលរៀបចំរួច ទៅដាក់ពីលើថាសមីក្រូទស្សន៍ ដោយប្រើអុបសិចទីបលេខតូច បន្ទាប់មកបង្វិលយកអុបសិចទីបលេខធំ ដើម្បីមើលឱ្យបានច្បាស់ ។

## 4. សន្និដ្ឋាន

- តើកោសិកាមានរូបរាងយ៉ាងដូចម្តេច ? តើវាមានណ្វៃយ៉ូប៉ុន្មាន ?
- ចូរគូររូបធាតុកោសិកាដែលសង្កេតឃើញក្នុងមីក្រូទស្សន៍និងដាក់ចំណងជើងផ្នែកផ្សេងៗ ។

## មេរៀនសង្ខេប

- កោសិកាជាឯកតាបង្ករបស់ភាវ រស់ ។
- សារពាង្គកាយដែលបង្កឡើងដោយកោសិកាតែមួយហៅថា ***សារពាង្គកាយឯកកោសិកា***។
- សារពាង្គកាយដែលបង្កឡើងដោយកោសិកាច្រើនហៅថា ***សារពាង្គកាយពហុកោសិកា***។
- កោសិកាមានច្រើនប្រភេទ កោសិកាប្រភេទនីមួយៗមានរូបរាងនិងនាទីមិនដូចគ្នាទេ ។ ប៉ុន្តែកោសិកាទាំងអស់មានលក្ខណៈរួមមួយចំនួន : ភ្នាសសែលុយឡូសមានតែចំពោះកោសិការុក្ខជាតិ ភ្នាសស៊ីតូប្លាស វ៉ាគុយអូល និងណ្វៃយ៉ូ ។
- សារពាង្គកាយធំធាត់ដោយសារចំនួនកោសិកា ។ កំណើនចំនួនកោសិកាបណ្ដាលមកពីកោសិកាធ្វើចំណែក ។ កោសិកាមេមួយចែកខ្លួនបានជាកោសិកាកូនពីរ ដែលមានរូបរាងដូចគ្នានិងដូចទៅនឹងកោសិកាមេបេះបិទ ។
- កែវពង្រីកនិងមីក្រូទស្សន៍ប្រើសម្រាប់ពង្រីកវត្ថុតូចល្អិតដែលភ្នែកទទេមិនអាចមើលឃើញឱ្យទៅជាវត្ថុធំ ។

## ? សំណួរ

1. ពន្យល់ពាក្យ : កោសិកា ឯកកោសិកា ពហុកោសិកា និងរកឧទាហរណ៍ ។
2. តើផ្នែកនីមួយៗនៃកោសិកាមានអ្វីខ្លះ ? ចូរពណ៌នា ។
3. ហេតុអ្វីបានជាសារពាង្គកាយអាចធំធាត់ ?
4. ចំពោះកុមារនិងមនុស្សពេញវ័យ តើកោសិកាធ្វើចំណែកដូចគ្នាដែរឬទេ ?
5. ចូរដាក់ឈ្មោះផ្នែកនីមួយៗរបស់កោសិការុក្ខជាតិ ។



មេរៀនទី

# 2 រូបផ្គុំសារពាង្គកាយមនុស្ស

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីកម្រិតរូបផ្គុំរបស់សារពាង្គកាយពហុកោសិកា
- ❑ ពណ៌នាពីរូបរាង ទំហំ និងនាទីរបស់កោសិកាប្រភេទនីមួយៗ
- ❑ ពណ៌នាពីសរីរាង្គផ្សេងៗដែលបង្កើតជាប្រព័ន្ធសរីរាង្គឬប្រដាប់
- ❑ បង្ហាញពីរូបផ្គុំរបស់សារពាង្គកាយមនុស្ស ។

ចំពោះសារពាង្គកាយពហុកោសិកា កោសិកាប្រភេទដូចគ្នាផ្គុំគ្នាបានជាជាលិកា ។ ជាលិកាផ្សេងៗផ្គុំគ្នាបានជាសរីរាង្គ ។ សរីរាង្គផ្សេងៗផ្គុំគ្នាបានជាប្រព័ន្ធសរីរាង្គឬប្រដាប់ ។ ប្រព័ន្ធសរីរាង្គធ្វើការជាមួយគ្នាដើម្បីបំពេញនាទីរួមមួយ ។ ដូចនេះ គេចែករូបផ្គុំសារពាង្គកាយជា ***ប្អូនកម្រិត*** គឺកោសិកា ជាលិកា សរីរាង្គ និងប្រព័ន្ធសរីរាង្គឬប្រដាប់ ។

## 1. កោសិកា

កោសិកាក្នុងសារពាង្គកាយមានរូបរាង ទំហំ និងនាទីខុសៗគ្នា ។

### 1.1. រូបរាង

កោសិកាស៊ុតបង្កកំណើតមានរាងស្វ៊ែ កោសិកាឈាមក្រហមមានរាងដូចថាស ហើយផតសងខាង ។ កោសិកាឆ្អឹងនិងកោសិកាប្រសាទមានរាងដូចផ្កាយដែលមានជ្រុងច្រើន កោសិកាអេពីតេល្យូមមានរាងស៊ីឡាំងនិងកោសិកាសាច់ដុំឆ្នូតមានរាងសរសៃៗ ។

### 1.2. ទំហំ

កោសិកាស៊ុតបង្កកំណើតជាកោសិកាធំជាងគេ ។ កោសិកាបន្តពូជឈ្មោលជាកោសិកាតូចបំផុត ។ កោសិកាដែលវែងជាងគេគឺ កោសិកាប្រសាទ ។

សារពាង្គកាយមនុស្សផ្គុំឡើងដោយកោសិការាប់កោដិ ។

### 1.3. នាទី

កោសិកាអេពីតេល្យូមមាននាទីគ្របដណ្តប់និងការពារសារពាង្គកាយ ។ កោសិកាសាច់ដុំមាននាទីធ្វើឱ្យសារពាង្គកាយមានចលនា ។ កោសិកាប្រសាទមាននាទីបញ្ជាទៅគ្រប់សរីរាង្គ ។ កោសិកាសន្ធានមាននាទីភ្ជាប់និងទ្រទ្រង់ផ្នែកទាំងឡាយរបស់សារពាង្គកាយ ។




*រូបទី2.1. រូបរាងផ្សេងៗរបស់កោសិកា*

## 2. ជាលិកា

ជាលិកាជាបណ្តុំកោសិកាប្រភេទដូចគ្នា ដែលធ្វើការរួមគ្នាដើម្បីបំពេញនាទីមួយ ។ ក្នុងសារពាង្គកាយមានជាលិកាច្រើនប្រភេទដូចជា ជាលិកាអេពីតេល្យូម ជាលិកាសាច់ដុំ ជាលិកាប្រសាទ ជាលិកាសន្ធាន ។ល ។

***ឧទាហរណ៍*** :

- ជាលិកាដែលពាសផ្ទៃខាងក្នុងនៃសរីរាង្គ ដូចជាក្រពះ ពោះវៀន ហៅថា ***ជាលិកាអេពីតេល្យូម*** ។ វាមាននាទីគ្របដណ្តប់និងការពារសរីរាង្គ ។
- ***ជាលិកាសន្ធាន*** ជាក្រុមកោសិកាឯកទេសសម្រាប់ភ្ជាប់និងទ្រទ្រង់ផ្នែកទាំងឡាយរបស់សារពាង្គកាយដូចជា ជាលិកាឆ្អឹង ជាលិកាសាច់ដុំ ។




*រូបទី2.2. ប្រភេទផ្សេងៗនៃជាលិកា*

## 3. សរីរាង្គ

សរីរាង្គជាទម្រង់មួយដែលបង្កឡើងដោយជាលិកាច្រើនប្រភេទ រួមគ្នាដើម្បីបំពេញនាទីរួមមួយ ។

***ឧទាហរណ៍*** ក្រពះបង្កឡើងដោយជាលិកាអេពីតេល្យូមនិងជាលិកាសាច់ដុំ ។ ជាលិកាទាំងនេះបំពេញនាទីរួមគ្នា ដើម្បីឱ្យក្រពះបំពេញនាទីរបស់វា គឺរំលាយអាហារ ។




*រូបទី2.3. ពំនុះភ្ញាលក្រពះ*

## 4. ប្រព័ន្ធសរីរាង្គឬប្រដាប់

ប្រព័ន្ធសរីរាង្គ ជាបណ្តុំសរីរាង្គមួយក្រុមដែលធ្វើការជាមួយគ្នា ដើម្បីបំពេញនាទីរួមមួយ ។

***ឧទាហរណ៍*** ប្រដាប់រំលាយអាហារផ្គុំឡើងពីសរីរាង្គមួយចំនួនដូចជា បំពង់អាហារ ក្រពះ ពោះវៀន ដើម្បីបំពេញនាទីរួមមួយគឺ***ការរំលាយអាហារ*** ។




*រូបទី2.4. ប្រដាប់រំលាយអាហារ*

## 5. សារពាង្គកាយ

សារពាង្គកាយមនុស្សផ្គុំឡើងដោយប្រព័ន្ធសរីរាង្គឬប្រដាប់ជាច្រើនដែលមាននាទីផ្សេងៗគ្នាដូចជា

- ប្រព័ន្ធសាច់ដុំរួមមាន សាច់ដុំនិងឆ្អឹង ។ វាមាននាទីជួយសារពាង្គកាយដើម្បីធ្វើចលនា ។
- ប្រដាប់រំលាយអាហាររួមមាន មាត់ បំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ ទ្វារធំ និងក្រពេញរំលាយអាហារ ។ វាមាននាទីរំលាយអាហារដែលយើងបរិភោគ ឱ្យទៅជាសារធាតុចិញ្ចឹមសម្រាប់សារពាង្គកាយនិងបញ្ចេញកាកសំណល់ទៅក្រៅ ។
- ប្រដាប់បញ្ចេញចោលរួមមាន តម្រងនោមពីរ បំពង់បង្ហូរនោម ប្លោកនោម និងក្រពេញញើស ។
- ប្រដាប់បន្តពូជមាននាទី បង្កកំណើតដើម្បីរក្សាពូជឱ្យគង់វង្សទៅថ្ងៃក្រោយ ។

- ប្រដាប់ដង្ហើមមាន សួតនិងបំពង់ខ្យល់ ។ វាមាននាទីក្នុងដំណើរបណ្ដូរឧស្ម័នរវាងសារពាង្គកាយនិងបរិយាកាស ។
- ប្រដាប់របត់ឈាមរួមមាន បេះដូង និងសរសៃឈាម ។ វាមាននាទីដឹកនាំសារធាតុចិញ្ចឹម អុកស៊ីសែន កាបូនឌីអុកស៊ីត និងកាកសំណល់ ។
- ប្រព័ន្ធប្រសាទរួមមាន ខួរក្បាល ខួរឆ្អឹងខ្នង និងសរសៃប្រសាទ ។ វាមាននាទីបញ្ជារាល់សកម្មភាពរបស់សរីរាង្គទាំងអស់ ដើម្បីធ្វើឱ្យសារពាង្គកាយសម្របទៅនឹងបម្រែបម្រួលរបស់មជ្ឈដ្ឋានខាងក្រៅ ។




*រូបទី2.5. ប្រដាប់ឬប្រព័ន្ធផ្សេងៗក្នុងខ្លួនមនុស្ស*

## ៦. ទិដ្ឋភាពទូទៅនៃសរីរាង្គក្នុងខ្លួនមនុស្ស

ដងខ្លួនមនុស្សចែកជាពីរចំណែកគឺ ទ្រូងនិងពោះ ។ ទ្រូងនិងពោះខណ្ឌគ្នាដោយសារ ***សន្ទះទ្រូង*** ។

- នៅក្នុងទ្រូងមានសួតពីរ និងបេះដូងមួយ ។
- នៅក្នុងពោះមានក្រពះ ថ្លើម ប្រមាត់ ពោះវៀន លំពែង ។ នៅខាងក្រោយពោះវៀនមានតម្រងនោមពីរដែលទាក់ទងទៅនឹងប្លោកនោម ។




*រូបទី2.6. ទិដ្ឋភាពទូទៅក្នុងខ្លួនមនុស្ស*

## ៧. នាទីរបស់សរីរាង្គនិងប្រព័ន្ធសរីរាង្គ

រាល់សរីរាង្គនៃប្រព័ន្ធសរីរាង្គនីមួយៗក៏ដូចជាប្រព័ន្ធសរីរាង្គនីមួយៗក្នុងសារពាង្គកាយទាំងមូល តែងតែបំពេញមុខងារស៊ីសង្វាក់គ្នា ។ ***ឧទាហរណ៍*** នៅពេលលេងកីឡា ឬហាត់ប្រាណ យើងឃើញថា ប្រព័ន្ធសាច់ដុំត្រូវការថាមពលច្រើនដើម្បីធ្វើសកម្មភាព ដូចនេះវាត្រូវស្រូបយកអុកស៊ីសែននិងបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីតច្រើនជាងពេលមិនធ្វើសកម្មភាព ។ ជាមួយគ្នានេះដែរបេះដូងរបស់យើងធ្វើការខ្លាំងក្លាទើបអាចផ្តល់អុកស៊ីសែនគ្រប់គ្រាន់សម្រាប់ការចំណាយថាមពលក្នុងការធ្វើសកម្មភាពរបស់ប្រព័ន្ធសាច់ដុំបាន ។

ចំណែកប្រព័ន្ធប្រសាទក៏មាននាទីសំខាន់ដែរក្នុងការបញ្ជារាល់សកម្មភាពរបស់សារពាង្គកាយឱ្យមានភាពស៊ីសង្វាក់គ្នា ។

## មេរៀនសង្ខេប

- គេចែករូបផ្គុំសារពាង្គកាយជាបួនកម្រិត កោសិកា ជាលិកា សរីរាង្គ ប្រព័ន្ធសរីរាង្គ ឬប្រដាប់ ។
- កោសិកាប្រភេទនីមួយៗមានរូបរាង ទំហំ និងនាទីខុសៗគ្នា ។
- កោសិកាមួយប្រភេទដែលមាននាទីដូចគ្នា ផ្គុំបានជាជាលិកា ។
- ជាលិកាប្រភេទផ្សេងៗមាននាទីតែមួយ ផ្គុំបានជាសរីរាង្គ ។
- សរីរាង្គផ្សេងៗមាននាទីតែមួយហៅថា ប្រព័ន្ធសរីរាង្គ ឬប្រដាប់ ។
- ប្រព័ន្ធសរីរាង្គឬប្រដាប់ធ្វើការជាមួយគ្នាដើម្បីបំពេញនាទីរួមមួយ ហើយបង្កើតបានជាសារពាង្គកាយមួយ ។
- នៅក្នុងទ្រូងមានសួតពីរនិងបេះដូងមួយ ។ នៅក្នុងពោះមានក្រពះ ថ្លើម ប្រមាត់ ពោះវៀនលំពែង ។ នៅខាងក្រោយពោះវៀនមានតម្រងនោមដែលទាក់ទងទៅនឹងប្លោកនោម ។
- សរីរាង្គនីមួយៗក៏ដូចជាប្រព័ន្ធសរីរាង្គនៅក្នុងសារពាង្គកាយ បំពេញនាទីមានភាពស៊ីសង្វាក់គ្នា ។
- ប្រព័ន្ធប្រសាទមាននាទីសំខាន់ក្នុងការបញ្ជារាល់សកម្មភាពរបស់សារពាង្គកាយដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នា ។

## សំណួរ

1. ចូរឱ្យឧទាហរណ៍កោសិកាមួយចំនួនដែលមានរូបរាងនិងនាទីខុសគ្នា ។
2. ចូរពន្យល់ពាក្យ ជាលិកា សរីរាង្គ ប្រព័ន្ធសរីរាង្គ ឬប្រដាប់ ។
3. តើសរីរាង្គអ្វីខ្លះដែលផ្គុំគ្នាបានជាប្រដាប់រំលាយអាហារ ?
4. ហេតុអ្វីបានជារាល់សកម្មភាពរបស់សារពាង្គកាយមានភាពស៊ីសង្វាក់គ្នា ?
5. ចូរដាក់ឈ្មោះសរីរាង្គនីមួយៗដែលមាននៅក្នុងខ្លួនមនុស្ស ។



# 3 កោសិការុក្ខជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីរូបផ្គុំកោសិកាស្លឹករុក្ខជាតិ
- ❑ រៀបរាប់ពីលក្ខណៈពិសេសនៃកោសិការុក្ខជាតិ
- ❑ បង្ហាញពីសារប្រយោជន៍របស់រុក្ខជាតិចំពោះមនុស្ស ។

យើងដឹងហើយថា សារពាង្គកាយមនុស្សផ្គុំឡើងពីកោសិកាជាច្រើន ។ តើមានតែសារពាង្គកាយមនុស្សទេឬដែលបង្កឡើងពីកោសិកា ?

ការពិតរុក្ខជាតិគ្រប់ប្រភេទទាំងអស់សុទ្ធតែផ្គុំឡើងពីកោសិកា។ ចូរយើងសង្កេតមើលដោយប្រុងប្រយ័ត្ននូវស្រទាប់កោសិកាមើមខ្ទឹមបារាំងក្រោមមីក្រូទស្សន៍ ។

## 1. រូបផ្គុំកោសិការុក្ខជាតិ

### 1.1. កោសិកាអេពីឌែមមើមខ្ទឹមបារាំង

យើងប្រើម្ជុលលំពែងឆ្កឹះយកស្រទាប់កោសិកាអេពីឌែមមើមខ្ទឹមបារាំងទៅសង្កេតក្រោមមីក្រូទស្សន៍អុបទិច ។ យើងឃើញធាតុវែងៗជាច្រើនរាងជាពហុកោណដែលជាប់គ្នាទៅវិញទៅមកគឺ ***កោសិការុក្ខជាតិ*** ។




*រូបទី 3.1. កោសិកាអេពីឌែមមើមខ្ទឹមបារាំង*

កោសិកានីមួយៗមាន ៖

- ***ណ្វៃយ៉ូ*** មានរាងស្វ៊ែឬរាងពងក្រពើ ។
- ***ស៊ីតូប្លាស*** ព័ទ្ធជុំវិញណ្វៃយ៉ូនិងវ៉ាគុយអូល ។ ស៊ីតូប្លាសមានលក្ខណៈគ្រាស់តាមមុំនៃកោសិកា ។
- ***វ៉ាគុយអូល*** ប្រហោងធំមួយមានទំហំធំប្រហែលទំហំរបស់កោសិកាដែលផ្ទុកសារធាតុផ្សេងៗ ។
- ***ភ្នាសស៊ីតូប្លាស*** ព័ទ្ធជុំវិញស៊ីតូប្លាស ។

- ភ្នាសមួយទៀតក្រាស់ព័ទ្ធពីលើភ្នាសស៊ីតូប្លាសហៅថា ***ភ្នាសសែលុយឡូស***។ ភ្នាសនេះបង្កឡើងពីជាតិសែលុយឡូស ។

### 1.2. រូបផ្តុំកោសិកានៃស្លឹកអេឡូដេ

អេឡូដេ ជាប្រភេទរុក្ខជាតិដែលច្រើនដុះនៅក្នុងបឹងបួ ។ វាមានស្លឹកតូចៗហើយស្តើង ។ ស្លឹកនេះផ្គុំគ្នាបីៗតាមថ្នាំងនីមួយៗ ។ ក្រោមមីក្រូទស្សន៍ យើងសង្កេតឃើញស្លឹករបស់វាកើតឡើងពីកោសិកាជាច្រើនមានរាងជាពហុកោណ ។ ក្នុងស៊ីតូប្លាសនៃកោសិកានីមួយៗមាន :

- វ៉ាគុយអូល
- ធាតុតូចៗពណ៌បៃតងគឺជា ***ក្លរ៉ូប្លាស***។ ក្លរ៉ូប្លាសស្ទើរទាំងអស់ធ្វើចលនាវិលជុំវិញវ៉ាគុយអូលជានិរន្តរ៍ ។
- ណៃយ៉ូ ។



*រូបទី3.2. អេឡូដេ ក. ដើមអេឡូដេ ខ. កោសិកាស្លឹកអេឡូដេ*

## 2. លក្ខណៈពិសេសនៃកោសិការុក្ខជាតិ

ហេតុអ្វីបានជារុក្ខជាតិមានលក្ខណៈរឹងមិនទន់ដូចស្បែកមនុស្ស ព្រមទាំងមានស្លឹកពណ៌បៃតង ផ្កា និងផ្លែមានពណ៌ផ្សេងៗ ?

### 2.1. ភ្នាសគ្រោងឬភ្នាសសែលុយឡូស

ភ្នាសស៊ីតូប្លាសជាភ្នាសរួស ទន់ ដែលរុំព័ទ្ធពីក្រៅស៊ីតូប្លាស ហើយភ្ជាប់ខ្លួនវាពីខាងក្រៅទៅនឹងភ្នាសមួយទៀត ។ ដោយសារភ្នាសខាងក្រៅនេះហើយដែលកោសិការុក្ខជាតិមានរូបរាងជាក់លាក់ រឹង ខុសពីកោសិកាសត្វ ។ វាគឺជា ***ភ្នាសគ្រោង*** ឬ ***ភ្នាសសែលុយឡូស*** ដែលបង្កឡើងដោយជាតិសែលុយឡូស ។

### 2.2. ប្លាស

ប្លាស ជាធាតុកោសិកានៅក្នុងស៊ីតូប្លាសដែលមានរូបរាងផ្សេងៗ ភាគច្រើនមានរាងស្វ៊ែ ។ នៅក្នុងប្លាសមានផ្ទុកនូវសារធាតុផ្សេងៗដែលវាសម្រាំងបានដូចជា អាមីដុងជាដើម ។ តាមនាទីរបស់វាគេចែកប្លាសជា ៖

- ***ក្លរ៉ូប្លាស*** គឺជាប្លាសមានផ្ទុកជាតិពណ៌បៃតង ហៅថាក្លរ៉ូភីល ។

- ***អាមីឡូប្លាស*** គឺជាប្លាសគ្មានពណ៌ ដែលផ្ទុកអាមីដុង ។
- ***ក្រូម៉ូប្លាស*** គឺជាប្លាសមានផ្ទុកពណ៌ផ្សេងៗក្រៅពីក្លរ៉ូភីល ជួនកាលពណ៌លឿងហៅថា ***សង់តូភីល*** ជួនកាលពណ៌ក្រហមហៅថា ***ការ៉ូតែន*** ។




***រូបទី 3.3. ប្លាស***

## 2.3. វ៉ាគុយអូល

វ៉ាគុយអូល គឺជាថង់មួយក្នុងស៊ីតូប្លាស ដែលបំពេញទៅដោយវត្ថុរាវម្យ៉ាងហៅថា ***រសវ៉ាគុយអូល*** ។ ក្នុងវ៉ាគុយអូលមានផ្ទុកអាហារ សារធាតុផ្សេងៗដែលកោសិកាត្រូវការនិងកាកសំណល់ ។

# 3. សារប្រយោជន៍របស់រុក្ខជាតិ

រុក្ខជាតិជាសម្បត្តិរបស់មនុស្ស ដូចនេះយើងត្រូវចេះប្រើប្រាស់រុក្ខជាតិឱ្យស្របទៅនឹងលក្ខណៈសម្បត្តិរបស់វា ដូចជា រុក្ខជាតិសម្រាប់ធ្វើអាហារ រុក្ខជាតិឱសថ រុក្ខជាតិពុល រុក្ខជាតិឧស្សាហកម្ម និងរុក្ខជាតិលំអ ។

មនុស្សមិនអាចរស់នៅបានដោយគ្មាន រុក្ខជាតិនិងសត្វទេ ។ ដូចនេះយើងចាំបាច់ត្រូវថែរក្សានិងការពាររុក្ខជាតិ ។ ការថែរក្សានិងការពាររុក្ខជាតិផ្តល់ដល់មនុស្សនូវប្រយោជន៍ច្រើនយ៉ាង ដូចជាធ្វើអាជីវកម្ម ធ្វើសំណង់ ធ្វើគ្រឿងសង្ហារិម ជាជម្រករបស់សត្វគ្រប់ប្រភេទ ធ្វើជាប្រភពថាមពល (អុសនិងធ្យូង) អាចជារបាំងការពារព្យុះ អាចទប់ស្កាត់ការហូរច្រោះដី អាចថែរក្សាធាតុអាកាសមិនឱ្យមានបម្រែបម្រួលខ្លាំង អាចទាក់ទាញទឹកភ្លៀង ទប់ទឹកជំនន់ ធ្វើជារបងការពារប្រទេសជាតិ ជាអាហារផ្តល់ជីជាតិដល់ដីកសិកម្ម ទាក់ទាញទេសចរ ជាពិសេសរុក្ខជាតិមួយចំនួនអាចយកទៅធ្វើជាឱសថសម្រាប់ព្យាបាលរោគមនុស្សនិងសត្វទៀតផង ។

## មេរៀនសង្ខេប

- គ្រប់រុក្ខជាតិទាំងអស់បង្កឡើងពីកោសិកាដែលមានរាងជាពហុកោណ ។ កោសិកានីមួយៗមានណៃយ៉ូ ស៊ីតូប្លាស វ៉ាគុយអូល ភ្នាសស៊ីតូប្លាស និងភ្នាសសែលុយឡូសដែលព័ទ្ធពីលើភ្នាសស៊ីតូប្លាស ។ នៅក្នុងស៊ីតូប្លាសរបស់កោសិកានីមួយៗនៃស្លឹករុក្ខជាតិមានវ៉ាគុយអូល ក្លរ៉ូប្លាស និងណៃយ៉ូ ។
- លក្ខណៈពិសេសរបស់កោសិការុក្ខជាតិគឺ
- ភ្នាសគ្រោងឬភ្នាសសែលុយឡូស ដែលធ្វើឱ្យរុក្ខជាតិមានរូបរាងជាក់លាក់និងរឹងខុសពីកោសិកាសត្វ ។
- ប្លាសមានក្លរ៉ូប្លាសផ្ទុកក្លរ៉ូភីលជាតិពណ៌បៃតង អាមីឡូប្លាសផ្ទុកអាមីដុងគ្មានពណ៌ និងក្រូម៉ូប្លាសផ្ទុកជាតិពណ៌ផ្សេងៗ ជួនកាលពណ៌លឿង (សង់តូភីល) ជួនកាលពណ៌ក្រហម (ការ៉ូតែន) ។
- វ៉ាគុយអូលផ្ទុករសវ៉ាគុយអូល ។

## សំណួរ

1. តើកោសិការុក្ខជាតិមានរាងយ៉ាងដូចម្ដេច ?
2. ចូរពណ៌នាពីលក្ខណៈពិសេសរបស់រុក្ខជាតិ ។
3. តើប្លាសក្នុងកោសិកាស្លឹកអេឡូដេជាអ្វី ? តើវាមានលក្ខណៈពិសេសអ្វី ?
4. ហេតុអ្វីបានជារុក្ខជាតិមានលក្ខណៈរឹង ស្លឹកមានពណ៌បៃតង ផ្លែ និងផ្កាមានពណ៌ផ្សេងៗ ?
5. ហេតុអ្វីបានជាប្អូនចាំបាច់ត្រូវថែរក្សា និងការពាររុក្ខជាតិ ?

## សំណួរនិងលំហាត់ជំពូក 3

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. ណៃយ៉ូរបស់កោសិកាមាននាទី

☐ក. បញ្ជាគ្រប់សកម្មភាពរបស់កោសិកា ☐ខ. ផ្ទុកប្លាស

☐គ. ផ្ទុករសកោសិកា ☐ឃ. ព័ទ្ធពីក្រៅធាតុកោសិកា ។

2. កោសិការុក្ខជាតិមានរាងជាក់លាក់រឹងខុសពីកោសិកាសត្វនិងកោសិកាមនុស្សដោយ

☐ក. ភ្នាសសែលុយឡូស ☐ខ. ភ្នាសស៊ីតូប្លាស

☐គ. វ៉ាគុយអូល ☐ឃ. ប្លាស ។

3. ប្លាសដែលផ្ទុកជាតិពណ៌លឿងហៅថា

☐ក. ក្លរ៉ូប្លាស ☐ខ. ក្រូម៉ូប្លាស

☐គ. អាមីឡូប្លាស ☐ឃ. វ៉ាគុយអូល ។

4. ក្នុងកោសិការុក្ខជាតិ អាហារនិងកាកសំណល់ផ្ទុកនៅក្នុង

☐ក. ណៃ្វយ៉ូ ☐ខ. ប្លាស

☐គ. វ៉ាគុយអូល ☐ឃ. ស៊ីតូប្លាស ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

1. គ្រប់សរីរាង្គ (ស្លឹក ឫស ដងដើម) របស់រុក្ខជាតិសុទ្ធតែបង្កឡើងដោយ ....... ។

2. ប្រភេទកោសិកាផ្សេងៗមាន ........ និង ....... ខុសៗគ្នា ។

3. ក្រុមកោសិកាដែលមានរូបរាងនិងទម្រង់រូបផ្គុំដូចគ្នា ហើយបំពេញមុខងាររួមមួយគឺជា..... ។

III. ចូរឆ្លើយសំណួរខាងក្រោមនេះ

1. តើគេអាចដឹងបានឬទេ ថាកោសិកាណាមួយជាកោសិការុក្ខជាតិ ? ព្រោះអ្វី ?

2. ចូរពណ៌នាពីដំណើរចំណែកកោសិការុក្ខជាតិ ?

3. ហេតុអ្វីក៏កោសិការុក្ខជាតិមានរាងមួយជាក់លាក់ ?

4. ហេតុអ្វីបានជារុក្ខជាតិមានលក្ខណៈរឹង ?

5. តើប្លាសក្នុងកោសិការុក្ខជាតិមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

6. ចូរប្រៀបធៀបកោសិកាសត្វនិងកោសិការុក្ខជាតិតាមរយៈរូបភាពខាងក្រោម ។

លក្ខណៈខុសគ្នា លក្ខណៈដូចគ្នា លក្ខណៈខុសគ្នា



## ជំពូក 4

# ការរំលាយអាហារ



អ្នកប្រហែលធ្លាប់និយាយថា "ឈ្ងុយក្លិនអ្វីនឹងហ្ន៎! រមួលពោះណាស់ ឬក្រពះខ្ញុំកូរព្រួតៗ"។

ក្រពះជាផ្នែកមួយនៃប្រដាប់រំលាយអាហារ។ វាមាននាទីក្នុងការកិនបំបែកអាហារ។ ក្នុងរូបភាពខាងលើនេះ យើងឃើញមនុស្សពីរនាក់កំពុងបរិភោគអាហារយ៉ាងឆ្ងាញ់។ អ្នកក៏ដូចអ្នកទាំងពីរនេះដែរ នៅពេលអ្នកចាប់កាន់អ្វីមួយបរិភោគ ក្នុងខ្លួនអ្នកនឹងមានដំណើរការមួយកើតឡើង។ ដំណើរការនេះជួយឱ្យសារពាង្គកាយចាប់យកសារធាតុចិញ្ចឹមពីអាហារដែលអ្នកបរិភោគ។

តើប្រដាប់រំលាយអាហារមានសរីរាង្គអ្វីខ្លះ ?

តើក្នុងខ្លួនយើងអាហារត្រូវបានបំបែកដូចម្ដេច ?

មេរៀនទី

# 1 រូបផ្តុំប្រដាប់រំលាយអាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យ " ការរំលាយអាហារ"
- ❑ រាប់ឈ្មោះផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ ។

ហេតុអ្វីបានជាមនុស្ស និងសត្វស៊ីអាហារ ? ទាំងសត្វទាំងមនុស្សមានមូលហេតុដូចគ្នា គឺស៊ីអាហារដើម្បីចិញ្ចឹមជីវិត ។ សារពាង្គកាយប្រើប្រាស់ថាមពលដើម្បីផ្លាស់ទី លូតលាស់ ធំធាត់ ប្រឆាំងនឹងជំងឺជាដើម ។ យើងទទួលបានថាមពលពីអាហារដែលយើងបរិភោគ ។ អាហារក៏បានផ្គត់ផ្គង់នូវរូបធាតុដើមចាំបាច់សម្រាប់បង្កើតកោសិកាថ្មីៗ នៅពេលលូតលាស់និងជួសជុលជាលិកាខូចខាតនៅក្នុងសារពាង្គកាយ ។ បើគ្មានអាហារទេ យើងទាំងអស់គ្នានឹងស្លាប់ ។

## 1. តម្រូវការការរំលាយអាហារ




*រូបទី 1.1. តម្រូវការការរំលាយអាហារ*

អាហារដែលយើងបរិភោគមិនអាចរំលាយបានទេ ភាគច្រើនវាកើតពីម៉ូលេគុលធំៗ ។ សារពាង្គកាយយើងមិនអាចប្រើប្រាស់ថាមពលនៅក្នុងអាហារបែបនេះបានទេ ។

តើត្រូវធ្វើដូចម្តេចចំពោះអាហារដែលយើងបរិភោគ ? គ្រប់ម៉ូលេគុលអាហារទាំងអស់ត្រូវតែបំបែកជាមុនសិន ទើបសារពាង្គកាយអាចប្រើប្រាស់វាបាន ។ ដំបូងម៉ូលេគុលធំៗនៃអាហារត្រូវបានបំបែកជាដុំតូចៗ ហើយនៅចុងបញ្ចប់វាត្រូវបំបែកជាម៉ូលេគុលតូចល្អិត និងងាយ ។ ម៉ូលេគុលល្អិតៗនិងងាយទាំងនេះជ្រាបចូលក្នុងឈាម ហើយដឹកនាំទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយ

(រូបទី 1.1) ។ លំនាំនៃការបំបែកអាហារឱ្យទៅជាម៉ូលេគុលតូចល្អិត និងងាយហៅថា " ***ការរំលាយអាហារ*** " ។ ការរំលាយអាហារកើតមាននៅក្នុងប្រដាប់រំលាយអាហារ ។ ផ្នែកនីមួយៗនៃប្រដាប់រំលាយអាហារមាននាទីពិសេសរៀងៗខ្លួន ។ ការរំលាយអាហារចាប់ផ្តើមពេលអ្នកដាក់អាហារក្នុងមាត់ ។

## 2. រូបផ្តុំប្រដាប់រំលាយអាហារ

ការរំលាយអាហារកើតឡើងនៅក្នុងមាត់និងបំពង់រំលាយអាហារដែលនៅទីនោះ អាហារត្រូវបានបំបែកបន្តិចម្តងៗទៅជាម៉ូលេគុលតូច ល្អិត និងងាយ ។ មុននឹងសិក្សាពីដំណើរការរំលាយអាហារ យើងត្រូវសង្កេតមើលផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារសិន (រូបទី 1.2) ។




***រូបទី*** *1.2. រូបផ្តុំប្រដាប់រំលាយអាហារ*

**មេរៀនសង្ខេប**

- ដំណើរការបំបែកអាហារពីម៉ូលេគុលធំៗទៅជាម៉ូលេគុលតូចល្អិត និងងាយហៅថា " ការរំលាយអាហារ " ។
- ប្រដាប់រំលាយអាហារមានធ្មេញ បំពង់អាហារ និងក្រពេញរំលាយអាហារ ។ ។

## ? សំណួរ

1. ដូចម្តេចហៅថាការរំលាយអាហារ ?
2. តើប្រដាប់ដែលមាននាទីរំលាយអាហារហៅថាអ្វី ?
3. តើប្រដាប់នោះមានសរីរាង្គអ្វីខ្លះ ?

# 2 ផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ប្រាប់ឈ្មោះផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ
- ❑ បង្ហាញពីភាពខុសគ្នារវាងធ្មេញទឹកដោះ និងធ្មេញស្រុក
- ❑ ពណ៌នាពីនាទីផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ ។

ប្រដាប់រំលាយអាហារមាន ធ្មេញ បំពង់រំលាយអាហារ និងក្រពេញរំលាយអាហារ ។

## 1. ធ្មេញ

### 1.1. ទម្រង់ធ្មេញ



រូបទី2.1 ពំនុះធ្មេញ

ពំនុះធ្មេញតាមបណ្តោយ បង្ហាញឱ្យឃើញៈ

ក. ភ្លុកធ្មេញជាសារធាតុប្រហោងៗ ហើយរឹងខ្លាំង ។

ខ. កាចធ្មេញជាសារធាតុពណ៌ស រឹងខ្លាំងជាងភ្លុកធ្មេញ ប៉ុន្តែស្រួយ ។ កាចធ្មេញរុំស្រោបភ្លុកនៃដើមធ្មេញ ។

គ. សំបកធ្មេញជាជាលិកាឆ្អឹងពណ៌លឿង ដែលរុំស្រោបភ្លុកនៃឫសធ្មេញ ។

ឃ. បណ្តូលធ្មេញជាជាលិកាសន្ធាន ។ វាមានសរសៃឈាមជាច្រើននិងសរសៃប្រសាទមួយដែលធ្វើឱ្យធ្មេញរួស ។ ដូចនេះធ្មេញមានជីវិត ។



រូបទី2.2 ប្រភេទទាំង 4 នៃធ្មេញមនុស្ស

ធ្មេញមនុស្សនីមួយៗមានពីរផ្នែកៈ

- ដើមធ្មេញ ៖ ផ្នែកនៅខាងលើអញ្ចាញធ្មេញ ។
- ឫសធ្មេញ ៖ ផ្នែកកប់នៅក្នុងរណ្តៅធ្មេញ ។

នៅចន្លោះផ្នែកទាំងពីរនេះ គេសំគាល់ឃើញមានស្នាមស្តួចយ៉ាងស្រាលហៅថា " ***គល់ធ្មេញ*** " ។

### 1.2. ប្រភេទធ្មេញ

មនុស្សពេញវ័យមានធ្មេញចំនួន 32 ដែលចែកចេញជា 4 ប្រភេទខុសគ្នា ។ ឆ្អឹងថ្គាមមួយចំហៀងមាន ៈ

- ធ្មេញមុខពីរមានដើមធ្មេញមុតនិងឫសមួយ ។ ធ្មេញមុខមាននាទីខាំកកេរ ។
- ចង្កូមមួយមានដើមធ្មេញស្រួចនិងឫសមួយ វែងជាងឫសធ្មេញមុខ ។ វាមាននាទីហែក ។
- ថ្គាមតូចពីរមានដើមធ្មេញនិងឫសព្រែក ។ ថ្គាមតូចមាននាទីទំពា ។
- ថ្គាមធំបី មានដើមធ្មេញធំមាំនិងឫសបី ។ ថ្គាមធំមាននាទីទំពា ។



រូបទី2.3. កម្រងធ្មេញ

មនុស្សដុះធ្មេញពីរដងបន្តបន្ទាប់គ្នា។ កូនក្មេងទើបកើតគ្មានធ្មេញទេ ។ ធ្មេញដែលដុះចេញដំបូងហៅថា ***ធ្មេញទឹកដោះ*** (ចាប់ដុះចន្លោះពីអាយុ 6 ខែ ទៅ 30 ខែ) ។ ក្មេងគ្មានថ្គាមទេ ។ ចាប់ពីអាយុ 6 ឬ 7 ឆ្នាំឡើងទៅ ធ្មេញទឹកដោះក៏បាក់ ធ្មេញស្រុកដុះជំនួសម្តងមួយៗ ។ ធ្មេញស្រុកដុះនៅចន្លោះអាយុពី 6 ទៅ 11 ឆ្នាំ ។ ថ្គាមធំទី 3 ហៅថា ថ្គាមទាល់ដែលដុះចេញនៅចន្លោះអាយុពី 25 ទៅ 30 ឆ្នាំ ប៉ុន្តែជួនកាលថ្គាមទាល់នេះមិនដុះទេ ។ ធ្មេញមានរូបមន្តដូចខាងក្រោមនេះ

$$\frac{\text{ធ.ម.}2+\text{ច.}1+\text{ថ.ត}2+\text{ថ.}3}{\text{ធ.ម.}2+\text{ច.}1+\text{ថ.ត}2+\text{ថ.}3}$$

→ ធ្មេញពាក់កណ្តាលឆ្អឹងថ្គាមលើ
→ ធ្មេញពាក់កណ្តាលឆ្អឹងថ្គាមក្រោម

## 2. បំពង់រំលាយអាហារ

បំពង់រំលាយអាហារមានមាត់ ដើមក បំពង់អាហារ ក្រពះ ពោះវៀនតូច និងពោះវៀនធំ ។

### 2.1. ប្រហោងមាត់

ប្រហោងមាត់ មានបបូរមាត់ ថ្ពាល់ និងឆ្អឹងក្រអូម ។ នៅក្នុងមាត់មានអណ្តាត និងធ្មេញ ។ អណ្តាតជាសរីរាង្គសាច់ដុំមានចលនាច្រើន ដែលមានស្បែកស្តើងពាសដោយអញ្ចាញ ។ អញ្ចាញមានពីរបែបៈ មួយបែបសម្រាប់ឱ្យដឹងការប៉ះនិងមួយបែបទៀតឱ្យដឹងរសជាតិ ។ នាទីសំខាន់របស់មាត់គឺទំពាអាហារឱ្យល្អិត ។



រូបទី 2.4 ប្រហោងមាត់

## 2.2. ដើមក

ដើមក ជាកន្លែងកាត់ខ្វែងរវាងផ្លូវអាហារនិងផ្លូវដង្ហើម (រូបទី 2.5) ។ នៅពេលលេបអាហារចូល ផ្លូវដង្ហើមអាចបិទជិត ដោយសាររបាំងក្រអូមខាងលើ ។ របាំងក្រអូមនេះអាចបិទរូងច្រមុះ (រន្ធច្រមុះខាងក្នុង) ។ នៅផ្នែកខាងក្រោមមានសន្ទះខ្យល់ដែលអាចបិទបំពង់សំឡេង ។ ដើមកជាបំពង់មួយសម្រាប់ឱ្យអាហារធ្លាក់ចុះទៅក្នុងបំពង់អាហារ ។



*រូបទី 2.5 ដើមក*

## 2.3. បំពង់អាហារ

បំពង់អាហារ ជាបំពង់មួយប្រវែង 25cm ដែលស្ថិតនៅចន្លោះឆ្អឹងខ្នងនិងទងសួត ។ វាឆ្លងកាត់សន្ទះទ្រូង ហើយភ្ជាប់ទៅនិងក្រពះតាមរន្ធមួយហៅថា ***ទ្វារលើក្រពះ*** ។ បំពង់អាហារមាននាទីបញ្ជូនអាហារទៅឱ្យក្រពះ ។

## 2.4. ក្រពះ

ក្រពះ ជាថង់មួយមានចំណុះប្រហែល 2ℓ ។ ផ្ទៃរបស់វាមានកម្រាស់ពី 2 – 3mm ។ ភ្នាសរបស់វាមានក្រពេញជាច្រើន ។ អាហារត្រូវបានកិនលំអិតនៅក្នុងក្រពះ ។ ក្រពះទាក់ទងនឹងពោះវៀនតូចតាមទ្វារក្រោមក្រពះ ។ អាហារចេញពីក្រពះ ហើយធ្លាក់ចូលទៅក្នុងពោះវៀនតូច ។



*រូបទី 2.6 ក្រពះ*

## 2.5. ពោះវៀនតូច

ពោះវៀនតូចជាបំពង់បត់បែនច្រើនផ្នត់ ។ វាមានប្រវែងប្រហែល 7m ។ ផ្ទៃក្នុងនៃពោះវៀនតូចមានផ្នត់ភ្នាសសើមជាច្រើន ដែលនៅលើផ្នត់នោះមានកន្ទួលតូចៗ ហៅថា ជ្រាំងពោះវៀន ។ ពោះវៀនតូចទាក់ទងនឹងពោះវៀនធំ ដោយសារច្រិសមួយដែលការពារមិនឱ្យលាមកមនុស្សត្រឡប់ពីពោះវៀនធំទៅពោះវៀនតូច ។ ការរំលាយអាហារត្រូវបានបញ្ចប់ទៅក្នុងពោះវៀនតូច ។ អាហាររលាយជ្រាបចូលទៅក្នុងឈាម តាមភ្នាសពោះវៀនតូច ។

## 2.6. ពោះវៀនធំ

ពោះវៀនធំមានប្រវែងប្រហែល 1.50m និងអង្កត់ផ្ចិត 10cm ។ នៅដើមពោះវៀនធំមានខ្នែងពោះវៀនប្រវែងប្រហែល 2 – 4cm ។ ការរលាកខ្នែងនេះបណ្ដាលឱ្យមានជំងឺខ្នែងពោះវៀន ។ នៅខាងចុងពោះវៀនធំមានចុងពោះវៀននិងទ្វារធំ ។ ផ្ទៃពោះវៀនធំសម្បូរដោយសាច់ដុំ ប៉ុន្តែគ្មានក្រពេញរំលាយអាហារទេ ។ ពោះវៀនធំមាននាទីស្រូបយកទឹកនិងអំបិលខនិជពីអាហារមិនរលាយ ។



រូបទី 2.7 ខ្នាត់ពោះវៀនធំ

# 3. ក្រពេញរំលាយអាហារ

ក្រពេញរំលាយអាហារមាន : ក្រពេញទឹកមាត់ ក្រពេញក្រពះ ក្រពេញពោះវៀនតូច លំពែង ថ្លើម ។

## 3.1. ក្រពេញទឹកមាត់

ក្រពេញទឹកមាត់មានរាងជាចង្កោម ។ គេចែកវាជាបីក្រុម គឺក្រពេញគុម្ពត្រចៀកស្ថិតនៅក្រោមថ្គាល់ក្បែរត្រចៀក ។ វាបញ្ចេញទឹកមាត់រាវខ្លាំង ។ ការរលាកក្រពេញនេះ បណ្ដាលឱ្យកើតសាលាខែន ។ ក្រពេញក្រោមថ្គាមនិងក្រពេញក្រោមអណ្ដាតបញ្ចេញទឹកមាត់ខាប់ និងអន្ទិល ។ ទឹកមាត់មាននាទីជ្រើមនិងរំលាយអាហារ ។



រូបទី 2.8 ក្រពេញទឹកមាត់

## 3.2. ក្រពេញក្រពះ

វាស្ថិតនៅក្នុងផ្ទៃក្រពះ ។ វាបញ្ចេញរសក្រពះសម្រាប់រំលាយអាហារ ។ ក្រពេញក្រពះមានរាងជាបំពង់ងាយនិងបែកខ្នែង ។



រូបទី 2.9 ក្រពេញក្រពះ

## 3.3. ក្រពេញពោះវៀនតូច

ក្រពេញពោះវៀនតូចស្ថិតក្នុងផ្ទៃពោះវៀនតូច ។ វាមានរាងជាចង្កោម និងបំពង់ ។ វាបញ្ចេញរសពោះវៀនសម្រាប់រំលាយអាហារ ។

## 3.4. លំពែង

លំពែងជាក្រពេញមួយដែលស្ថិតនៅផ្តេកក្រោមក្រពះ ។ លំពែងមានទម្ងន់ប្រហែល 70g ។ បំពង់បញ្ចេញរបស់វា ស្ថិតនៅក្បែរគល់ពោះវៀនចម្ងាយ 2 – 3cm ពីទ្វារក្រោមក្រពះត្រង់កន្លែងប្រសព្វមុខគ្នា ជាមួយបំពង់ប្រមាត់ដែលចេញពីថ្លើម ។ លំពែងបញ្ចេញរសលំពែងទៅក្នុងពោះវៀនតូច ។

## 3.5. ថ្លើម

ថ្លើមជាក្រពេញធំជាងគេពណ៌ត្នោត ។ វាមានទម្ងន់ 2kg ស្ថិតនៅក្រោមសន្ទះទ្រូងផ្នែកខាងស្តាំ ។ ថ្លើមផលិតទឹកប្រមាត់ដែលហូរ ចូល ទៅក្នុងថង់ ទឹកប្រមាត់ រួចចូលទៅក្នុងពោះវៀនតូចតាមបំពង់ទឹកប្រមាត់នៅពេល រំលាយអាហារ ។ បំពង់ទឹកប្រមាត់និងបំពង់ទឹកលំពែងចូលទៅក្នុងពោះ វៀនតូចនៅកន្លែងតែមួយ ។




*រូបទី 2.10 ថ្លើម និងលំពែង*

ថ្លើម ក្រពះ លំពែង ពោះវៀន រុំព័ទ្ធដោយភ្នាសមួយហៅថាភ្នាសពោះ ។

### មេរៀនសង្ខេប

- ប្រដាប់រំលាយអាហាររបស់មនុស្សមាន ធ្មេញ បំពង់រំលាយអាហារ និងក្រពេញរំលាយអាហារ ។
- មនុស្សពេញវ័យមានធ្មេញចំនួន 32 ចែកចេញជាបួនប្រភេទ គឺធ្មេញមុខ 2 ចង្កូម 1 ថ្គាមតូច 2 និងថ្គាមធំ 3 (ចំនួនធ្មេញពាក់កណ្តាលថ្គាម) ។
- បំពង់រំលាយអាហាររួមមានប្រហោងមាត់ ដើមក បំពង់អាហារ ក្រពះ ពោះវៀនតូច និងពោះវៀនធំ ។
- ក្រពេញរំលាយអាហារមានក្រពេញទឹកមាត់ ក្រពេញក្រពះ ក្រពេញពោះវៀន ថ្លើម និងលំពែង ។

## ? សំណួរ

1. ចូរដាក់ឈ្មោះប្រភេទផ្សេងៗរបស់ធ្មេញ ( រូបទី 1 )និងផ្នែកផ្សេងរបស់ធ្មេញ ( ក ខ គ)
2. ចូរដាក់ឈ្មោះផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារដែលតាងដោយលេខ 1 ដល់ 10 ( រូបទី 2)
3. តើធ្មេញទឹកដោះ និងធ្មេញស្រុកខុសគ្នាដូចម្ដេច ?
4. តើក្រពេញទឹកមាត់មានប៉ុន្មានក្រុម ? គឺអ្វីខ្លះ ?
5. តើក្រពេញនីមួយៗមាននាទីដូចម្ដេច ?
6. តើទឹកប្រមាត់ផលិតដោយសរីរាង្គអ្វី ?
7. ដូចម្ដេចហៅថាជំងឺខ្នែងពោះវៀន ?




រូបទី 1




រូបទី 2

មេរៀនទី

# 3 ការរំលាយអាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យការរំលាយអាហារនិងស្រូបអាហារ
- ❑ ប្រៀបធៀបការរំលាយអាហារបែបមេកានិចនិងគីមី
- ❑ ពណ៌នាពីដំណើររំលាយអាហារ
- ❑ រៀបរាប់ពីការប្រើប្រាស់អាហាររលាយនៅក្នុងសារពាង្គកាយ ។

កោសិកាមិនអាចប្រើប្រាស់អាហារដែលយើងបរិភោគភ្លាមៗបានទេ ។ តាមធម្មតាសារធាតុចិញ្ចឹមនៅក្នុងអាហារជាម៉ូលេគុលធំៗ ។ កោសិកាអាចចាប់យកសារធាតុចិញ្ចឹមទាំងនោះមកប្រើប្រាស់បាន លុះត្រាតែម៉ូលេគុលធំៗទាំងនោះត្រូវបានបំបែកទៅជាម៉ូលេគុលតូចនិងងាយសិន ។ លំនាំនៃការបំបែកម៉ូលេគុលនេះ ជាការរំលាយអាហារ ។

## 1. ការរំលាយអាហារបែបមេកានិចនិងគីមី

នៅក្នុងបំពង់រំលាយអាហារ ដុំអាហារត្រូវបានបំបែកតាមបែបមេកានិចនិងគីមី ។ ដំបូងដុំអាហារត្រូវបានកាត់ជាកំណាត់ៗ បន្ទាប់មកបំបែកជាភាគល្អិតៗ ដោយពុំមានការផ្លាស់ប្តូរធាតុគីមីរបស់វាឡើយ ។ ដំណើរនេះហៅថា ការរំលាយអាហារបែបមេកានិច ដែលធ្វើឡើងដោយធ្មេញនិងសាច់ដុំក្រពះ ។ បន្ទាប់មក ម៉ូលេគុលធំៗនៅក្នុងដុំអាហារត្រូវបានបំបែកជាម៉ូលេគុលតូចៗហើយងាយដោយការចូលរួមពីសារធាតុគីមី ។ ដំណើរនេះហៅថា ការរំលាយអាហារបែបគីមី ។ ការរំលាយអាហារបែបមេកានិចសម្រួលដល់ការរំលាយអាហារបែបគីមីឱ្យប្រព្រឹត្តទៅលឿន ។ ការរំលាយអាហារទាំងពីរបែបនេះ ប្រព្រឹត្តទៅរបៀបដូចគ្នា គឺបំបែកម៉ូលេគុលធំៗ ឱ្យទៅជាម៉ូលេគុលតូចៗនិងងាយសម្រាប់ ស្រូបរបស់កោសិកា ។




*រូបទី 3.1. ដំណើររំលាយអាហារ*

## 2. អាហារសំខាន់ទាំងបីក្រុម

អាហារភាគច្រើន ដែលមនុស្សបរិភោគស្ថិតនៅក្នុងក្រុមអាហារសំខាន់ទាំងបី ។ ក្រុមអាហារទាំងនេះមានប្រូតេអ៊ីន គ្លុយស៊ីត និងខ្លាញ់(លីពីត) ។ អាហារជាប្រូតេអ៊ីនមានសាច់សត្វ ត្រី ស៊ុត សណ្តែកសៀង... ។ អាហារជាគ្លុយស៊ីតមានបាយ ដំឡូង នំប៉័ង គ្រាប់ធញ្ញជាតិ... ។ អាហារភាគច្រើនជាខ្លាញ់ រួមមានប្រេងឆា ប្រេងដូង ខ្លាញ់សត្វ សណ្តែកដី... ។

ប្រដាប់រំលាយអាហារផលិតសារធាតុគីមីពិសេស ដែលជួយក្នុងដំណើរការរំលាយអាហារ ។ សារធាតុគីមីទាំងនេះហៅថា អង់ស៊ីមរំលាយអាហារ ។ អង់ស៊ីមទាំងនេះជំរុញល្បឿនប្រតិកម្មគីមីនៃដំណើរការបំបែកអាហារខុសៗគ្នាឱ្យទៅជាម៉ូលេគុលតូចៗងាយជ្រាបតាមភ្នាសពោះវៀនក្នុងរយៈពេលរំលាយអាហារ ។ អង់ស៊ីមមានច្រើនប្រភេទខុសៗគ្នា សម្រាប់បំបែកអាហារប្រភេទផ្សេងៗ ។ អង់ស៊ីមដែលបំបែកខ្លាញ់មិនបំបែកប្រូតេអ៊ីននិងគ្លុយស៊ីតទេ ។ ឯអង់ស៊ីមបំបែកប្រូតេអ៊ីនមិនបំបែកខ្លាញ់និងគ្លុយស៊ីតទេ មានន័យថា អង់ស៊ីមមានលក្ខណៈយថាប្រភេទ ។

## 3. ដំណើរការរំលាយអាហារ

នៅក្នុងប្រដាប់រំលាយអាហារ តើអាហារដែលយើងបរិភោគត្រូវបានបំបែកយ៉ាងដូចម្តេច ? អាហារដែលយើងបរិភោគ ត្រូវបានបំបែកជាដំណាក់ៗដូចខាងក្រោមនេះ ។

### 3.1. ក្នុងមាត់



រូបទី 3.2. មាត់

ការរំលាយអាហារចាប់ផ្តើមនៅក្នុងមាត់ ។ ធ្មេញមុខខាំផ្តាច់អាហាររឹង ។ ចង្កូមច្រៀកអាហារ ថ្គាមកិនលំអិត ។ សកម្មភាពទាំងនេះជួយឱ្យការរំលាយអាហារបានលឿននិងងាយស្រួល ។ នៅពេលយើងទំពាអាហារ ថ្គាមកិនលំអិតអាហារដែលផ្សើមដោយទឹកមាត់ធ្វើឱ្យអាហារសើមនិងទន់ ឯអណ្តាតក៏បង្វិលអាហារចុះឡើង ។ ទឹកមាត់មានផ្ទុកអង់ស៊ីមដែលបំបែកអាមីដុង (គ្លុយស៊ីត) នៅក្នុងដុំអាហារ ។ អាមីដុងនៅក្នុងអាហារដែលយើងបរិភោគចាប់ផ្តើមរំលាយទៅជាម៉ូលេគុលស្ករនៅក្នុងមាត់ ។ អណ្តាតលុញអាហាររំលាយខ្លះៗឱ្យទៅជាដុំអាហារតូចៗដែលត្រូវលេបចូលទៅក្នុងបំពង់អាហារ ។

## ៣.២. ក្នុងបំពង់អាហារ



រូបទី ៣.៣. បំពង់អាហារ

នៅក្នុងបំពង់អាហារពុំមានអង់ស៊ីមរំលាយអាហារទេ ។ សាច់ដុំបំពង់អាហារកន្ត្រាក់ហើយរលាជាញឹកញាប់ ។ លក្ខណៈទាំងនេះបង្កើតបានជាកម្លាំងមួយគ្រប់គ្រាន់សម្រាប់រុញអាហារឱ្យធ្លាក់ទៅក្នុងក្រពះ ។

## ៣.៣. ក្នុងក្រពះ



រូបទី ៣.៤. ក្រពះ

ក្រពះផលិតអាស៊ីត និងអង់ស៊ីម ។ នៅពេលអាហារចូលដល់ក្នុងក្រពះវាលាយជាមួយអាស៊ីតនិងអង់ស៊ីម ។ ក្រពះចាប់ផ្ដើមច្របាច់អាហារហើយដុំអាហារធ្វើចលនាវិលចុះវិលឡើង ។មានតែប្រូតេអ៊ីននៅក្នុងអាហារតែប៉ុណ្ណោះដែលត្រូវបានបំបែកនៅក្នុងក្រពះ ។ ចំណែកអាមីដុងនិងខ្លាញ់មិនបំបែកនៅក្នុងក្រពះទេ ។ បន្ទាប់មកអាហារចាកចេញពីក្រពះមានសភាពជាធាតុរាវខាប់ ។ វាហូរចូលទៅក្នុងពោះវៀនតូចក្នុងរយៈពេលដ៏ខ្លី ។

## ៣.៤. ក្នុងពោះវៀនតូច

អាហារមួយចំនួនមាននៅក្នុងពោះវៀនតូច ។ អាហារនៅសល់ ដែលមិនទាន់បានបំបែកនិងត្រូវបំបែកនៅទីនោះ ។ ម៉ូលេគុលធំៗរបស់អាមីដុង ប្រូតេអ៊ីន និងខ្លាញ់ត្រូវបានបំបែកយ៉ាងពេញលេញនៅក្នុងពោះវៀនតូច :

- អាមីដុង បំបែកជា ស្ករងាយ
- ប្រូតេអ៊ីន បំបែកជា អាស៊ីតអាមីនេ
- ខ្លាញ់ បំបែកជា អាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល ។

ថ្លើមផលិតធាតុរាវពណ៌បៃតងហៅថា ***ទឹកប្រមាត់*** ។ ទឹកប្រមាត់ស្តុកទុកក្នុងថង់ប្រមាត់ មុននិងវាត្រូវបានបញ្ចេញទៅក្នុងពោះវៀនតូច ។ ទឹកប្រមាត់ចូលរួមក្នុងការបំបែកខ្លាញ់ ។ លំពែងបញ្ចេញអង់ស៊ីមរំលាយអាហារ(រសលំពែង)ទៅក្នុងពោះវៀនតូច ដែលជួយក្នុងការបំបែកគ្លុយស៊ីត ខ្លាញ់ និងប្រូតេអ៊ីន ។

## ៣.៥. ក្នុងពោះវៀនធំ



រូបទី ៣.៥. ពោះវៀនធំ

អាហារដែលមិនអាចបំបែកបានឆ្លងកាត់តាមបណ្តោយពោះវៀនធំ ។ ទឹកភាគច្រើន និងអំបិលខនិជត្រូវបានជ្រាបចេញពីពោះវៀនធំ ។ រូបធាតុ

ដែលមិនបំបែក ឬមិនជ្រាបចេញក្លាយទៅជាកាកសំណល់ស្ទើររឹង ហៅថាលាមក ។ លាមកធ្លាក់ចូលទៅក្នុងចុងពោះវៀន ។

លាមកស្តុកទុកជាបណ្តោះអាសន្ននៅក្នុងចុងពោះវៀន រហូតដល់វាត្រៀមចាកចេញក្រៅសារពាង្គកាយតាមទ្វារធំ ។

# 4. សម្រូបអាហារ

សារធាតុចិញ្ចឹមដែលប្រើប្រាស់ដោយកោសិកានៃសារពាង្គកាយ ត្រូវបានឆ្លងកាត់តាមភ្នាសកោសិកា ។ ជាការពិតណាស់ អាហារទាំងអស់នៅក្នុងពោះវៀនតូចត្រូវបានបំបែក ។ ប្រូតេអ៊ីនបំបែកជាអាស៊ីតអាមីនេ ។ អាមីដុងបំបែកជាស្ករងាយ ។ ខ្លាញ់បំបែកជាអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ។ តែទោះបីជាយ៉ាងណាក៏ដោយ សារធាតុចិញ្ចឹមទាំងនេះអាចប្រើប្រាស់ជាថាមពលសម្រាប់កោសិកាបាន ដំបូងវាត្រូវតែស្រូបចូលទៅក្នុងឈាមតាមភ្នាសពោះវៀនតូច ។

## 4.1. ជម្រាបក្នុងពោះវៀនតូច

នៅក្នុងអាហាររលាយ សារធាតុចិញ្ចឹមទាំងអស់ឆ្លងកាត់តាមផ្ទៃភ្នាសពោះវៀនតូច ។ បាតុភូតនេះហៅថា ***សម្រូបអាហារ*** ។ ពោះវៀនតូចមានប្រវែងប្រហែល 7m ។ ផ្ទៃខាងក្នុងពោះវៀនតូចមានពកតូចៗរាប់លានហៅថា ***ជ្រាំងពោះវៀន*** ។ ជ្រាំងពោះវៀននីមួយៗមានប្រវែង 0.5mm ។ ជម្រាបធ្វើឡើងតាមរយៈជ្រាំងពោះវៀន ។ អាហាររលាយជ្រាបតាមជ្រាំងពោះវៀន ហើយចូលទៅក្នុងបណ្តាញសរសៃឈាមដែលដឹកនាំសារធាតុចិញ្ចឹមទៅគ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ ។ ជ្រាំងពោះវៀននេះបង្កើនទំហំផ្ទៃពោះវៀនតូច ដើម្បីជួយសម្រួលសម្រូបអាហាររលាយ ។




*រូបទី 3.6. ជម្រាបក្នុងពោះវៀនតូច*

ជ្រាំងពោះវៀនកើតឡើងពីកោសិកាស្រាស់តែមួយស្រទាប់ដែលអាចឱ្យអាហាររលាយឆ្លងកាត់យ៉ាងងាយ ។ ក្នុងពោះវៀនមានបណ្តាញសរសៃឈាម ដែលដឹកនាំឈាម និងមានសរសៃទឹករងៃដែលដឹកនាំទឹករងៃ ។




*រូបទី 3.7. ខ្ទាត់ជ្រាំងពោះវៀនតូច*

### 4.2. ជម្រាបក្នុងពោះវៀនធំ

អាហារមិនរលាយចូលក្នុងពោះវៀនធំ មានសភាពជាល្បាយរាវ ។ នាទីសំខាន់របស់ពោះវៀនធំគឺស្រូបយកទឹកពីអាហារមិនរលាយ ។ ដូចនេះបរិមាណទឹកយ៉ាងច្រើនត្រូវបានត្រឡប់ចូលទៅក្នុងសារពាង្គកាយវិញ ដើម្បីរក្សាថេរលំនឹង ។ អាហារមិនរលាយទាំងនេះស្ថិតនៅក្នុងពោះវៀនធំយ៉ាងយូរបីថ្ងៃ ។ ក្រោយពីស្រូបយកទឹកដែលលើសអស់ហើយ រូបធាតុនៅសល់មិនរលាយក្លាយជារឹង ។

បាក់តេរីដែលរស់នៅក្នុងពោះវៀនធំ ចិញ្ចឹមជីវិតដោយរូបធាតុមិនរលាយ ដូចជាសែលុយឡូសជាដើម ។ នេះជាទំនាក់ទំនងសហប្រាណ ។ បាក់តេរីចិញ្ចឹមជីវិតដោយកាកសំណល់ ដូចជាសែលុយឡូស ហើយផលិតវីតាមីនមួយចំនួន ដូចជាវីតាមីន K និងវីតាមីន B កុំផ្លិចដែលយើងត្រូវការ ។ សាច់ដុំនៃចុងពោះវៀន និងទ្វារធំត្រួតពិនិត្យការបញ្ចេញកាកសំណល់រឹងពីសារពាង្គកាយក្រោមទម្រង់ជាលាមក ។

## 5. ការប្រើប្រាស់អាហាររលាយ

ម៉ូលេគុលអាហាររលាយត្រូវបានជ្រាបចូលទៅក្នុងសរសៃឈាមនៃពោះវៀនតូច ។ ចេញពីពោះវៀនតូច ជាដំបូងឈាមហូរទៅកាន់ថ្លើម ។

- ស្ករងាយ : នៅក្នុងឈាមស្ករធ្វើដំណើរទៅសាច់ដុំ ដើម្បីផ្តល់ថាមពល ។ ស្ករលើសត្រូវស្តុកទុកនៅក្នុងថ្លើមក្រោមទម្រង់ជាគ្លីកូសែន ។
- អាស៊ីតអាមីនេ : នៅក្នុងឈាម អាស៊ីតអាមីនេធ្វើដំណើរទៅកាន់សរីរាង្គផ្សេងៗដើម្បីបង្កើតប្រូតេអ៊ីនសម្រាប់ការលូតលាស់និងជួសជុល ។ អាស៊ីតអាមីនេខ្លះទៀតស្ថិតនៅក្នុងថ្លើម បង្កើតប្រូតេអ៊ីននៅក្នុងឈាម ។ ***ឧទាហរណ៍*** ភីប្រីណូសែនសម្រាប់កំណកឈាម ។ អាស៊ីតអាមីនេលើសត្រូវបានបំបែក ហើយផ្តល់ជាថាមពល ។
- វីតាមីន ស្តុកទុកក្នុងថ្លើម និងបញ្ចេញទៅក្នុងឈាមនៅពេលត្រូវការ ។

## 6. នាទីរបស់ថ្លើម

ថ្លើម ជាសរីរាង្គធំជាងគេនៅក្នុងសារពាង្គកាយ ។ វាមាននាទីពិសេសច្រើនយ៉ាងសម្រាប់សុខភាព និងជីវិត ។ ដោយហេតុនេះហើយ ថ្លើមត្រូវបានផ្គត់ផ្គង់ឈាមច្រើនជាងផ្នែកផ្សេងៗទៀតនៃសារពាង្គកាយ ។ ថ្លើមទទួលឈាមពីប្រភពសំខាន់ពីរ ។ មួយផ្នែកបានពីបេះដូងនិងមួយផ្នែកទៀតបានមកពីប្រដាប់រំលាយអាហារដែលឈាមសម្បូរដោយអាហាររលាយ ។

- ថ្លើមផលិតទឹកប្រមាត់ដែលចូលរួមក្នុងការរំលាយខ្លាញ់ក្នុងអាហារ
- ថ្លើមត្រួតពិនិត្យជាតិស្ករនៅក្នុងឈាម
- ថ្លើមបំបាត់ជាតិពុលនៅក្នុងឈាម
- ថ្លើមស្តុកជាតិដែក
- ថ្លើមស្តុកវីតាមីន ។ វីតាមីន A និង D ស្តុកទុកក្នុងថ្លើមរហូតដល់សារពាង្គកាយត្រូវការវា ។
- ថ្លើមផលិតប្រូតេអ៊ីនប្លាស្មាដូចជាភីប្រីណូសែន
- ថ្លើមផលិតកម្តៅ ។

## មេរៀនសង្ខេប

- ការរំលាយអាហារជាការបំបែកម៉ូលេគុលធំនៃអាហារឱ្យទៅជាម៉ូលេគុលតូចដែលអាចជ្រាបបាន ។ ដំណើរនេះត្រូវបានបង្កើនល្បឿនដោយសារអង់ស៊ីមរំលាយអាហារ ។
- ការរំលាយអាហារបែបមេកានិចកើតមានឡើង ពេលណាអាហារត្រូវបំបែកតាមការលំអិតរបស់ធ្មេញ និងចលនាកញ្ច្រោលរបស់បំពង់រំលាយអាហារ ។
- បំលែងអាហារទៅជាសារធាតុងាយដោយសារអង់ស៊ីមហៅថា ***ការរំលាយអាហារបែបគីមី*** ។
- ការរំលាយអាហារចាប់ផ្តើមនៅក្នុងមាត់ និងបញ្ចប់នៅក្នុងពោះវៀនតូច ។
- ម៉ូលេគុលតូចៗនៃអាហាររលាយនៅក្នុងពោះវៀនតូច ហើយជ្រាបចូលទៅក្នុងប្រព័ន្ធសរសៃឈាមរបស់ពោះវៀនតូច ។

## ? សំណួរ

1. ដូចម្តេចហៅថាការរំលាយអាហារ ?
2. តើការរំលាយអាហារមានប៉ុន្មានបែប ? អ្វីខ្លះ ?
3. តើអាហារសំខាន់បីក្រុមដែលត្រូវរំលាយមានអ្វីខ្លះ ?
4. តើសារធាតុគីមីដែលជួយរំលាយអាហារឈ្មោះអ្វី ?
5. តើអាហារប្រភេទណាដែលត្រូវបំបែកនៅក្នុងមាត់ ?
6. តើបំពង់អាហារមានអង់ស៊ីមដែរឬទេ ? តើវាមាននាទីអ្វី ?
7. តើទឹកប្រមាត់ផលិតនៅកន្លែងណា ? តើវាមាននាទីអ្វី ?
8. តើថ្លើមមាននាទីអ្វីខ្លះ ?

# 4 ជំងឺនិងអនាម័យប្រដាប់រំលាយអាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីមូលហេតុដែលធ្វើឱ្យធ្មេញខូច
- ❑ ពណ៌នាពីអនាម័យផ្សេងៗដែលធ្វើឱ្យប្រដាប់រំលាយអាហារមានសុខភាពល្អ
- ❑ រៀបរាប់ពីជំងឺឆ្លងតាមផ្លូវរំលាយអាហារមួយចំនួន ។

ដើម្បីឱ្យប្រដាប់រំលាយអាហារមានសុខភាពល្អ យើងចាំបាច់ត្រូវអនុវត្តនូវអនាម័យនៃប្រដាប់រំលាយអាហារ ។

## 1. អនាម័យធ្មេញ

### 1.1. តម្រូវការធ្មេញល្អ

ធ្មេញដុះល្អ នាំឱ្យយើងទំពាអាហារបានល្អិត ។ ការរំលាយអាហារឱ្យសព្វ ហើយយឺតៗមានសារៈសំខាន់ណាស់ ព្រោះវាជួយសម្រួលការរំលាយអាហារបែបមេកានិចនៅក្នុងក្រពះ និងពោះវៀន ។ ការទំពាអាហារខ្ជីខ្ជា នាំឱ្យប្រដាប់រំលាយអាហារធ្វើការច្រើននិងហត់ខ្លាំងដែលបណ្ដាលឱ្យឈឺក្រពះ និងពោះវៀន ។ ធ្មេញមិនល្អនិងបណ្ដាលឱ្យមានការឈឺចាប់ ហើយទំពាអាហារមិនបានម៉ដ្ឋល្អ ដែលបណ្ដាលឱ្យខូចសុខភាព ។

### 1.2. មូលហេតុនៃការធ្មេញខូច

ធ្មេញខូចបណ្ដាលមកពីមូលហេតុពីរយ៉ាង :

- ទឹកមាត់មានសារធាតុដែលធ្វើឱ្យក្លាំងជើងធ្មេញ ។ ក្លាំងជើងធ្មេញជាកន្លែងដែលមេរោគស្ថិតនៅហើយបណ្ដាលឱ្យហើមជើងធ្មេញ ។ ក្រៅពីនេះការប្រែប្រួលយ៉ាងឆាប់រហ័សនៃសីតុណ្ហភាព (ទឹកកកឬទឹកក្ដៅ) ឬអំពើមេកានិច (ខាំវត្ថុរឹងខ្លាំង) ក៏បណ្ដាលឱ្យប្រេះកាចាធ្មេញនិងនាំឱ្យធ្មេញខូចបានដែរ ។
- បាក់តេរីនៅក្នុងមាត់បំប្លែងជាតិស្ករដែលមានក្នុងកម្ទេចអាហារឱ្យទៅជាអាស៊ីត ។ អាស៊ីតនេះស៊ីកាចាធ្មេញនិងភ្លុកធ្មេញ ហើយបង្កើតបានជាប្រហោងមួយ ។ កាលណាប្រហោងនេះធ្លុះដល់សរសៃប្រសាទនៅក្នុងបណ្ដូលធ្មេញ យើងនឹងមានការឈឺចាប់យ៉ាងខ្លាំង ។ ប្រសិនបើយើងព្យាបាលមិនទាន់ វានឹងបណ្ដាលឱ្យមានខ្ទុះនៅផ្នែកខាងចុងនៃឫសធ្មេញ ឬរលាកឆ្អឹងថ្គាម ។

### 1.3. ការថែរក្សាធ្មេញ

ដើម្បីថែរក្សាធ្មេញឱ្យបានល្អយើងត្រូវ :

- ដុសធ្មេញនិងប្រាសដុសធ្មេញយ៉ាងតិចពីរដងក្នុងមួយថ្ងៃ បន្ទាប់ពីបរិភោគអាហាររួច ។
- កុំផឹកភេសជ្ជៈដែលមានជាតិស្កររៀងរាល់ថ្ងៃ ។
- ហាមកុមារកុំឱ្យបរិភោគស្ករច្រើនពេក ។
- ទម្លាប់កុំឱ្យក្មេងចាក់ធ្មេញនិងឈើចាក់ធ្មេញ ។
- ទៅពិនិត្យធ្មេញនៅមន្ទីរពេទ្យរាល់ប្រាំមួយខែម្តង ។

## 2. ការថែរក្សាប្រដាប់រំលាយអាហារ

ដើម្បីថែរក្សាប្រដាប់រំលាយអាហារប្រកបដោយសុខភាពល្អ យើងត្រូវ :

- បរិភោគអាហារច្រើនប្រភេទនិងមានរសជាតិឆ្ងាញ់ ហើយរបបអាហារនោះត្រូវមានខ្លាញ់តិច និងសែលុយឡូសច្រើន ។ បរិភោគអាហារឱ្យទៀងទាត់ ។
- បរិភោគតាមសម្រួលកុំប្រញាប់ ហើយប្រកបដោយអារម្មណ៍ល្អ ។
- បរិភោគឱ្យល្មម គឺមិនត្រូវបរិភោគតាមការស្រេកឃ្លានទេ ។
- ពិសាភេសជ្ជៈតិចតួចក្នុងពេលបាយ ព្រោះភេសជ្ជៈនិងទឹកធ្វើឱ្យរសរំលាយអាហាររាវនិងបន្ថយសកម្មភាពរបស់វា ។ សុរា ថ្នាំជក់បង្អន់អំពើរបស់រសទឹកមាត់និងរសក្រពះ ។
- សម្រាកបន្តិចក្រោយពេលបរិភោគបាយរួច ។
- បន្ទោបង់លាមករាល់ថ្ងៃឱ្យទៀងពេល ព្រោះការទល់លាមកបណ្តាលឱ្យមានការពុលខ្លួនទៅតែត្រូវចៀសវាងកុំប្រើថ្នាំបញ្ចុះច្រើនពេក ។

## 3. ជំងឺផ្លូវតាមផ្លូវរំលាយអាហារ

### 3.1. ជំងឺរាក

ជំងឺនេះសំគាល់ឡើងដោយការចុះរាកច្រើនដងក្នុងមួយថ្ងៃ ។ ជំងឺនេះបណ្តាលមកពីការប្តូររបបអាហារ ការពុលអាហារ ឬការបរិភោគច្រើនហួស ។ ជំងឺរាក គឺអាចបណ្តាលមកពីអាមីបដែរ ។ នៅពេលរាក ទឹកមិនបានជ្រាបចូលទៅក្នុងសរសៃឈាមទេ វាអាចបណ្តាលឱ្យអ្នកជំងឺមានការបាត់បង់ទឹកយ៉ាងច្រើនពីសារពាង្គកាយ ។ ដើម្បីការពារការបាត់បង់ទឹក អ្នកជំងឺត្រូវផឹកទឹកឱ្យបានច្រើន ។

### 3.2. ជំងឺរលាកថ្លើម

ជំងឺរលាកថ្លើមបណ្តាលមកពីវីរុស ។ ជំងឺរលាកថ្លើម ដែលគេច្រើនជួបប្រទះសព្វថ្ងៃនេះមានបីប្រភេទ : រលាកថ្លើមប្រភេទ A ប្រភេទ B និងប្រភេទ C ។

វីរុសជំងឺរលាកថ្លើមប្រភេទ A ឆ្លងច្រើនជាងគេ ។ វាឆ្លងតាមរយៈអាហារដែលលាងមិនបានស្អាតល្អ តាមការប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ ឬប្រើទឹកដែលមានមេរោគរលាកថ្លើម ។ ក្រោយពេលបង្ករោគលើសពី 45 ថ្ងៃទៅ អ្នកជំងឺមានរោគសញ្ញាដូចជា ឈឺក្បាល គ្រុនក្តៅ បាត់បង់រសជាតិ ហើយស្បែកនិងប្រស្រីភ្នែកឡើងពណ៌លឿង ។ អ្នកជំងឺជៀសវាងបរិភោគអាហារមានខ្លាញ់ច្រើន ហើយសម្រាកឱ្យបានគ្រប់គ្រាន់ ។

រលាកថ្លើមប្រភេទ B និង C ឆ្លងតាមរយៈឈាម ដោយការបញ្ចូលឈាមដែលមានមេរោគរលាកថ្លើម B ឬ C តាមការប្រើម្ជុលចាក់ថ្នាំមិនស្អាត ឬប្រើឧបករណ៍សម្រាប់វះកាត់ ឬដកធ្មេញមិនបានរំងាប់មេរោគ ។ ជំងឺនេះក៏ឆ្លងតាមការរួមភេទផងដែរ ។

### 3.3. ជំងឺទល់លាមក

ជំងឺទល់លាមក ជាជំងឺដែលលាមកក្លាយជារឹងស្ងួត ហើយពោះវៀនពិបាកធ្វើចលនា ។ ប្រសិនបើលាមកស្ថិតនៅក្នុងពោះវៀនរយៈពេលយូរ ទឹកនឹងជ្រាបចេញពីវាយ៉ាងច្រើន ។ រោគទល់លាមកបណ្តាលមកពីកង្វះជាតិសរសៃលុយខ្សូសក្នុងរបបអាហារ ការទម្លាប់បរិភោគមិនទៀងទាត់ ការផឹកទឹកតិចពេក កង្វះលំហាត់ប្រាណ ឬការប្រើថ្នាំបញ្ចុះជានិច្ចកាល ។ ការបរិភោគអាហារមានតុល្យភាព ការផឹកទឹកច្រើន ការធ្វើលំហាត់ប្រាណទៀងទាត់ជាវិធីល្អដើម្បីជៀសវាងរោគទល់លាមក ។

## 4. តម្រូវការអាហារ

សារពាង្គកាយត្រូវការរៀងរាល់ថ្ងៃនូវប្រភេទអាហារសំខាន់ៗសម្រាប់សុខភាព ។ អាហារទាំងនោះមាន :

- អាហារផ្តល់ថាមពល : គ្លុយស៊ីត ប្រូទីត ខ្លាញ់ ។
- អាហារមិនផ្តល់ថាមពល ប៉ុន្តែចាំបាច់សម្រាប់សុខភាព : ទឹក អំបិលខនិជ វីតាមីន សែលុយឡូស ។

អាហារប្រភេទខុសៗគ្នាទាំងនេះ ត្រូវតែមានក្នុងបរិមាណសមស្រប ។ ប្រសិនបើមិនដូច្នោះទេ វានឹងនាំមកនូវវិបត្តិចំណីអាហារ ។ ការបរិភោគអាហារមួយប្រភេទច្រើនហួសហេតុ គេសង្កេតឃើញមានវិបត្តិលើសអាហារ ។ ការបរិភោគអាហារមួយប្រភេទតិចហួសហេតុ គេសង្កេតឃើញមានវិបត្តិកង្វះអាហារ ។

## 4.1. វិបត្តិលើសអាហារ

***ឧទាហរណ៍ :*** អាហារដែលមានជាតិខ្លាញ់ច្រើនហួស មិនរំលាយបានទេ ។ ប្រសិនបើអាហារមានប្រូទីតច្រើនហួស ថ្លើមនិងតម្រងនោមមានការនឿយហត់ អុយរ៉េកើនឡើងក្នុងឈាមហើយអាស៊ីតអ៊ុយរិចនិងមានក្នុងសន្លាក់ ។

## 4.2. វិបត្តិកង្វះអាហារ

មនុស្សម្នាក់ត្រូវការយ៉ាងតិចប្រូទីត 1g ក្នុងមួយថ្ងៃសម្រាប់ទម្ងន់ខ្លួន 1Kg ។ (ចំពោះយុវជនត្រូវការ 1.5g ទៅ 2g ) ។ មនុស្សពេញវ័យទម្ងន់ 40Kg ត្រូវបរិភោគប្រូទីត 60g រៀងរាល់ថ្ងៃ ។ យើងសង្កេតឃើញថា ការបរិភោគច្រើនហួស វាគ្មានផ្តល់ផលប្រយោជន៍អ្វីទេ ។ ប៉ុន្តែប្រសិនបើកង្វះប្រូតេអ៊ីន វានិងបង្អាក់ការលូតលាស់និងមិនអាចជួសជុលកន្លែងខូចខាតបានទេ ។

តម្រូវការជាតិខ្លាញ់ 0.6g ក្នុងទម្ងន់ខ្លួន 1Kg សម្រាប់មួយថ្ងៃ ។

**មេរៀនសង្ខេប**

- ធ្មេញខូចបណ្តាលមកពីក្តាំងដើងធ្មេញ បម្រែបម្រួលសីតុណ្ហភាពរហ័សពេកនៃអាហារដែលបរិភោគ បាក់តេរីក្នុងមាត់បំប្លែងជាតិស្ករក្នុងកម្ទេចកម្ទីអាហារឱ្យទៅជាអាស៊ីតដែលស៊ីកាចាធ្មេញ ។
- ការរំលាយអាហារប្រព្រឹត្តទៅល្អប្រសើរអាស្រ័យនិងធ្មេញល្អ ចំណីអាហារមានរសជាតិឆ្ងាញ់ការទំពាយឺតៗហើយម៉ដ្ឋ ចេះប្រមាណក្នុងការបរិភោគ បរិភោគអាហារឱ្យទៀងទាត់ពេល ។
- ជំងឺដែលឆ្លងតាមផ្លូវរំលាយអាហារមានជំងឺរាក ជំងឺរលាកថ្លើម ជំងឺទល់លាមកជាដើម ។

## ? សំណួរ

1. តើធ្មេញខូចបណ្តាលមកពីអ្វី ?
2. តើយើងធ្វើដូចម្តេច ដើម្បីថែរក្សាធ្មេញកុំឱ្យខូច ?
3. តើជំងឺអ្វីខ្លះដែលទាក់ទងនិងផ្លូវរំលាយអាហារ ?
4. ដើម្បីឱ្យប្រដាប់រំលាយអាហារមានសុខភាពល្អ តើយើងត្រូវធ្វើដូចម្តេច ?
5. តើអាហារអ្វីខ្លះដែលយើងត្រូវបរិភោគរាល់ថ្ងៃ ?
6. ដូចម្តេចហៅថាវិបត្តិលើសអាហារ ?
7. តើវិបត្តិកង្វះអាហារបណ្តាលមកពីអ្វី ?

## ? សំណួរនិងលំហាត់ជំពូក 4

I. ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. អាហារធ្វើចលនាពីមាត់ទៅក្រពះតាម :

☐ ក. លំពែង ☐ ខ. ពោះវៀនតូច ☐ គ. ពោះវៀនធំ ☐ ឃ. បំពង់អាហារ ។

2. គុយស៊ុត(អាមីដុង) បំបែកទៅជាគឺ :

☐ ក. ស្ករងាយ ☐ ខ. អាស៊ីតអាមីនេ ☐ គ. គ្លីកូសែន ☐ ឃ. លាមក ។

3. អាហាររលាយទាំងអស់ត្រូវបានជ្រាបចូលតាមភ្នាស ៖

☐ ក. មាត់ ☐ ខ. ក្រពះ ☐ គ. ពោះវៀនតូច ☐ ឃ. ពោះវៀនធំ ។

4. ជំងឺដែលឆ្លងតាមប្រដាប់រំលាយអាហារគឺ :

☐ ក. គ្រុនផ្តាសាយ ☐ ខ. គ្រុនឈាម ☐ គ. អេដស៍ ☐ ឃ. ថ្លើម ។

II. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

1. លំនាំនៃការបំបែកអាហារឱ្យទៅជាម៉ូលេគុលល្អិតៗ និងងាយហៅថា . . . . . . ។
2. សារធាតុគីមីដែលចូលរួមក្នុងការរំលាយអាហារហៅថា . . . . . . ។
3. ការទំពាលំអិតអាហារដោយធ្មេញជា . . . . . . . . . . ។
4. លាមកត្រូវបានស្តុកទុកជាបណ្តោះអាសន្ននៅក្នុង . . . . . . . ។

III. ចូរឆ្លើយសំណួរខាងក្រោម

1. តើអង់ស៊ីមទឹកមាត់បំបែកអាហារប្រភេទណាមួយ ?
2. តើនាទីសំខាន់របស់ពោះវៀនធំជាអ្វី ?
3. តើសារធាតុគីមីអ្វីខ្លះដែលមាននៅក្នុងក្រពះ ?
4. តើទឹកមាត់ទាក់ទងទៅនិងការរំលាយអាហារបែបមេកានិច ឬបែបគីមី ? ចូរពន្យល់ ។
5. ប្រសិនបើគ្មានសន្ទះខ្យល់ តើនឹងមានអ្វីកើតឡើងនៅពេលលេបអាហារ ?
6. មនុស្សម្នាក់អាចរស់បានដោយគ្មានប្រមាត់ ប៉ុន្តែគេមិនអាចរស់បានដោយគ្មានថ្លើមទេ ។ ហេតុអ្វី ?
7. អំពើរបស់ទឹកប្រមាត់មានលក្ខណៈស្រដៀងគ្នានិងទឹកសាប៊ូ ។ ចូរពន្យល់ពីសកម្មភាពរបស់ទឹកប្រមាត់ទៅលើខ្លាញ់នៅក្នុងការរំលាយអាហារ ។
8. ហេតុអ្វីបានជាយើងត្រូវទំពាអាហារឱ្យល្អិតជាចាំបាច់ ?

# ជំពូក 5 អាល់កុលនិងថ្នាំជក់




រូបភាពខាងលើនេះបង្ហាញពីហាងលក់គ្រឿងភេសជ្ជៈផ្សេងៗនិងបារី ។ គ្រឿងភេសជ្ជៈទាំងនេះភាគច្រើនជាគ្រឿងស្រវឹងដូចជា ស្រាក្រហម ស្រាបៀ ស្រាទំពាំងបាយជូរ... ។ គ្រឿងស្រវឹងនិងបារី មានផ្ទុកសារធាតុគីមីពុលដែលបណ្ដាលឱ្យខូចសុខភាព ។

# 1 ថ្នាំ

**ចប់មេរៀននេះ សិស្សអាច**

- ❑ កំណត់និយមន័យពាក្យ " ថ្នាំ"
- ❑ បែងចែកថ្នាំស្របច្បាប់ និងថ្នាំខុសច្បាប់
- ❑ រៀបរាប់អំពីផលវិបាកនៃការប្រើឱសថខុស
- ❑ អនុវត្តតាមបម្រាប់សុវត្ថិភាពនៃការប្រើប្រាស់ឱសថ ។

ថ្នាំជាសារធាតុគីមីផ្សេងពីអាហារ ។ នៅពេលវាចូលក្នុងសារពាង្គកាយ វាធ្វើឱ្យមានការប្រែប្រួលនៅក្នុងខ្លួន ។ ***ឧទាហរណ៍*** កាលណាយើងលេបថ្នាំងុយដេក វាធ្វើឱ្យយើងងងុយដេក ។ ប៉ុន្តែបើយើងផឹកតែ ឬកាហ្វេ វាធ្វើឱ្យយើងដេកមិនលក់ ។ កាហ្វេនិងតែមានផ្ទុកជាតិកាហ្វេអ៊ីនដែលមានឥទ្ធិពលទៅលើសកម្មភាពរបស់បេះដូងនិងខួរក្បាល ។ ថ្នាំជក់ក៏មានផ្ទុកសារធាតុម្យ៉ាងដែលមានឥទ្ធិពលទៅលើប្រព័ន្ធប្រសាទដែរ ។

## 1. ប្រភេទថ្នាំផ្សេងៗ

ជាទូទៅថ្នាំមានពីរប្រភេទ គឺថ្នាំស្របច្បាប់ និងថ្នាំខុសច្បាប់ ។ ***ឧទាហរណ៍*** ឱសថ ស្រា បារី ជាថ្នាំស្របច្បាប់ ។ កញ្ឆា អាភៀន ជាថ្នាំមិនស្របច្បាប់ ។ ស្រា បារី កញ្ឆា អាភៀន ជាគ្រឿងញៀន ។

### 1.1. ថ្នាំស្របច្បាប់




*រូបទី1.1. ឱសថប្រើប្រាស់ក្នុងវិស័យសុខាភិបាលសម្រាប់ព្យាបាលជំងឺ*



*រូបទី1.2. នីកូទីនជាជាតិញៀនដែលមាននៅក្នុងបារីនិងថ្នាំជក់*




រូបទី1.3. ស្រាប្រភេទផ្សេងៗ

- អាល់កុលជាថ្នាំដែលធ្វើឱ្យញៀន ។
- អាល់កុលមាននៅក្នុងស្រាបៀ ស្រាក្រហម ស្រាថ្នាំ . . . ។

## 1.2. គ្រឿងញៀន

បារី ស្រា កញ្ឆា អាភៀន ជាគ្រឿងញៀន ។ មនុស្សដែលប្រើប្រាស់គ្រឿងញៀនទាំងនេះនឹងទៅជាមនុស្សញៀន ។ មនុស្សញៀនមិនអាចបំពេញការងារបានត្រឹមត្រូវទេ នៅពេលដែលគេមិនបានប្រើថ្នាំញៀនឱ្យបានទៀងទាត់ ។




រូបទី1.4. គ្រឿងញៀន

## 1.3. ផលិតផលកែច្នៃ

ថ្នាំជក់ត្រូវបានគេយកទៅកែច្នៃជារូបភាពផ្សេងៗជាច្រើនដូចជា បារីឬថ្នាំសម្រាប់ខ្សៀ ។ លើសពីនេះយើងឃើញមានថ្នាំជក់ដែលគេផលិតសម្រាប់ចុកផងដែរ ។ ប៉ុន្តែទោះបីជាផលិតផលបែបណាក៏ដោយ ក៏វាផ្តល់នូវគ្រោះថ្នាក់ដល់សុខភាពដូចគ្នា ។

ក៏ដូចជាថ្នាំជក់ដែរ ស្រាត្រូវបានកែច្នៃជាច្រើនរូបភាពដែរដូចជា ស្រាស ស្រាបៀ ស្រាថ្នាំ ស្រាក្រហមជាដើម ។



រូបទី1.5. ផលិតផលកែច្នៃពីថ្នាំជក់

## 2. ឱសថប្រើប្រាស់ផ្នែកសុខាភិបាល

ឱសថ ឬថ្នាំពេទ្យជាប្រភេទមួយនៃថ្នាំដែលប្រើប្រាស់សម្រាប់ការពារសុខភាព ។ ជាទូទៅឱសថចែកចេញជាបីក្រុមអាស្រ័យទៅនឹងឥទ្ធិពលរបស់វានៅលើរាងកាយ ។ ឱសថដែលគេប្រើប្រាស់យ៉ាងទូលំទូលាយមានដូចខាងក្រោម ។

### 2.1. ឱសថបន្ធូរបន្ថយការឈឺចាប់

ថ្នាំពេទ្យខ្លះប្រើសម្រាប់បន្ថយការឈឺចាប់ ។ ***ឧទាហរណ៍*** នៅពេលគ្រុន យើងប្រើឱសថដែលអាចបន្ថយការឈឺក្បាល បញ្ឈប់ការហៀរសំបោរនិងក្អក ។ ថ្នាំអាចជាថ្នាំទឹក (ស៊ីរ៉ូក្អក) ថ្នាំគ្រាប់ ថ្នាំម្សៅ និងថ្នាំចាក់ ។




រូបទី1.6. ថ្នាំផ្តាសាយនិងស៊ីរ៉ូក្អក

### 2.2. ឱសថប្រឆាំងនឹងមេរោគ

ថ្នាំខ្លះប្រើសម្រាប់ព្យាបាលជំងឺ ។ អង់ទីប្យូទិចជាសារធាតុគីមីដែលសម្លាប់ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបង្កជំងឺជាច្រើន ។ អង់ទីប្យូទិចផលិតចេញពីបាក់តេរី ផ្សិត និងរុក្ខជាតិមួយចំនួន ។ អង់ទីប្យូទិចដែលគេប្រើប្រាស់ច្រើនជាងគេមានប៉េនីស៊ីលីននិងតេត្រាស៊ីគ្លីន ។ គេប្រើវាព្យាបាលជំងឺរលាកសួត ឈឺបំពង់កជាដើម ។



រូបទី1.7. ថ្នាំអង់ទីប្យូទិច

### 2.3. ឱសថបង្ការជំងឺ

វ៉ាក់សាំងជាសូលុយស្យុងដែលផ្ទុកមេរោគងាប់ឬខ្សោយ ។ វ៉ាក់សាំងផ្តល់ភាពស៊ាំសកម្មឱ្យយើង ដើម្បីទប់ទល់នឹងមេរោគដែលចូលមកយាយីខ្លួនយើង ។ ***ឧទាហរណ៍*** មេរោគបង្កជំងឺគ្រុនស្វិតដៃជើង ជំងឺតេតាណូស ជំងឺកញ្ជ្រិល របេងជាដើម ។




រូបទី1.8. ថ្នាំវ៉ាក់សាំង

## ៣. ការប្រើប្រាស់ថ្នាំ

មនុស្សខ្លះប្រើថ្នាំបានត្រឹមត្រូវតាមវេជ្ជបញ្ជា ប៉ុន្តែមនុស្សខ្លះទៀតប្រើថ្នាំខុសពីវេជ្ជបញ្ជា ។ ថ្នាំអាចផ្តល់ផលប្រយោជន៍ ប៉ុន្តែវាក៏អាចផ្តល់នូវទោសបានដែរ ។ ប្រសិនបើយើងប្រើវាខុសរបៀបវានឹងបណ្តាលឱ្យយើងទទួលរងគ្រោះថ្នាក់ ។ ឧទាហរណ៍ខាងក្រោមនេះបង្ហាញពីការប្រើប្រាស់ថ្នាំត្រឹមត្រូវ និងមិនត្រឹមត្រូវ ។

- ការប្រើប្រាស់ថ្នាំត្រឹមត្រូវ



*រូបទី1.9. លេបថ្នាំដើម្បីបំបាត់គ្រុនក្តៅ និងក្អក*



*រូបទី1.10. លេបថ្នាំបំបាត់ការឈឺក្បាល*

- ការប្រើប្រាស់ថ្នាំមិនត្រឹមត្រូវ

ដើម្បីរត់ឱ្យលឿន

ដើម្បីឱ្យមានកម្លាំងខ្លាំង

ដើម្បីបំបាត់ទុក្ខព្រួយ

ដើម្បីបំបាត់ភាពចុញទ្រាន់ និងអផ្សុក

ដើម្បីចុះសម្រុងនឹងមិត្តភក្តិ







- ការប្រើប្រាស់ឱសថដោយខ្លួនឯងគ្មានវេជ្ជបញ្ជាហៅថា ***ប្រើឱសថខុស***។
- ការប្រើប្រាស់ឱសថច្រើនជាងវេជ្ជបញ្ជាហៅថា ***ប្រើឱសថខុស***។

# 4. សុវត្ថិភាពនៃការប្រើប្រាស់ឱសថ

ឱសថអាចធ្វើឱ្យខូចសុខភាព ប្រសិនបើយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ ។ ឥទ្ធិពលរបស់វាមិនសូវធ្ងន់ធ្ងររួមមាន ឈឺក្រពះ ឈឺក្បាល ឬអស់កម្លាំង ។ ឥទ្ធិពលរបស់វាធ្ងន់ធ្ងរណាស់រួមមាន ក្អួត ព្រិលភ្នែក វិលមុខ និងចុះខ្សោយ ។ ចូរអនុវត្តបម្រាប់សុវត្ថិភាពគ្រប់ពេល ដែលអ្នកប្រើប្រាស់ឱសថ ។




- មិនត្រូវប្រើឱសថណាមួយទេ លុះត្រាតែអ្នកត្រូវការវាខានមិនបានឬប្រើប្រាស់វាតាមដំបូន្មានគ្រូពេទ្យ ។



- ត្រូវពិភាក្សាជាមួយអ្នកឯកទេសពេទ្យគ្រប់ពេលមុននឹងប្រើឱសថណាមួយ ។



- ត្រូវតែអានបញ្ជានៅលើស្លាកថ្នាំជានិច្ច មុនពេលអ្នកប្រើឱសថ ។



- មិនត្រូវប្រើឱសថដែលមនុស្សមិនស្គាល់ណាម្នាក់ឱ្យអ្នកទេ ។ ។




- បោះចោលឱសថចាស់ៗនិងឱសថគ្មានស្លាកបិទ ។



- គ្រប់ឱសថទាំងអស់ត្រូវដាក់ឱ្យឆ្ងាយពីដៃកុមារ ។

## 5. ឱសថនៅក្នុងរាងកាយ

ឥទ្ធិពលរបស់ថ្នាំនៅក្នុងរាងកាយ អាស្រ័យទៅនិងប្រភេទនិងបរិមាណឱសថដែលមនុស្សម្នាក់ៗប្រើ និងវិធីប្រើប្រាស់ឱសថនោះ ។ ថ្នាំចូលទៅក្នុងរាងកាយតាមវិធីបីបែបសំខាន់ ។ ប្រសិនបើគេលេបឱសថនោះ វានឹងធ្លាក់ចូលទៅក្នុងក្រពះដូចជាអាហារដែរ ។ ឱសថខ្លះត្រូវលេបនៅពេលបរិភោគអាហារ ។ ថ្នាំរលាយនៅក្នុងក្រពះឬពោះវៀនតូច បន្ទាប់មកវាជ្រាបចូលទៅក្នុងសរសៃឈាម ហើយដឹកនាំទៅកាន់ថ្លើម ។

ឱសថខ្លះទៀតអាចចាក់បញ្ចូលដោយផ្ទាល់ទៅក្នុងសរសៃវ៉ែនចូលទៅក្នុងជាលិកាសាច់ដុំ ។ ថ្នាំដែលចាក់បញ្ចូលមានឥទ្ធិពលរហ័ស ពីព្រោះវាជ្រាបចូលយ៉ាងរហ័សទៅក្នុងសរសៃឈាមដោយផ្ទាល់បន្ទាប់មកទៅកាន់ថ្លើម ។

ថ្នាំខ្លះទៀតដែលស្រូបចូលតាមច្រមុះ ជ្រាបចូលទៅក្នុងសរសៃឈាមដោយឆ្លងកាត់តាមសួត ។ ឱសថដែលហឺតចូល ត្រូវតែឆ្លងកាត់តាមភ្នាសស្លេស្មនៃរន្ធច្រមុះមុនពេលជ្រាបចូលទៅក្នុងសរសៃឈាម ។

**មេរៀនសង្ខេប**

- ថ្នាំជាធាតុគីមីផ្សេងពីអាហារ ។ នៅពេលវាចូលទៅក្នុងរាងកាយ វាធ្វើឱ្យមានការប្រែប្រួលនៅក្នុងខ្លួន ។ ថ្នាំមានពីរប្រភេទ ថ្នាំស្របច្បាប់និងថ្នាំខុសច្បាប់ ។ ស្រា បារី កញ្ឆា អាភៀនជាគ្រឿងញៀន ។
- ឱសថមានបីប្រភេទសំខាន់គឺ វ៉ាក់សាំង ឱសថបន្ធូរបន្ថយការឈឺចាប់ និងអង់ទីប្យូទិច ។
- ការប្រើប្រាស់ឱសថដោយខ្លួនឯងគ្មានវេជ្ជបញ្ជាត្រឹមត្រូវឬប្រើច្រើនជាងវេជ្ជបញ្ជាហៅថា ***ការប្រើឱសថខុសច្បាប់*** ។
- ឱសថចូលទៅក្នុងរាងកាយតាមវិធីបីបែបសំខាន់ ការលេបតាមមាត់ ការចាក់បញ្ចូល និងការហឺតតាមច្រមុះ ។

## ? សំណួរ

1. តើថ្នាំជាអ្វី ? តើថ្នាំចែកជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើគ្រឿងញៀនមានអ្វីខ្លះ ?
3. តើឱសថផ្នែកសុខាភិបាលមានអ្វីខ្លះ ?
4. ចូរឱ្យឧទាហរណ៍ប្រភេទឱសថនីមួយៗ ។

មេរៀនទី

# 2 ថ្នាំជក់និងបារី

**ចប់មេរៀននេះ សិស្សអាច**

- ប្រាប់ឈ្មោះសារធាតុគីមីផ្សេងៗក្នុងផ្សែងបារី
- បង្ហាញពីឥទ្ធិពលនៃសារធាតុគីមីក្នុងផ្សែងបារី
- បកស្រាយពីជំងឺមួយចំនួនដែលបណ្តាលមកពីការជក់បារី
- រៀបរាប់ពីវិធីសាស្ត្របញ្ឈប់ការជក់បារី ។

នៅពេលបច្ចុប្បន្នគេប៉ាន់ស្មានថា ថ្នាំជក់បានសម្លាប់មនុស្សជាង 3 លាននាក់ក្នុងមួយឆ្នាំ ។ ដោយសំអាងទៅលើនិន្នាការថ្មី នៅទសវត្សរ៍ឆ្នាំ2020 ឬទសវត្សរ៍ឆ្នាំ2030 ចំនួនអ្នកស្លាប់នឹងកើនឡើងដល់ 10 លាននាក់ក្នុងមួយឆ្នាំ ដែល 70% នៃអ្នកស្លាប់ទាំងនោះស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។ ដើម្បីជាផលប្រយោជន៍ចំពោះសុខភាព យើងត្រូវតែយល់ដឹងពីសារធាតុគីមីនៅក្នុងថ្នាំជក់ ឬបារី ព្រមទាំងឥទ្ធិពលរបស់វាចំពោះសារពាង្គកាយ ។

## 1. សារធាតុគីមីក្នុងថ្នាំជក់ឬបារី




*រូបទី 2.1. សារធាតុគីមីដែលមាននៅក្នុងផ្សែងបារី*

នៅពេលបារីកំពុងឆេះ វាបញ្ចេញផ្សែងដែលមានសារធាតុគីមីជាង 4000 ប្រភេទ ភាគច្រើនជាធាតុពុលនិងធាតុធ្វើឱ្យកោសិការលាក ។ ក្នុងចំណោមនោះ មានសារធាតុគីមីយ៉ាងតិចក៏ 69 ប្រភេទដែលធ្វើឱ្យមនុស្សកើតជំងឺមហារីក ។ ប៉ុន្តែសារធាតុគីមីនៅក្នុងថ្នាំជក់ឬបារីក៏អាចបណ្តាលឱ្យមានជំងឺផ្សេងៗទៀតដែរ ។

## 2. ឥទ្ធិពលនៃសារធាតុគីមីក្នុងថ្នាំជក់ឬបារី

សារធាតុគីមីពុលសំខាន់ជាងគេនៅក្នុងផ្សែងបារីមានដូចខាងក្រោម ។

### 2.1. នីកូទីន

នីកូទីន ជាសារធាតុពុលនិងញៀនខ្លាំងបំផុត ។ ប្រសិនបើគេចាក់វាមួយតំណក់បញ្ចូលទៅក្នុងខួរកណ្តុរ នោះកណ្តុរនឹងស្លាប់ភ្លាម ។ នីកូទីន 7 តំណក់អាចសម្លាប់សត្វគោមួយក្បាលបាន ។ កាលណាយើងចុកថ្នាំឬស្រូបផ្សែងបារី នីកូទីននិងជ្រាបចូលយ៉ាងរហ័សទៅក្នុងសរសៃឈាមនៃមាត់ ច្រមុះ ឬសួត ។ បន្ទាប់មកវាចែកចាយទៅក្នុងសរីរាង្គទាំងអស់នៅគ្រប់សារពាង្គកាយ ។ ដោយសារតែសារធាតុនេះ ទើបអ្នកជក់បារីញៀន ហើយមិនអាចបញ្ឈប់ការជក់បារីបានឡើយ ។

### 2.2. ជ័រថា

ភាគច្រើនរសជាតិរបស់បារី អាស្រ័យទៅនឹងជ័រថានៅក្នុងថ្នាំជក់ ។ ជ័រថាជាធាតុរាវខាប់ ពណ៌ខ្មៅស្អិតដែលកើតឡើងនៅពេលបារីឆេះ ។ សារធាតុមួយចំនួននៅក្នុងជ័រថា ជាកាស៊ីណូសែនដែលបណ្តាលឱ្យកើតជំងឺមហារីកនៅត្រង់កន្លែងផ្សែងបារីចូលទៅប៉ះជាប្រចាំគឺ បបូរមាត់ ក្រអូមមាត់ អណ្តាត ដើមក បំពង់ខ្យល់ និងសួត ។ ក្រៅពីនេះ វាបណ្តាលឱ្យកើតជំងឺរលាកទងសួត ហើមសួត និងជំងឺផ្លូវដង្ហើមដទៃទៀត ។ វាក៏ធ្វើឱ្យក្រចកដៃ ធ្មេញ និងជាលិកាសួតឡើងពណ៌លឿងដែរ ។

### 2.3. ឧស្ម័នកាបូនម៉ូណូអុកស៊ីត

កាបូនម៉ូណូអុកស៊ីត ជាឧស្ម័នពុលគ្មានពណ៌ គ្មានក្លិន ដែលមាននៅក្នុងផ្សែងបារី ។ វាដូចគ្នាទៅនឹងឧស្ម័នដែលបញ្ចេញដោយរថយន្តនៅពេលបញ្ឆេះម៉ាស៊ីនដែរ ។ ឧស្ម័នកាបូនម៉ូណូអុកស៊ីតមានលទ្ធភាពភ្ជាប់ជាមួយគោលិកាក្រហមបានយ៉ាងមាំជាងម៉ូលេគុលអុកស៊ីសែន មានន័យថា កាបូនម៉ូណូអុកស៊ីតបានទៅជំនួសកន្លែងភ្ជាប់ជាច្រើនរបស់ម៉ូលេគុលអុកស៊ីសែនក្នុងគោលិកាក្រហម ដែលធ្វើឱ្យការចែកចាយអុកស៊ីសែនទៅឱ្យសារពាង្គកាយរបស់គោលិកាក្រហមត្រូវបាត់បង់ ។ កាបូនម៉ូណូអុកស៊ីតក៏ធ្វើឱ្យអុកស៊ីសែន ដែលមាននៅក្នុងឈាមជ្រាបចូលទៅក្នុងសាច់ដុំនិងសរីរាង្គផ្សេងៗដោយលំបាកដែរ ។ ដូចនេះនៅពេលពួកគេជក់បារី បេះដូងរបស់ពួកគេខំធ្វើការយ៉ាងខ្លាំងតែបានផលតិចតួច ។

## 2.4. សារធាតុផ្សេងទៀត

សារធាតុផ្សេងទៀត ក្រៅពីរៀបរាប់ខាងលើក៏អាចនាំឱ្យមានការរលាកប្រដាប់ដង្ហើមទាំងមូល ។

# 3. ផលប៉ះពាល់សុខភាព




*រូបទី2.2 គំនូសតាងផលអាក្រក់នៃផ្សែងបារីចំពោះសរីរាង្គកាយមនុស្ស*

## 3.1. ការជក់បារីនិងជំងឺបេះដូង

ការជក់បារីបណ្តាលឱ្យមានជំងឺបេះដូងសរសៃឈាមកូរ៉ូណែ ដែលលេចឡើងនូវលក្ខណៈសំខាន់ពីរគឺការចុកទ្រូងនិងការគាំងបេះដូង ។ ជំងឺទាំងពីរបែបនេះកើតឡើងដោយសារសរសៃអាកទែ ដែលនាំឈាមទៅចិញ្ចឹមសាច់ដុំបេះដូង (សរសៃឈាមកូរ៉ូណែ)ត្រូវបានស្ទះឬរួមតូច ។



*រូបទី2.3. កំណកខ្លាញ់ក្នុងសរសៃឈាម*

ការចុកទ្រូង ជាការឈឺចាប់យ៉ាងខ្លាំងនៅក្នុងទ្រូង ដែលកើតមានឡើងនៅពេលខំប្រឹងធ្វើអ្វីមួយ ហើយវានឹងធូរស្រាលមកវិញនៅពេលឈប់សម្រាក ។ ជំងឺគាំងបេះដូងកើតឡើងដោយសារការតៀតសរសៃឈាមឬកំណកខ្លាញ់ក្នុងសរសៃឈាមកូរ៉ូណែ ។ ដូចនេះ សរសៃឈាមស្ទះ ហើយឈាមមិនអាចហូរទៅដល់បេះដូង ដែលជាហេតុនាំឱ្យបេះដូងមិនអាចទទួលអាហារនិងអុកស៊ីសែនគ្រប់គ្រាន់សម្រាប់ដំណើរការបាន ។ នៅពេលនេះមនុស្សមានជំងឺគាំងបេះដូង ។

## 3.2. ការជក់បារីនិងជំងឺសួត

ការជក់បារីបណ្ដាលឱ្យមានជំងឺសួតច្រើនប្រភេទដែលមានគ្រោះថ្នាក់ ដូចជំងឺមហារីកសួតដែរ ។



*រូបទី2.4. ជំងឺហើមសួត*

- ***ជំងឺរលាកទងសួត*** : ការជក់បារីនាំឱ្យមានជំងឺរលាកទងសួតរ៉ាំរ៉ៃ ។ ទងសួតមានរោមល្អិតៗសម្រាប់សំអាតកម្ទេចកម្ទីធូលីនិងមេរោគដែលជ្រៀតចូលសួតតាមរយៈដង្ហើមចូល ។ ជ័រជាក្នុងផ្សែងបារីធ្វើឱ្យរោមល្អិតៗទាំងនេះ ធ្វើការមិនបានត្រឹមត្រូវដែលបណ្ដាលឱ្យធូលីនិងមេរោគជ្រៀតចូលសួតបានយ៉ាងងាយ ។ លក្ខណៈបែបនេះជាមូលហេតុដែលអ្នកជក់បារីក្អកញឹកញាប់ព្រមទាំងបញ្ចេញស្លេស្មច្រើនហួស ។ អ្នកជក់បារីនឹងកើតជំងឺរលាកទងសួត ។
- ***ជំងឺហើមសួត*** : ការជក់បារីក៏ជាមូលហេតុធំមួយនៃជំងឺហើមសួតដែរ ។ អ្នកជំងឺបាត់បង់លទ្ធភាពដកដង្ហើមបន្តិចម្ដងៗ ។ ពេលមានជំងឺហើមសួត ជញ្ជាំងខណ្ឌរវាងកូនថង់សួតត្រូវបានធ្លាយ ហើយបង្កើតបានថង់សួតធំៗចំនួន 2–3 ដែលធ្វើឱ្យអុកស៊ីសែនជ្រាបចូលទៅក្នុងសរសៃឈាមមានចំនួនតិចតួច ។ ដាយថាហេតុផ្ទៃសួតទាំងមូលរបស់អ្នកជំងឺរួមតូច ដែលតម្រូវឱ្យអ្នកជំងឺហើមសួត ដង្ហក់រកខ្យល់សម្រាប់ដកដង្ហើម ។
- ***ជំងឺមហារីក*** : ការជក់បារីក៏បណ្ដាលឱ្យកើតជំងឺមហារីកនៅលើសរីរាង្គផ្សេងៗដែរ ដូចជា មាត់ បំពង់ក សួត ក្រពះ ថ្លើម ប្លោកនោម ។ ដោយផ្អែកតាមការស្រាវជ្រាវបានបញ្ជាក់ឱ្យឃើញថា មហារីកសួត 80 % បណ្ដាលមកពីការជក់បារី ។ ឱកាសនៃការកើតជំងឺមហារីកស្របគ្នានឹងចំនួនបារីដែលបានជក់ មានន័យថាបើជក់បារីកាន់តែច្រើន ឱកាសកើតជំងឺមហារីកក៏កាន់តែច្រើនដែរ ។

## 4. ការជក់បារីដោយប្រយោល

ការស្រូបផ្សែងបារីពីអ្នកជក់ ជាការស្រូបយកខ្យល់ក្នុងបរិយាកាសដែលមានផ្សែងបារី ។ ប្រសិនបើអ្នកជក់បង្ហុយផ្សែងបារីចោលក្នុងបរិយាកាស អ្នកនៅក្បែរជកដង្ហើមចូលទាំងផ្សែងបារីដោយស្វ័យប្រវត្តិ ។ ការស្រូបផ្សែងបារីបែបនេះហៅថា ***ការជក់បារីអកម្ម*** ឬការជក់បារីដោយប្រយោល ។ ការស្រូបផ្សែងបារីពីគេ ក៏បណ្ដាលឱ្យមានជំងឺជាច្រើនមុខដូចអ្នកជក់បារីដែរ ។

### 4.1. ស្ត្រីមានផ្ទៃពោះ

ស្ត្រីមានផ្ទៃពោះ ដែលស្រូបផ្សែងបារីពីប្ដី ឬអ្នករួមការងារអាចមានគ្រោះថ្នាក់ចំពោះម្ដាយនិងទារកក្នុងផ្ទៃ ។ ជាទូទៅទារកដែលកើតពីម្ដាយជាអ្នកស្រូបផ្សែងបារីជាប្រចាំក្នុងអំឡុងពេលមានផ្ទៃពោះច្រើនកើតមកមិនគ្រប់ទម្ងន់ មិនគ្រប់លក្ខណៈ សុខភាពទារកទន់ខ្សោយ ប្រាជ្ញាមិនឆ្លាតវាងវៃ កូនកើតមកស្លាប់ភ្លាមឬកើតមិនគ្រប់ខែ ។

### 4.2. កុមារនិងផ្សែងបារី

កុមារទាំងឡាយ ដែលឪពុកម្ដាយជាអ្នកជក់បារី តែងទទួលផលប៉ះពាល់ដូចតទៅ ៖

- ការលូតលាស់យឺត ទាំងរាងកាយ ទាំងសតិបញ្ញា ប្រសិនបើកុមាររស់នៅក្នុងបរិយាកាស ដែលមានផ្សែងបារីយូរអង្វែង ។
- ប្រព័ន្ធស៊ាំចុះខ្សោយដែលងាយនិងទទួលរងជំងឺឆ្លងផ្សេងៗ ដូចជាជំងឺរលាកច្រមុះ រលាកបំពង់ករលាកសួត រលាកទងសួត ត្អូតរ៉ាំរ៉ៃ ជំងឺផ្ដាសាយ ។ល ។
- ចំពោះកុមារដែលមានជំងឺប្រចាំកាយស្រាប់ដូចជា ជំងឺហឺត ជំងឺបេះដូង ជំងឺសរសៃប្រសាទជាដើម ការជក់បារីរបស់ឪពុកម្ដាយ ធ្វើឱ្យសភាពជំងឺទាំងនេះកាន់តែធ្ងន់ធ្ងរឡើង ។
- ផ្ដល់គំរូអាក្រក់ដល់កូននិងយកតម្រាប់តាមឪពុកម្ដាយដែលជាអ្នកជក់បារី ។

### 4.3. ការិយាល័យនិងទីប្រជុំជន

គេចាត់ទុកផ្សែងបារីជាភ្នាក់ងារបង្កផលប៉ះពាល់ដល់បរិស្ថានដូចជា ឧស្ម័នពុលផ្សេងៗទៀតដែរ ។ ផ្សែងបារីដែលហុយវិលវល់ក្នុងកន្លែងធ្វើការ ក៏ជាមូលហេតុបណ្ដាលឱ្យការប្រមូលអារម្មណ៍ ការពិចារណា ភាពឆ្លាតវៃថយចុះ ។ ដូចនេះ គុណភាពការងារមិនល្អប្រសើរទេ ។ លើសពីនេះទៀត ការជក់បារីនៅកន្លែងធ្វើការប៉ះពាល់ដល់សីលធម៌ ជាពិសេសរំលោភសិទ្ធិអ្នកមិនជក់បារីទៀតផង ។

នៅទីប្រមូលផ្ដុំប្រជាជនច្រើនដូចជា វត្តអារាម មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា មធ្យោបាយធ្វើដំណើរសាធារណៈ ភោជនីយដ្ឋាន សណ្ឋាគារ រោងភាពយន្ត ។ល ។ ធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកមិនជក់

បារី ។ ក្រៅពីនេះវាបណ្តាលឱ្យបរិយាកាសនៅទីនោះអាប់អួរ មានក្លិនអាក្រក់ និងពិបាកដកដង្ហើម ។ ប្រសិនបើអ្នកជក់បារីមិនជក់នៅកន្លែងដែលមានប្រជាជនច្រើនទេនោះ មានន័យថាអ្នកបានជួយការពារមនុស្សជាច្រើនឱ្យចៀសផុតពីវិបាកផ្សេងៗដែលបណ្តាលមកពីផ្សែងបារី ។

## 5. បង្ការការជក់បារី


រូបទី25. បំរាមជក់បារី

ដើម្បីចៀសវាងបញ្ហាដូចបានរៀបរាប់ពីខាងលើ វិធីប្រសើរបំផុតគឺត្រូវតែកែប្រែផ្ទះសម្បែង កន្លែងធ្វើការ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីសាធារណៈ ផ្សេងៗឱ្យទៅជាកន្លែងគ្មានផ្សែងបារី មានន័យថា មិនអនុញ្ញាតឱ្យមានការជក់បារីនៅក្នុងផ្ទះ កន្លែងធ្វើការ ...ដាច់ខាត ។

រដ្ឋាភិបាលបានចូលរួមក្នុងការបង្ការការជក់បារី ដែលមានសកម្មភាពដូចខាងក្រោម ៖

- ដំឡើងជាបន្តបន្ទាប់នូវអត្រាពន្ធដាររបស់ថ្នាំជក់ ។
- ភ្ជាប់បម្រាមប៉ះពាល់សុខភាពលើកញ្ចប់បារីនិងជាមួយការផ្សាយពាណិជ្ជកម្ម ដោយធ្វើបែបនេះរហូតមានច្បាប់បញ្ឈប់ការផ្សាយពាណិជ្ជកម្មបារីជាស្ថាពរ ។
- ពង្រីកចំណេះដឹងអំពីថ្នាំជក់តាមរយៈសកម្មភាពអប់រំសុខភាព បណ្តាញព័ត៌មាន និងតាមសៀវភៅសិក្សា ។
- ហាមឃាត់ការឃោសនាលក់បារីតាមគ្រប់រូបភាពនិងមធ្យោបាយផ្សេងៗ ។
- បង្កើតច្បាប់ហាមជក់បារីនៅតាមមន្ទីរពេទ្យ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា កន្លែងធ្វើការ កន្លែងសាធារណៈផ្សេងៗ . . . ។
- បង្កើតច្បាប់ហាមឃាត់លក់បារីឱ្យក្មេងៗ ។

## 6. វិធីសាស្ត្របញ្ឈប់ការជក់បារី

### 6.1. ការតាំងចិត្ត

ដំបូងត្រូវតែមានការតាំងចិត្តយ៉ាងមុតមាំ ក្នុងការសម្រេចចិត្តឈប់ជក់បារី ។ ការតាំងចិត្តនេះជាចំណុចសំខាន់ណាស់ ព្រោះបើគ្មានការតាំងចិត្តទេនោះ ការឈប់ជក់បារីក៏មិនសម្រេចដែរ ។ កាលណាការតាំងចិត្តរបស់អ្នកជក់កាន់តែខ្លាំងក្លា ជោគជ័យនៃការផ្តាច់បារីក៏កាន់តែជាក់លាក់ដែរ ។

## 6.2. កាលបរិច្ឆេទឈប់ជក់បារី

បន្ទាប់ពីការតាំងចិត្ត អ្នកជក់ត្រូវកំណត់កាលបរិច្ឆេទឱ្យច្បាស់លាស់ ដើម្បីឈប់ជក់បារី ។ ថ្ងៃនេះជាពេលល្អបំផុតក្នុងការឈប់ជក់បារី ព្រោះការពន្យារពេលអាចធ្វើឱ្យការតាំងចិត្តធ្លាក់ចុះ ។

## 6.3. ការត្រៀមខ្លួនឈប់ជក់បារី

នៅពេលតាំងចិត្តបានមុតមាំ និងកំណត់កាលបរិច្ឆេទឈប់ជក់បារីបានហើយ អ្នកជក់ត្រូវត្រៀមខ្លួនអនុវត្តសកម្មភាពដូចខាងក្រោម ៖

- បោះបារីនិងចានគោះគ្រញូមបារីចោល ។
- នៅឆ្ងាយពីអ្នកជក់បារី ព្រោះការឃើញគេជក់បារីនាំឱ្យមានចំណង់ជក់ ។
- កុំផឹកគ្រឿងស្រវឹង ឬកាហ្វេក្នុងដំណាក់កាលដំបូងនៃការឈប់ជក់បារី ។ គួរបរិភោគបន្លែនិងផ្លែឈើឱ្យបានច្រើន ។
- ទទួលទានដំណេកបានគ្រប់គ្រាន់ និងហាត់ប្រាណទៀងទាត់ដើម្បីឱ្យអារម្មណ៍ល្អ ។
- សុំការគាំទ្រពីក្រុមគ្រួសារ និងមិត្តភក្តិ ។

## 6.4. រោគសញ្ញាញៀន

ក្នុងអំឡុងប៉ុន្មានថ្ងៃដំបូងនៃការឈប់ជក់បារី រោគសញ្ញាញៀនមួយចំនួនកើតឡើង ចំណង់ជក់បារីខ្លាំង (ជូរមាត់) ហៀរទឹកមាត់ តប់ប្រមល់ ចិត្តមិននឹងនរ គិតអ្វីមិនចេញ ឆាប់ខឹង មួម៉ៅ ឈឺក្បាល វិលមុខ ធីងធោង សម្រាន្តមិនលក់ ។ល។ រោគសញ្ញាទាំងនេះនឹងថយចុះជាលំដាប់ ។ នៅថ្ងៃទី 3 ឬទី 4 នៃការឈប់ជក់បារី អ្នកជក់ក៏មានអាការៈស្រួលខ្លួនអារម្មណ៍ភ្លឺថ្លា និងដកដង្ហើមស្រួលឡើងវិញ ។

## 6.5. វិធីទប់ទល់នឹងចំណង់ខ្លាំង

ពេលអ្នកជក់មានចំណង់ជក់បារីខ្លាំងម្តងៗ ត្រូវអនុវត្តតាមវិធីសាមញ្ញតែមានប្រសិទ្ធភាពខ្ពស់ ។

- ក្រេបទឹកបន្តិចម្តងៗឱ្យអស់មួយកែវ ឬពីរកែវ ។
- ដកដង្ហើមវែងៗបាន 3 ទៅ 4 ដង ។
- ធ្វើការងារបន្លប់ការចង់ជក់បារី : ដើរជុំវិញផ្ទះ ទំពាស្ករកៅស៊ូ ធ្វើពលកម្មស្រាលៗ អានសៀវភៅ ជជែកលេងជាមួយអ្នកមិនជក់ ។ល ។
- ហាត់ប្រាណឬលេងកីឡា ។
- ចំពោះអ្នកជឿសាសនា អាចអង្គុយសមាធិ ភាវនាចម៌ ។

វិធីទាំងនេះ អាចបន្ថយចំណង់ជក់បារីខ្លាំងដែលមានរយៈពេលតែ 3 – 5 នាទីប៉ុណ្ណោះ ។ ចូរអនុវត្តវិធីទាំងនេះរាល់ពេលមានចំណង់ជក់បារីរហូតលែងមានអារម្មណ៍ទាំងនេះកើតឡើង ។

**មេរៀនសង្ខេប**

- នៅក្នុងផ្សែងបារីមានសារធាតុគីមីជាង 4000 ប្រភេទ ភាគច្រើនជាសារធាតុពុលនិងធាតុធ្វើឱ្យគោសិការលាក ។ ក្នុងចំណោមនោះមានសារធាតុគីមីយ៉ាងតិច 69 ប្រភេទ ដែលធ្វើឱ្យមនុស្សកើតជំងឺមហារីក ។
- សារធាតុគីមីពុលសំខាន់ៗនៅក្នុងផ្សែងបារីមាន : នីកូទីន កាបូនម៉ូណូអុកស៊ីត ជាតិជ័រថា ។
- ជំងឺដែលបង្កឡើងពីការជក់បារីមាន ជំងឺរលាកទងសួត ជំងឺហើមសួត ជំងឺគាំងបេះដូង ជំងឺមហារីកនៅលើសរីរាង្គផ្សេងៗ ។
- ការស្រូបផ្សែងបារីបណ្តាលឱ្យមានជំងឺច្រើនមុខដូចអ្នកជក់បារីដែរ ។ ដើម្បីបង្ការការស្រូបផ្សែងបារី ត្រូវតែប្រែផ្ទះសម្បែង សាលារៀន កន្លែងធ្វើការ ទីកំសាន្ត . . . ឱ្យទៅជាកន្លែងគ្មានផ្សែងបារី ។
- វិធីសាស្ត្របញ្ឈប់ការជក់បារីមាន ការតាំងចិត្ត ការកំណត់កាលបរិច្ឆេទឈប់ជក់បារីនិងត្រៀមខ្លួនឈប់ជក់បារី ។

## ? សំណួរ

1. តើសារធាតុគីមីក្នុងផ្សែងបារីមានប៉ុន្មានប្រភេទ ?
2. តើសារធាតុពុលសំខាន់ៗក្នុងផ្សែងបារីមានអ្វីខ្លះ ?
3. តើជ័រថា មានឥទ្ធិពលដូចម្តេចខ្លះ ?
4. តើការជក់បារីបណ្តាលឱ្យកើតជំងឺអ្វីខ្លះ ?
5. ដូចម្តេចហៅថាការជក់បារីដោយប្រយោល ?
6. តើអ្នកស្រូបផ្សែងបារីអាចមានជំងឺដែរឬទេ ? ហេតុអ្វី ?
7. តើរាជរដ្ឋាភិបាលធ្វើដូចម្តេចដើម្បីបង្ការការជក់បារី ?

មេរៀនទី

# 3 គ្រឿងស្រវឹង

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ពាក្យគ្រឿងស្រវឹង
- ❑ ប្រាប់ឈ្មោះជំងឺដែលបណ្តាលពីគ្រឿងញៀន
- ❑ ពណ៌នាពីវិធីសាស្ត្រជួយផ្តាច់គ្រឿងញៀន ។

ស្រាមិនមែនជាគ្រឿងញៀនខុសច្បាប់ទេ ប៉ុន្តែយើងមិនគួរផឹកស្រាឡើយ ។ ស្រាជាវត្ថុរាវដូចជា ស្រាបៀ ស្រាស ស្រាទំពាំងបាយជូរ ដែលផលិតចេញពីផ្លែឈើ ឬគ្រាប់ធញ្ញជាតិ ។

## 1. ស្រាជាគ្រឿងស្រវឹង



*រូបទី3.1. ស្រាប្រភេទផ្សេងៗ*

អាល់កុលសុទ្ធគ្មានពណ៌និងគ្មានរសជាតិទេ ។ ស្រាមានពណ៌និងរសជាតិខុសៗគ្នា ដោយសារធាតុផ្សំដទៃទៀតដែលគេបន្ថែម ។

គ្រឿងស្រវឹង ជាសារធាតុធ្វើឱ្យធ្លាក់ទឹកចិត្ត មិនមែនសារធាតុដែលបង្កើនកម្លាំងចិត្តដូចការគិតរបស់មនុស្សភាគច្រើននោះទេ ។ គ្រឿងស្រវឹងធ្វើឱ្យយឺតយ៉ាវដល់ការបញ្ជូនព័ត៌មានពីខួរក្បាលទៅសរីរាង្គ ។ គ្រឿងស្រវឹងប៉ះពាល់ដល់ការប្រមូលអារម្មណ៍និងពន្យឺតរយៈពេលឆ្លើយតបទៅនឹងហេតុការណ៍ចៃដន្យណាមួយ ។

## 2. គ្រឿងស្រវឹងនិងរាងកាយ

គ្រឿងស្រវឹងជ្រាបចូលដោយផ្ទាល់ទៅក្នុងចរន្តឈាម តាមក្រពះ និងពោះវៀនតូច ។ អាហារដែលមាននៅក្នុងក្រពះ បន្ថយអត្រាជ្រាបចូលនៃគ្រឿងស្រវឹង ប៉ុន្តែមិនកាត់បន្ថយកម្រិតនៃការពុល ឬស្រវឹងទេ ។ គ្រឿងស្រវឹងត្រូវបានចែកចាយទៅគ្រប់សរីរាង្គដែលមានជាតិទឹក ប៉ុន្តែមិនជ្រាបចូលទៅក្នុងជាលិកាខ្លាញ់ទេ ។ ថ្លើមបំបែកគ្រឿងស្រវឹងជាង 90 % ឯចំនួននៅសល់តិចតួចត្រូវបានបញ្ចេញ

ចោលតាមទឹកនោម ញើស និងដំណកដង្ហើម ។ ថ្លើមអាចបំបែកសារធាតុពុលប្រហែល $\frac{3}{4}$ នៃកម្រិតស្តង់ដាក្នុងមួយម៉ោង ។ ការស្វាងស្រវឹងត្រូវការពេលវេលា ចំណែកការងូតទឹកត្រជាក់ ហាត់ប្រាណ ផឹកកាផេខ្មៅ ការស្រូបខ្យល់បរិសុទ្ធ ឬការក្អួតមិនធ្វើឱ្យឆាប់ស្វាងស្រវឹងទេ ។

## 3. ផលប៉ះពាល់រាងកាយ

ក្រោយពីបានផឹក 2 – 3 កែវ គេអាចមានអារម្មណ៍ធូរស្បើយ កាត់បន្ថយការប្រមូលអារម្មណ៍ ប្រតិកម្មឆ្លើយតបយឺត ។ បើផឹក 2 – 3 កែវបន្តទៀត គេមានអាកប្បកិរិយាឆ្គាំឆ្គង និយាយខ្សុលៗ និងមានការរំជួលចិត្ត (កើតទុក្ខ សប្បាយ ឬក្រេវក្រោធ) ។ បើផឹកបន្តទៀត គេមានអារម្មណ៍ច្របូកច្របល់ ស្រវាំងភ្នែក សមត្ថភាពបញ្ចាសាច់ដុំចុះខ្សោយ ។ បើផឹកបន្តទៀត គេនឹងក្អួត ហើយដេកលក់ ។ បើផឹកច្រើនជាងនេះ អាចបណ្តាលឱ្យសន្លប់ ឬស្លាប់ក៏មាន ។ ការផឹករយៈពេលយូរអាចប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពដូចជា បាត់បង់ការចងចាំ វង្វេងវង្វាន់ កើតមហារីកមាត់ បំពង់អាហារ ថ្លើម កើនសម្ពាធឈាម បេះដូងរីក រលាកក្រពះ ដំបៅក្រពះ ឈាមក្នុងក្រពះ រលាកថ្លើម ក្រិនថ្លើម រលាកលំពែង . . . ។

## 4. ស្ត្រីនិងគ្រឿងស្រវឹង

ការស្រាវជ្រាវបង្ហាញថា គ្រឿងស្រវឹងផ្តល់ផលប៉ះពាល់ដល់ស្ត្រី ខុសប្លែកពីបុរស ។

- ប្រសិនបើបុរសនិងស្ត្រីទទួលទានគ្រឿងស្រវឹងក្នុងបរិមាណដូចគ្នា ស្ត្រីនោះនឹងមានកំហាប់ជាតិអាល់កុលក្នុងឈាមខ្ពស់ជាងបុរស ។ មូលហេតុមកពីរាងកាយស្ត្រីផ្ទុកជាតិខ្លាញ់ច្រើនជាងនិងជាតិទឹកតិចជាងរាងកាយបុរស ។ ស្ត្រីតែងមានទម្ងន់ខ្លួនស្រាលជាងបុរស ។
- ស្ត្រីងាយនិងខូចថ្លើម ហើយទទួលរងផលប៉ះពាល់ដល់សុខភាពផ្សេងៗទៀតជាងបុរស ទោះបីទទួលទានគ្រឿងស្រវឹងតិចជាងបុរសក៏ដោយ ។ម្យ៉ាងទៀតស្ត្រីដែលទទួលទានគ្រឿងស្រវឹងច្រើន ប្រឈមមុខនឹងការកើតជំងឺមហារីកដោះនិងរោគស្ត្រី ជាងស្ត្រីដែលមិនទទួលទានគ្រឿងស្រវឹង ។
- តាមរយៈការស្រាវជ្រាវបានបង្ហាញថា ប្រតិកម្មរបស់ស្ត្រីទៅនិងគ្រឿងស្រវឹងប្រែប្រួលទៅតាមវដ្តរដូវរបស់ស្ត្រី ដោយសារកម្រិតខុសៗគ្នានៃអរម៉ូន ។ ស្ត្រីដែលប្រើប្រាស់ថ្នាំពន្យារកំណើតត្រូវការពេលវេលាដើម្បីបញ្ចេញជាតិអាល់កុលពីរាងកាយយូរជាងស្ត្រីដែលមិនប្រើប្រាស់ថ្នាំពន្យារកំណើត ។

ដោយសារមូលហេតុទាំងនេះ ទើបអ្នកជំនាញផ្នែកសុខាភិបាលផ្តល់យោបល់ដល់ស្ត្រីឱ្យទទួលទានគ្រឿងស្រវឹងតិចជាងបុរស ។

ចំពោះស្ត្រីមានផ្ទៃពោះ ជាតិអាល់កុលដែលទទួលទាន ឆ្លងកាត់សុកទៅដល់ទារក ។ ការទទួលទានគ្រឿងស្រវឹងពេលមានផ្ទៃពោះ អាចបណ្តាលឱ្យមានបញ្ហាដូចជា ធ្លាក់ឈាម រលូតកូន ឬកូនកើតមិនគ្រប់ខែ ។ ទារកដែលកើតពីម្តាយញៀនគ្រឿងស្រវឹង អាចមានអាការៈញៀនក្រោយពេលកើតនិងមានចង្កោមរោគសញ្ញាស្លាប់ដោយគ្រឿងស្រវឹង ។ ទារកដែលមានចង្កោមរោគសញ្ញាទាំងនេះ អាចមានមុខមាត់មិនប្រក្រតីនិងពិការផ្នែករាងកាយនិងបញ្ញា ។

អង្គការពិភពលោកផ្តល់ដំបូន្មានថា គ្មានការទទួលទានគ្រឿងស្រវឹងដែលមានសុវត្ថិភាពទេ ក្នុងអំឡុងពេលមានផ្ទៃពោះ ។ ដើម្បីសុវត្ថិភាពគភ៌ ស្ត្រីមានផ្ទៃពោះមិនត្រូវទទួលទានគ្រឿងស្រវឹងទាល់តែសោះ ។

# 5. វិធីសាស្ត្រផ្តាច់ការញៀនគ្រឿងស្រវឹង

## 5.1. ការប្រើប្រាស់ឱសថ

ឱសថមួយចំនួនមានឥទ្ធិពលក្នុងការកាត់បន្ថយអាការៈញៀនដែលអាចកើតមាននៅពេលកំពុងផ្តាច់គ្រឿងស្រវឹង ។ អ្នកដែលអាចចេញវេជ្ជបញ្ជាឱ្យអ្នកញៀនប្រើឱសថបានមានតែគ្រូពេទ្យឯកទេស ឱសថស្ថានឯកទេស និងគ្រូពេទ្យឯកទេស ដែលមានការអនុញ្ញាតត្រឹមត្រូវ ។ ដើម្បីឱ្យមានប្រសិទ្ធភាព អ្នកញៀនគ្រឿងស្រវឹងត្រូវប្រើឱសថនេះគួបផ្សំជាមួយការតាំងចិត្តខ្ពស់និងការផ្តល់ប្រឹក្សាពីអ្នកឯកទេស ។

## 5.2. ការផ្តល់ប្រឹក្សា

ការប្រឹក្សាផ្តាច់ការញៀនគ្រឿងស្រវឹង ធ្វើឡើងនៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលគ្រឿងស្រវឹង ។ ឯការប្រឹក្សាខ្លះទៀតធ្វើឡើងដោយមានការណាត់ជួបជាមួយអ្នកញៀនគ្រឿងស្រវឹងឱ្យបានទៀងទាត់ ។ វិធីប្រឹក្សានីមួយៗមានប្រសិទ្ធភាពខុសៗគ្នាលើអ្នកញៀនគ្រឿងស្រវឹង ។

## 5.3. អន្តរាគមន៍ត្រួសៗ

អ្នកផ្តល់អន្តរាគមន៍ អាចជាមនុស្សធម្មតា ដែលបានទទួលការបណ្តុះបណ្តាល ។ អ្នកទើបតែចាប់ផ្តើមប្រើប្រាស់គ្រឿងស្រវឹង ត្រូវជួបផ្ទាល់ជាមួយអ្នកផ្តល់អន្តរាគមន៍រយៈពេល 5 – 30 នាទី ដើម្បីសាកសួរព័ត៌មាននិងទទួលឯកសារអប់រំពីរបៀបកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់គ្រឿងស្រវឹងសម្រាប់ជួយខ្លួនឯង ។ អ្នកផ្តល់អន្តរាគមន៍ត្រួសៗ អាចណាត់ជួបជាមួយអ្នកញៀនជាទៀងទាត់ ដើម្បីតាមដាននិងបន្តជួយអន្តរាគមន៍ ។

## មេរៀនសង្ខេប

- ស្រាជាគ្រឿងស្រវឹងដែលធ្វើឱ្យអ្នកជំងឺធ្លាក់ទឹកចិត្ត ។ ស្រាជ្រាបចូលដោយផ្ទាល់នៅក្នុងចរន្តឈាមតាមក្រពះ ពោះវៀនតូច ។ ថ្លើមបំបែកគ្រឿងស្រវឹងជាង ๙០ % ឯចំនួននៅសល់តិចតួចត្រូវបានបញ្ចេញចោលតាមទឹកនោម ញើស និងដំណកដង្ហើម ។
- ផលប៉ះពាល់រយៈពេលយូរមាន មហារីកមាត់ បបូរមាត់ បំពង់អាហារ បេះដូងរីក រលាកក្រពះ រលាកលំពែង ក្រិនថ្លើម ... ។
- ការទទួលទានគ្រឿងស្រវឹងពេលមានផ្ទៃពោះ បណ្តាលឱ្យធ្លាក់ឈាម រលូតកូន កូនកើតមិនគ្រប់ខែ ។ទារកដែលកើតពីម្តាយញៀនគ្រឿងស្រវឹងអាចញៀនក្រោយពេលកើត ជួនកាលទារកមានមុខមាត់មិនប្រក្រតីនិងពិការផ្នែករាងកាយនិងបញ្ញា ។
- វិធីជួយផ្តាច់គ្រឿងស្រវឹងមានការប្រើប្រាស់ឱសថ ការផ្តល់ប្រឹក្សា អន្តរាគមន៍គ្រួសា ។

## ? សំណួរ

1. តើជាតិញៀននៅក្នុងស្រាជាអ្វី ?
2. នៅពេលផឹកចូល តើស្រាជ្រាបទៅកន្លែងណាខ្លះ ?
3. តើការផឹកស្រាបណ្តាលឱ្យកើតជំងឺអ្វីខ្លះ ?
4. តើការទទួលទានគ្រឿងញៀនស្រវឹងពេលមានផ្ទៃពោះមានផលប៉ះពាល់ដូចម្តេច ?

## ? សំណួរនិងលំហាត់ជំពូក 5

### I. ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. គ្រឿងញៀនមាន

☐ក. ថ្នាំក្អក ☐ខ. អង់ទីប្យូទិច

☐គ. បារី ☐ឃ. វ៉ាក់សាំង ។

2. នៅក្នុងផ្សែងបារីមានសារធាតុគីមីជាង :

☐ក. 1000 ប្រភេទ ☐ខ. 2000 ប្រភេទ

☐គ. 3000 ប្រភេទ ☐ឃ. 4000 ប្រភេទ ។

3. សារធាតុគីមីនៅក្នុងផ្សែងបារីដែលបណ្ដាលឱ្យកើតជំងឺមហារីកគឺ

☐ក. អាល់កុល ☐ខ. ជ័រថា

☐គ. និកូទីន ☐ឃ. កាបូនម៉ូណូអុកស៊ីត ។

4. គ្រឿងស្រវឹងភាគច្រើនត្រូវបានបំបែកដោយ

☐ក. ក្រពះ ☐ខ. ពោះវៀន

☐គ. ថ្លើម ☐ឃ. សួត ។

## II. ចូរបំពេញចន្លោះឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. សារធាតុញៀននៅក្នុងថ្នាំជក់ជា . . . . . . . . . . ។
2. សារធាតុញៀននៅក្នុងស្រាជា . . . . . . . . . . ។
3. សារធាតុគីមីដែលសម្លាប់ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបង្កជំងឺជា . . . . . . . . . . ។
4. សារធាតុគីមីពុលសំខាន់ក្នុងផ្សែងបារីជា . . . . . . . . . . ។
5. ការស្រូបផ្សែងបារីពីអ្នកជក់ហៅថា . . . . . . . . . . ។
6. គ្រឿងស្រវឹងពន្យឺតការបញ្ជូនព័ត៌មានពីខួរក្បាលទៅ . . . . . . . . . . ។
7. គ្រឿងស្រវឹងជ្រាបចូលដោយផ្ទាល់ទៅក្នុងចរន្តឈាម . . . . . . និង . . . . . . ។

## III. ចូរឆ្លើយសំណួរខាងក្រោម

1. តើគេចែកឱសថជាក្រុមដោយសារអ្វី ? ចូរឱ្យឧទាហរណ៍បញ្ជាក់ ។
2. ហេតុអ្វីបានជានៅពេលខ្លះ ឱសថផ្តល់ទុក្ខទោសដល់រាងកាយ ?
3. ចូររៀបរាប់ពីសុវត្ថិភាពនៃការប្រើប្រាស់ឱសថ ?
4. តើឱសថចូលក្នុងរាងកាយតាមវិធីណាខ្លះ ? ចូររៀបរាប់ពីវិធីនីមួយៗ ។
5. ហេតុអ្វីបានជាការជក់បារីបណ្ដាលឱ្យមានជំងឺមហារីក ?
6. តើការជក់បារីបណ្ដាលឱ្យប៉ះពាល់បេះដូងដូចម្ដេចខ្លះ ?
7. តើវិធីសាស្ត្រឈប់ជក់បារីមានប៉ុន្មានដំណាក់ ? អ្វីខ្លះ ?
8. ហេតុអ្វីបានជាគ្រឿងស្រវឹងផ្តល់ផលប៉ះពាល់ដល់ស្ត្រីខ្លាំងជាងបុរស ?
9. តើរោគសញ្ញាញៀនអ្វីខ្លះ កើតឡើងនៅពេលបញ្ឈប់ការជក់បារី ?
10. នៅពេលចូលដល់ក្នុងឈាម តើគ្រឿងស្រវឹងចែកចាយទៅកន្លែងណា ?
11. តើមានវិធីសាស្ត្រអ្វីខ្លះ ដើម្បីផ្តាច់ការញៀនគ្រឿងស្រវឹង ?